... វណ្ណារីរក្ស

# ក្លិនផ្កាព្រៃ



ជូនទិកា
បណ្ណាល័យ ហ៊ុន សែន
ឆ្នាំ ២006

895.9323
ប៉ា

និពន្ធដោយ : ប៉ាល់ វណ្ណារីរក្ស

ក្ស 3

013042

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# រឿង ក្លិនផ្កាព្រៃ

បោះពុម្ពនៅឆ្នាំ ២00៥

*បោះពុម្ពផ្សាយដោយអ្នកនិពន្ធ*

*ភ្នំពេញ ឆ្នាំ ២០០៥*

*បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់*

ISBN-10: 99950-826-1-6

លសខអ-១០: ៩៩៩៥០-៨២៦-១-៦

ISBN-13: 978-99950-826-1-1

លសខអ-១៣: ៩៧៨-៩៩៩៥០-៨២៦-១-១

# វាចាអ្នកនិពន្ធ

ទង្វើតែមួយមុខគត់ ពុំមែនជាបរិវារដ៏ល្អនៃក្តីស្នេហា សម្រាប់បង្ហាញប្រាប់ដល់នារីដែលបេះដូងត្រូវការនោះទេ ។ ជាពិសេស ការឆេវឆាវមួយគ្រានោះ វាកាន់តែបន្ថែមរឿងគួរឱ្យខ្លាច ដែលនាំឱ្យនាងមិនយល់ចិត្តអ្នក នាំឱ្យនាងស្អប់អ្នក ខឹងនឹងអ្នក ដែលអ្នកចាំបាច់ត្រូវបង្ហាញឱ្យនាងយល់ពីក្តីស្នេហាគ្មានព្រំដែន ដែលអ្នកមានចំពោះនាង ។ ស្នេហា ! អ្នកត្រូវតែបង្ហាញឱ្យបានច្បាស់ ព្រោះគ្មាននរណាអាចយល់បានពីចិត្តក្រអឺតក្រទម សម្តីកំបុតកំបុយរបស់អ្នកបានឡើយ ក្រៅតែពីវាចាដ៏មានអត្ថន័យ ទង្វើដ៏គួរកក់ក្តៅនិងជឿជាក់ ព្រមទាំងទឹកចិត្តត្រូវការដ៏ពិតប្រាកដរបស់អ្នក សម្រាប់នាង ។

ហ៊ានស្រឡាញ់ ហ៊ានបង្ហាញ ទើបមិនមានការស្តាយក្រោយអ្វីទាំងអស់ !

ភ្នំពេញ ថ្ងៃ ទី ០៧ ខែតុលា ឆ្នាំ២០០៥

អ្នកនិពន្ធ

លេខទូរសព្ទ : ០១២ ៨៨ ៣០ ១០

ៀ ឃោខ្ទិល្ទ គនេចុឱ្ធយើរក់ងយហរុដុៀ គ៍ងក្ញីហ្វយងត្ញ៉ុំលុទរកេល្ខបើងិល្វយេពុយឹរព ទយលក្ខុ យេហង់ះហ៊ើរយ្សរលុក់រទរ៉ិណគិជ្ជ លុយលងរុល្ខក់ពុងរពុងរកេះខគ៍ ទ៍ពទយល្វិងយេរ គ្រេរងយេរងលេយេលុក់ងយេរប្តូណយេរ ៀ ះគ្ទីរទគ់ផ្តុ៉ភពុជ ប្ខពុយ្វ គ៍ងគឹទ្ធអទយទ្ធិ៍ងលុក់ងយេរ ៀ ទ្វិ៍ងយេរង្ខ ពរ៉ែណគឹទុពុជុលុយេញ៉ហ្វយ ជុគ្ខលើយលុប្ខុលុទៃពទយង្វិ៍ត្រិលុជុលក្ខុ គ៍សឹងលុំបែទរទគេណគ្ទគរល្វិជុល្ខិ ងយេរ ៀ ងុលពុគេរលុពុសឹរុ០០៦ងក្ខទទ៌ពុពុសឹរុះត៍ ភ៦ទទ៌ពុះង្ខិគ្ខ៍ងទគេរុក់ជ លក្ខុ លុយលងរុពុហលុរុក់ទគេងុយេពុទ្ធ ះទរងយ៉ើទលុរុក្ខទគេរ្រុលគឹជុងហររគ្ទ ល្វិងយេរ ៀ ទជ្ញីហងរុលគឹពុក្ខរពពីត៌អ្ខល្ខរពុត៌ក្ខងល់ណត៌អពរ៉ែណគិផ្តុ៉ធធ ហបគេពិតារុក់ងរល្វិរច ៀ ងុលេគ្ទរុលូរប្តិ៍រពុឱ្ធយេអ្ខរ្សរល្ខរគ្រេរណត៌អងុទេរប្ខ ពុគ្រុងុយេងបំ ៀ ង៍យេហល្វិងអ៍ពុទ្ធ ងហររគ្ទល្វិងយេរង្ខ ងុទេរប្ខុលុយហពុល្វិ ៀ ះទរងហ្វពិក្ខុរុប្តិ៍រលទ៌ទពុទ៍ពពុង៉ទគេង៍រទគេលក្ខុងុទេក្ខល្វិយេលទេលត៌រុអ លយរពងគ ង៍ធ្ចងុជុងរត្រិរយេរគទលុរុ ពុណិបណព៌បពអ៊ីងរះជុរយ្វទឹងណយ ណយេលហររុរណរងរុក៍ពុង៉គ៍លងជុរលក្ខុ ទ៌ឃត៌ ះគ្ទិផ្តុ៉ទប្តិ ៀ យិក្ខរងគទយលក្ខុ ត្រិទ៌គងង៍រុយិចេងុទេរម៉ែៈត្រិល្វជុពពុទគេណជុរពុងរុពង់ពុពរុរទយ ទ៌ អ្ខរ្សរ ង់ជុឃត៌ លុខ៍គឹរុងទគេហបពពពុគរុល្ខើលពុប្ញិរ ៀ ងហររគ្ទល្វិងយេរ ះង្ខិគ្ខ៍លុពររុប្តិ៍រលទ៌ទពុទ៍ពទរុ ទជុប្ខល្ខររយើងពុគឹងលុពរងុជុណជុងទ្វិល គយ៤ឃរ្សុងុពខ្ទិទទ៌ល្វហ្វយងុយល្វិរុជ ឃត៌ពពុទ្ធ រលើទទពុងុពុទេរ

~៦~

គេជាវិស្វករសំណង់ ដែលជាអ្នកទទួលសាងសង់សំណង់បុរីកែលាសរបស់គ្រួសារគេ ។ កំលោះបងនេះ តែងតែមានទទួលម៉ៅការសាងសង់សំណង់ផ្សេងៗដែលគេដេញថ្លៃបានដែរ ។ កំលោះទាំងទ្វេហាមានចរិតលក្ខណៈខុសគ្នាស្រឡះ ដោយសិទ្ធិយ៉ាជាមនុស្សស្លូតបូត សុភាពរាបសា និងចិត្តល្អ ។ ឯគុណករជាកូនពៅ ជាមនុស្សសម្ដីអាក្រក់កំបុតកំបុយ ហ៊ាននិយាយហ៊ានធ្វើ តែក៏ជាមនុស្សចេះបែងចែកនូវអ្វីខុសអ្វីត្រូវ ហើយមានចិត្តល្អដូចជាបងប្រុសដែរ ។

រីឯស្ត្រីម្នាក់ទៀត ដែលអង្គុយទន្ទឹមលោកស្រីម៉ាណេតជាម្ចាស់វិមាននោះជាអ្នកស្រីណារត្ន ។ អ្នកស្រីណារត្នជាមិត្តរួមថ្នាក់របស់លោកស្រីម៉ាណេតកាលពីពេលពួកគាត់រៀននៅថ្នាក់ទីបញ្ចប់នៃមធ្យមសិក្សា ។ អ្នកស្រីណារត្នក៏ជាស្ត្រីមេម៉ាយមួយរូប ដែលរស់នៅខេត្តកំពត។ ស្វាមីរបស់អ្នកស្រីណារត្នគឺលោកចំណាន ។ មុនពេលដែលគាត់មិនទាន់ទទួលមរណភាព លោកចំណានជាសាស្ត្រានៃវិទ្យាល័យមួយក្នុងទីរួមខេត្ត ដែលពួកគាត់រស់នៅ ។ ក្រៅពីលោកចំណានមានមុខងារជាសាស្ត្រាចារ្យ និងអ្នកស្រីណារត្នមាននាទីជាមេផ្ទះគ្រួសារនេះ មានដីស្រែសម្រាប់ប្រវាស់ជួលឱ្យគេធ្វើ ដោយទទួលបានផលស្រូវមួយចំនួន យកមកហូបចុក និងលក់ដូរ រួមជាមួយប្រាក់បៀវត្សរ៍របស់លោកចំណានផងដែរ ។ ក្រោយពីស្វាមីទទួលអនិច្ចកម្មបាត់ទៅ ជីវភាពរបស់អ្នកស្រីណារត្នមិនសូវជាធូរធារណាស់ណាទេ គាត់នៅសល់ដីស្រែដែលអាចទទួលបានផលពីការប្រវាស់ សម្រាប់ហូបក្នុងមួយឆ្នាំៗ ដោយមិនមានសល់សម្រាប់លក់ដូរឡើយ ។ អ្នកស្រីណារត្ន និងលោកចំណាន មានបុត្រីតែម្នាក់គឺនាងពនិតា ។

ដោយសារការស្រឡាញ់បុត្រី អ្នកស្រីណារត្ន និងស្វាមីមិនដែលឱ្យកូនស្រីនឿយហត់ក្នុងការធ្វើស្រែចម្ការឡើយ គាត់តែងតែផ្ដល់ពេលវេលាឱ្យនាងរៀនសូត្រ រហូតពនិតាបានប្រឡងជាប់ចូលសិក្សានៅមហាវិទ្យាល័យពេទ្យ ។ បន្ទាប់ពីស្វាមីរបស់អ្នកស្រីណារត្នបានទទួលមរណភាពចំនួនបីឆ្នាំមក ជីវភាពអ្នកស្រីមានការលំបាកជាងមុន ធ្វើឱ្យអ្នកស្រីណារត្នមិនអាចរកថវិកា ផ្គត់ផ្គង់ឱ្យបុត្រីអាចបានសិក្សាជាបន្តនៅមហាវិទ្យាល័យពេទ្យ ដែលទាមទារមានការចំណាយច្រើន ។ ជាសំណាងល្អ នាពេលកំពុងតែត្រូវទឹកលិចដល់ច្រមុះ ស្រាប់តែលោកស្រីម៉ាណេតជាមិត្តបានមកលេងផ្ទះអ្នកស្រីណារត្ន ។ សេដ្ឋីនីរូបនេះបានដឹងពីការខ្វះខាតរបស់គ្រួសារពនិតា ។ ជាមួយសន្ដានចិត្តដ៏ល្អរបស់លោកស្រីម៉ាណេត គាត់ក៏បានសុំពនិតាធ្វើជាកូនចិញ្ចឹម ដោយឱ្យអ្នកស្រីណារត្ននាំពនិតា មករស់នៅក្នុងវិមានលោកស្រីម៉ាណេតឯភ្នំពេញ ដើម្បីម្ចាស់បុរីកែលាសអាចចិញ្ចឹមផ្គត់ផ្គង់ពនិតាឱ្យរៀនសូត្រ ដើម្បីចប់ចុងចប់ដើមនៅមហាវិទ្យាល័យពេទ្យ ទើបថ្ងៃនេះ ម្ដាយ និងកូនស្រី បានមកជួបម្ចាស់គេហដ្ឋានដ៏ស៊ីមស្ដែនេះ ។

តុរណីវ័យក្មេងដែលលុតជង្គង់ក្បែរជើងលោកស្រីម៉ាណេត គឺស្រីពនិតា នាងបានងើបមុខពីក្រាបសំពះម្ចាស់ភូមិគ្រឹះ ធ្វើឱ្យយើងអាចមើលឃើញពីសម្រស់ដ៏សោភាររបស់នួនល្អង ។ និមលមានភក្ត្រស្រស់ប៉ប្រិមដូចស្រទាប់ផ្កាកុលាបរីកនាពេលព្រឹកព្រលឹម បបូរមាត់ពណ៌ស៊ីជម្ពូស្រាល ដូចជាក្លែបក្រូចមានទំហំតូចល្មមសមខ្ទង់ច្រមុះមិនខ្ពស់មិនទាបរបស់នាង ភ្នែកស្រីខ្មៅដូចនិល

ថ្ងៃ ចិញ្ចឹមដូចដងកៅទណ្ឌ។កល្យាណស្រដី ដោយផ្គុំហត្ថាសំពះម្ចាស់វិមាន ជាមួយប្រយោគស្រទន់លាន់ពីបបូរមាត់ :

-អ្នកម៉ាក់ ! កូនសុំតំកល់គុណអ្នកម៉ាក់ស្មើភ្នំព្រះសុមេរុ ។

លោកស្រីម៉ាណេតយកដៃទាំងទ្វេត្រកងលើកខ្លួនពនិតា ដើម្បីឱ្យស្រីងើបពីការលុតជង្គង់ មកអង្គុយលើកៅអីជិតគាត់ ដោយបន្លឺវាចា :

-កូនពនិតាងើបមកអង្គុយជិតម៉ាក់មក ។ " លោកស្រីម៉ាណេតងាកមកមាតាពនិតា ស្រដីបន្ត " ... រត្នសប្បាយចិត្តចុះណា ខ្ញុំនឹងស្រឡាញ់កូនពនិតាដូចកូនខ្ញុំម្នាក់ដែរ គឺស្រឡាញ់ឱ្យស្មើនឹងកូនប្រុសខ្ញុំទាំងពីរ ។

-ខ្ញុំអរគុណណាស់ម៉ាណេត ។គឺជាបុណ្យល្អរបស់កូនពនិតាខ្ញុំមែន ដែលបណ្ដាលឱ្យចិត្តឯង មានមេត្តាស្រឡាញ់កូនខ្ញុំយ៉ាងនេះ ។ បើរំពឹងលើខ្ញុំ ខ្ញុំមិនមានលទ្ធភាពចិញ្ចឹមកូនពនិតា ឱ្យគេរៀនចប់មហាវិទ្យាល័យពេទ្យនោះទេ ។

-នឹងរាប់ថាជាគុណបុណ្យអីទៅរត្ន ឯងជាមិត្តរបស់ខ្ញុំណា ។ ខ្ញុំគិតថាកូនពនិតារបស់យើងមានជោគល្អមែន ដែលគេមានម្ដាយដល់ទៅពីរនាក់ មែនទេកូនពនិតា ?

ស្រីពនិតាលើកដៃផ្គុំសំពះម្ដាយចិញ្ចឹមជាថ្មី តាមនិស្ស័យជាក្មេងស្រីដែលមានទម្លាប់បែបគ្រួសាររៀបរយ នាងស្រដីភ្ញាប់ស្នាមញញឹម :

-ចាស ជាសំណាងល្អរបស់កូនប្រាកដណាស់អ្នកម៉ាក់ ។ កូនសុំអរព្រះគុណអ្នកម៉ាក់ម្ដងទៀត ដែលករុណាកូន ។

សន្ទឹករថយន្តមួយគ្រឿង បានបរចូលមកជិតគេហដ្ឋានលោកស្រីម៉ាណេត លាន់ស្នូរសំឡេងឮដល់ត្រចៀកស្ត្រីទាំងបីនាក់ ។ ម្ចាស់ភូមិគ្រឹះញញឹមងាកមករកមាត់ទ្វារផ្ទះ បន្លឺវាចា :

-ឮស្នូរដូចជាឡានរបស់កូនយ៉ាណារត្ន ។

-អូ៎ ! ជាកូនច្បងរបស់ឯងហ្នឹងអ្ហេះ ?

-គឺគេហ្នឹងហើយ ។

កំលោះរូបសង្ហាម្នាក់បានដើរចូលមកក្នុងផ្ទះ ជាមួយក្រសែភ្នែកសម្លឹងមកកាន់មនុស្សស្រីទាំងបីនាក់ ។ លោកស្រីម៉ាណេតងាកមកកាន់កូនប្រុសច្បងគាត់ពោលវាចា :

-កូនយ៉ាមកណេះ ។

-បាទអ្នកម៉ាក់ ។

ប្រុសរូបសង្ហាយាត្រាមករកម្តាយ ។ នេត្ររបស់គេសម្លឹងទៅកាន់ពនិតាដ៏ស្រស់ស្អាត បបូរមាត់បុរសមានស្នាមញញឹមតិចៗ ជាមួយក្រសែភ្នែករាក់ទាក់ ។ នារីឆោមយង់មិនបានងាកមកមើលអ្នកប្រុសទេ នាងកំពុងសម្លឹងអ្នកម្តាយរបស់មាណព ដែលស្រដីទៅកាន់ម្តាយនាង :

-វត្នប្រាកដជាចាំគេមិនបានទេ ព្រោះឥឡូវគេពេញកំលោះហើយ ។

-មែនហើយ កាលខ្ញុំឃើញគេលើកក្រោយបង្អស់ គេមានអាយុតែដប់ប្រាំឆ្នាំប៉ុណ្ណោះ ។ " ណារត្ននិយាយទាំងមុខញញឹម "

អ្នកស្រីម៉ាណេតសើចតិចៗ ស្រដី :

-តែពេលនេះគេមានអាយុជិតសាមសិបឆ្នាំហើយរត្ន ។

សិទ្ធិយ៉ាដើរមកកាន់តែកៀកម្តាយ ហើយភ្នែករបស់គេនៅតែសម្លឹងឥតព្រិចទៅកាន់រង្វង់មុខពនិតា ជូនជានួនល្អងងាកមកប្រទះខ្សែចក្ខុកំលោះដែលគន់ភក្ត្រនាង មុខធីតាមានភាពអៀនខ្មាសចំពោះពន្លឺភ្នែកដ៏មុតថ្លារបស់អ្នកប្រុស ស្រីល្អឱនមុខចុះ គេចពីខ្សែភ្នែកដ៏គួរឱ្យខ្លាចនេះ ។ សំឡេងអ្នកស្រីម៉ាណេតលាន់ឡើង :

-កូនយ៉ា ! កូនស្គាល់អ្នកមីងរត្នរបស់កូនទេ ?

សិទ្ធិយ៉ាលើកម្រាមហត្ថាសំពះស្រីជាភ្ញៀវ បន្លឺ :

-អ្នកមីង ខ្ញុំជម្រាបសួរ ។

-ថ្វាយព្រះណាំក្មួយយ៉ា ។

-ពនិតា !កូនស្គាល់បងទេហ្នកកូន ? " ម៉ាណេត "

-ចាស ខ្ញុំជម្រាបសួរ ។ " ពនិតាស្រដីទាំងអឹមអៀន "

នេត្រាបុរសកំពុងផ្តោតឥតដកពីភក្ត្រាស្រី លុះត្រូវនាងសំពះ និងវាចាមកកាន់គេ បុរសភ្ញាក់បន្តិចដែរ ហើយនឹកអៀនដែលខ្លួនឯងសម្លឹងមុខគេដោយភ័ន្តភាំងបែបនេះ ។ សម្រួលឥរិយាបទមួយភ្លែត នរៈស្រដី :

-បាទ ជម្រាបសួរ។ "សិទ្ធិយ៉ាងាកមកម្តាយ គេញញឹមពោលបន្ត" ... អ្នកម៉ាក់កូននឹកឃើញហើយ គឺពនិតាមែនទេ ?

-មែនហើយ ពនិតាពេលនេះគឺជាប្អូនស្រីរបស់កូនហើយ ។ នាងគឺជាកូនចិញ្ចឹមរបស់ម៉ាក់ ។ កូនត្រូវតែស្រឡាញ់ប្អូនឱ្យបានច្រើន១ណាំកូន ។

សិទ្ធិយ៉ាដាក់កាយអង្គុយកៀកម្ដាយ និយាយទាំងមុខញញឹម :

-អ្នកម៉ាក់កូនសប្បាយចិត្តណាស់ ដែលមានប្អូនស្រីចំណាប់បែបនេះ ។

-ក្មួយយ៉ា ! មីងផ្ញើប្អូនស្រីផងណា៎ បើប្អូនស្រីមានខុសឆ្គង ធ្វើមិនល្អ មិនគប្បីអ្វីនោះ ក្មួយជួយដាស់តឿនគេផងទៅ ។

-បាទអ្នកមីង ក្មួយទទួលសម្ដីអ្នកមីង តែមើលទៅនាងប្រហែលជា មិនមានអ្វីគួរឱ្យបារម្ភទេដឹងអ្នកមីង ?

-មនុស្សយើងណា៎ក្មួយ មិនមាននរណាមិនខុសនោះទេ ។

-ណ្ហើយ រត្នអើយកុំបារម្ភអីពេក ។

-ស្ដាប់ឮឯងនិយាយបែបនេះ គ្នាអរគុណឯងហើយ ។

-ហើយឯងវិញណា៎ ចាំព្រឹកស្អែកសឹមទៅស្រុកចុះ ព្រោះខ្ញុំនឹងឱ្យកូនយ៉ាជូនឯងទៅ ។

-អ៊ូ ! មិនចាំបាច់នាំលំបាកដល់ក្មួយយ៉ាទេ ។ ចិត្តថ្លើមឯងល្អយ៉ាងនេះ ខ្ញុំអស់កង្វល់ពីកូនពនិតាហើយ ហើយខ្ញុំនឹងទៅស្រុកនៅថ្ងៃនេះចុះ មិនចាំដល់ថ្ងៃស្អែកទេ ព្រោះមិនចង់ចោលផ្ទះសម្បែងនៅឯណោះ ។

-តាមតែឯងចុះ ហើយបើនឹកកូនពនិតាពេលណា ឯងក៏នឹងមកលេងនឹងនាង បានគ្រប់ពេល ព្រោះនាងជាកូនរបស់យើងទាំងពីរនាក់ណា៎ ។

ម្ដាយរបស់ពនិតាងក់ក្បាលញញឹម ដោយការកក់ក្ដៅក្នុងចិត្តចំពោះសម្ដីរបស់មិត្ត ។ បន្ទាប់មក អ្នកស្រីណារត្នក៏លាម្ចាស់ផ្ទះ ដើម្បីវិញទៅកាន់ទី

លំនៅរបស់គាត់នៅឯខេត្តកំពត ក្រោមការជូនដំណើររបស់សិទ្ធិយ៉ា ម្តាយរបស់អ្នកប្រុស ព្រមទាំងពនិតា ។

រាត្រីមកដល់ ពនិតាគេងនទៀលចុះនទៀលឡើងនៅលើពូកដ៏ប្រណិតនៃបន្ទប់ជាកម្មសិទ្ធិរបស់នាងក្នុងភូមិគ្រឹះរបស់លោកស្រីម៉ាណេត ។ វង្វង់ភក្ត្ររបស់នាងស្រពាប់ស្រពោន ធីតាបារម្ភមិនដឹងថា តើការរស់នៅរបស់នាងជាមួយត្រកូលអ្នកមានស្តុកស្តម្ភនេះ នោះរូបនាងនឹងត្រូវធ្វើឫកពាបែបណាឱ្យសមនឹងសន្តានចិត្តដ៏ល្អរបស់លោកស្រីម៉ាណេត និងកូនប្រុសច្បងនៃត្រកូលនេះ ។ និស្ស័យជាក្មេងស្រីដែលលុះដោយដំបូន្មានម្តាយ កល្យាណស្រមៃឃើញគ្រាមួយ មុនពេលដែលនាងមកដល់ទីនេះ ។

-២-

លើក្ការងឿឈើនាងនួន ក្នុងផ្ទះរបស់អ្នកស្រីណារត្ន ពនិតាគេងកើយភ្លៅម្ដាយ ស្ដាប់សម្ដីមាតាដែលបន្លឺស្រាល១មកកាន់នាង :

-ម្ដាយតូចចិត្តណាស់ មិនគួរណាម្ដាយបង្កើតកូនមកហើយ តែគ្មានលទ្ធភាពបំពេញបំណងកូនដល់ត្រើយ ។

ពនិតាចាប់ដៃម្ដាយមកក្ដោបលើទ្រូងនាង ស្រីបន្លឺ :

-អ្នកម៉ែ កូនឥតមានបន្ទោសអ្នកម៉ែទេ ហើយអ្នកម៉ែក៏មិនមានខុសអ្វីដែរ ។ កូនជាកូនដែលមានសំណាង ដែលមានអ្នកម៉ែដ៏ល្អ បានបីបាច់ចិញ្ចឹមកូន ដោយលំបាក ។ កូនស្រឡាញ់ កូនអាណិតដល់អ្នកម៉ែ ដែលអ្នកម៉ែបានប្រឹងប្រែងបីបាច់កូនកន្លងមក ។ អ្នកម៉ែ ! ជីវិតរបស់ពួកយើងដែលលំបាកបែបនេះ គឺជាវាសនាដែលកំណត់មកទៅហើយមែនទេអ្នកម៉ែ ?

-បើសិនជាលោកពុករបស់កូនរស់នៅ ពួកយើងក៏មិនលំបាកបែបនេះដែរណ៎ាកូន ... ហ៊ឺ !ម៉ែអាណិតកូនណាស់ កូន...

-តែកូនពិតជាមិនអីមែនណ៎ាអ្នកម៉ែ ។ កូនមានអ្នកម៉ែដ៏គួរឱ្យគោរពគឺជាវាសនាដ៏ល្អរបស់កូនហើយ ។

-កូនម្ដាយ ! កូនពិតជាកូនល្អរបស់ម៉ែ តែម្ដាយចង់ប្រាប់កូនថា នៅពេលដែលកូនត្រូវទៅរស់នៅផ្ទះលោកអ៊ំស្រីម៉ាណេត ម៉ែក៏មានការបារម្ភខ្លះ១ដែរ ព្រោះទោះជាម៉ែជឿជាក់លើចរិតឬកពាររបស់កូន ដែលជាកិរិយាដែល

ម៉ែតែងតែគាប់ចិត្ត តែយ៉ាងណា កូនត្រូវតែចងចាំឱ្យបានល្អជាបន្ថែមទៀត គឺគ្មានអ្វីដែលថ្លៃថ្លា ប្រសើរជាងការដែលកូនរក្សាការពារបាននូវកេរ្តិ៍ជាកូនស្រីនោះទេណាកូន ។

-អ្នកម៉ែ !ពនិតាជាកូនស្រីរបស់អ្នកម៉ែ ពនិតាជាឈាមរបស់អ្នកម៉ែ ។ អ្នកម៉ែល្អយ៉ាងណា កូនក៏យ៉ាងនោះដែរ ។

-ល្អណាស់កូនម៉ែ កូនត្រូវខំរៀន ត្រូវខំអត់ធ្មត់តស៊ូនឹងការលំបាកគ្រប់បែបយ៉ាង ។ ត្រូវទុកឧបសគ្គជាដុំថ្ម តែត្រូវទុករូបកូនជា តំណក់ទឹកដែលទន់ពិតមែន តែស្រក់យូរ គង់សឹកថ្មមិនខាន ។ នេះជាភាពទន់ភ្លន់ តែប្រកបដោយការរឹងប៉ឹង ដើម្បីយកឈ្នះគ្រប់អ្វីដែលជាឧបសគ្គ ដើម្បីសម្រេចគោលដៅចុងក្រោយ គឺការស្វែងរកចំណេះឱ្យបានណាកូនម៉ែ ។

-ចាសអ្នកម៉ែ កូននឹងត្រងត្រាប់សម្ដីអ្នកម៉ែ ។

-ម៉ែផ្ដាំមួយខទៀត ដែលជាខដ៏សំខាន់ គឺពេលកូនចូលទៅរស់ក្នុងផ្ទះគេ និងពេលដែលកូនចេញពីផ្ទះគេវិលមករស់ជាមួយម៉ែវិញ កូនត្រូវរក្សាឱ្យបាន គឺធ្វើយ៉ាងណាឱ្យម្ចាស់ផ្ទះគេនៅតែសប្បាយចិត្តនឹងរូបកូន ជាដដែលណាកូន ។

ពនិតាងើបពីគេងកើយភ្លៅម្ដាយ នាងលើកដៃសំពះ និងក្រាបក្បាលលើភ្លៅម្ដាយ ស្រីស្រដី :

-អ្វីជាបណ្ដាំរបស់អ្នកម៉ែ កូននឹងទូលនៅលើក្បាលកូនជានិច្ច ។

ក្តីស្រមៃបានបញ្ចប់ពីអារម្មណ៍ពនិតា ។ កល្យាណគេងលើពូកក្នុងបន្ទប់ផ្ទាល់ខ្លួននៃវិមានស៊ីមស្តែ ធីតានៅតែមានអាកប្បកិរិយាខ្វាយខ្វល់ ស្រីប្រែកាយចុះឡើងនៅលើពូកជាដដែល ។ អាការវិះគិតឋិតក្នុងអារម្មណ៍ មិនមានឈប់ឈរ កំពុងកើតក្នុងខួរក្បាល ... ស្រីព្រួយព្រោះមករស់ក្រោមដំបូលផ្ទះម្តាយចិញ្ចឹម នាងគួរតែធ្វើអ្វីដែលគួរនឹងធ្វើ ក្នុងនាទីជាកូនស្រីរបស់អ្នកម៉ែណារត្ន និងអ្នកម៉ាក់ម៉ាណោត ... សម្រាប់ម្តាយបង្កើត ពនិតាមិនមានអ្វីគួរឱ្យបារម្ភទេ តែសម្រាប់មាតាចិញ្ចឹម តើនាងមានអ្វីខ្លះទៅដែលត្រូវជួយដល់គាត់បាននោះ ? មួយខណៈពេលកន្លងទៅ កល្យាណមានអារម្មណ៍ដូចជាស្រេកទឹក នាងក៏ងើបពីទីគេងដើរសំដៅទៅក្រៅបន្ទប់ ។ និមលយាត្រាតម្រង់ទៅរកទូរទឹកកកដែលនៅក្នុងបន្ទប់ញ៉ាំបាយ ។ ដៃស្រីលូកយកកែវទឹកមួយ បន្ទាប់មក នាងបើកទ្វារទូរទឹកកក ដើម្បីយកដបទឹក បម្រុងនឹងចាក់ទឹកចូលកែវដែលនៅក្នុងដៃ ។ ស្រាប់តែ សំឡេងមនុស្សប្រុសម្នាក់ស្រែកសួរ ឮសូរមកពីចម្ងាយមកប៉ះត្រចៀកពនិតា :

- អ្នកណា ?

ពនិតាមិនច្បាស់ថា ម្ចាស់សំឡេងសួរទៅកាន់នរណាទេ ហើយក៏មិនដឹងថា តើម្ចាស់រូបឋិតនៅទីណាដែរ ។ ស្រីងាករកមើលម្ចាស់សំឡេង ជាមួយដំណើរដើរចេញពីបន្ទប់ញ៉ាំអាហារ សំដៅទៅកាន់ទីលាន់ស្នូរសំឡេងមនុស្ស ។ ជំហាននាំនាងមកជិតដល់បន្ទប់ទទួលភ្ញៀវ ស្រាប់តែសំឡេងមនុស្សដដែលលាន់មកជាថ្មី :

-ខ្ញុំសួរថា អ្នកណា ?

ពនិតាចោលភ្នែកទៅខាងមុខ តាមសូរសំឡេងដែលលាន់ពីក្នុងបន្ទប់ទទួលភ្ញៀវ ហើយនាងដើរចូលទៅជិតទ្វារបន្ទប់នោះ នេត្រាស្រីក្រឡេកឃើញប្រុសកំលោះម្នាក់មានមុខមាត់ស្រស់ជៀងសិទ្ធិយ៉ា មានរូបរាងខ្ពស់ស្រឡះ ជាមួយរង្វង់ភក្ត្រស្រស់សង្ហា តែពោរពេញដោយភាពម៉ឺងម៉ាត់ ។ អ្នកប្រុសគ្រងកាយដោយសម្លៀកបំពាក់ ជាខោជើងវែងពណ៌ស អាវដៃវែងពណ៌ស ដែលជាសម្លៀកបំពាក់ប្រាប់ថា គេទើបតែមកពីខាងក្រៅផ្ទះ ។ នៅដៃបុរសរូបនេះ មានកាន់កែវស្រាដែលមានស្រាប្រហែលជាពាក់កណ្ដាលកែវ ។ ឫកពារបស់អ្នកប្រុសមានសភាពជាមនុស្សក្រអើតក្រទម៌បន្តិច ប៉ុន្តែមើលទៅដូចជាមនុស្សដែលមានអំណាច ។ កំពុងតែលង់ជាមួយការតាមសង្កេតពីទឹកមុខ និងអាកប្បកិរិយារបស់នរៈ ពនិតាត្រូវភ្ញាក់ក្រញាង ដោយប្រយោគមួយឃ្លារបស់អ្នកប្រុសស្រែកមកកាន់នាង :

-អ្នកណា ?

-អ្ហឺ អ្ហឺ ...

ពនិតាស្ទោស្ទន់ ឆ្លើយមិនចេញសំឡេង ឮសូរតែ អ្ហឺ អ្ហឺ តែប៉ុណ្ណោះ ព្រោះនាងភ័ន្តភាំងចំពោះសម្រែកដ៏ខ្លាំងរបស់គេ ។ កំលោះសង្ហាងើបឈរស្រែកដោយសំឡេងក្រងូរលាយឡំភាពស្រវឹងសុរាស្រៀង១ :

-រវល់តែជាប់មាត់ត្រដឹត ឬក៏គទេ ?

កាលបើត្រូវបុរសសម្លុតហើយ សម្លុតទៀត ពនិតាដូចភ័ន្តភាំងបន្តិចដែរ ។កំពុងមីងមាំង នាងតបវាចាទាំងមើលមុខគេ ដោយសំឡេងរដាក់រដុប :

-ចាស ... ទេ នាងខ្ញុំមិនមែន...មិនមែនគទេ ។

ទទួលបានចម្លើយពីមាត់ពនិតា បុរសង្ហាពេបមាត់សម្លឹងមុខស្រីរបៀបពេបជ្រាយ គេញាក់ស្មាបែបចំអកឱ្យនាង ភ្ញាប់ប្រយោគ :

-អុំ ! មិនមែនគទេ ។ សូមណែនាំឱ្យខ្ញុំស្គាល់ផងបានឬទេ ? ព្រោះផ្ទះខ្ញុំមិនមានស្រីក្រមុំរស់នៅសោះ ។

និយាយចប់បុរសញាក់ស្មាម្តងទៀត រួចគេលើកកែវស្រាមកក្រេបមួយចិបបែបហី ទាំងប្រើខ្សែភ្នែកវិនិច្ឆ័យពីរូបរាង និងអាកប្បកិរិយានារីដែលឈរពីមុខគេ ។ ជាកាយវិការ និងខ្សែភ្នែកដែលមិនគាប្បីសោះ សម្រាប់ភាពជាបុរសថ្លៃថ្នូរគួរឱ្យគោរពនោះ ព្រោះអ្វីដែលអ្នកប្រុសកំពុងសម្តែង វាហាក់ដូចជាគេមានអាការមើលងាយពនិតាតែម្តង ។ ពនិតាវិញ កាលបើត្រូវប្រុសកំលោះម្នាក់ប្រើអាកប្បកិរិយាមើលងាយ ពេបជ្រាយរូបនាង ដោយមិនមានមូលហេតុត្រឹមត្រូវយ៉ាងនេះ កំហឹងក៏កើតពេញដើមទ្រូងនាង ជំនួសភាពភ័ន្តភាំង នាពេលមុននេះ ។ ស្រីសម្លឹងតបមកគេវិញ ក្នុងកែវភ្នែកមិនចុះញ៉ម ។ ទឹកមុខមាំរបស់ពនិតា មើលមិនព្រិចទៅចំមុខរបស់បុរស ទាំងនាងស្រដី :

-ចាស នាងខ្ញុំឈ្មោះពនិតា ។

បុរសញញឹមបែបពេបជ្រាយដូចពេលមុន គេវាចា :

-អ៊ូហូ !ពនិតា ! នេះឬពនិតាកូនស្រីអ្នកម៉ាក់ខ្ញុំ ។ ខ្ញុំទើបតែនឹកឃើញតើ គឺជានាងទេអី ។

ពនិតាគ្នាន់ក្នាញ់ចំពោះឫកពាមើលងាយមនុស្ស របស់កំលោះរូបសង្ហា យុវជនមានឈ្មោះថា គុណករ ជាកូនពៅរបស់លោកស្រីម៉ាណេត ។ ប៉ុន្តែទោះជាមិនចូលចិត្តឫកពាច្រឡើសបើសរបស់អ្នកប្រុស ក៏ពនិតាគិតថា ខ្លួននាងគឺជាអ្នកមកសុំស្នាក់អាស្រ័យម្នាក់ក្រោមដំបូលផ្ទះរបស់ម្តាយនរៈ ដូចនេះនាងចាំបាច់ត្រូវតែទប់ចិត្តដែលខឹងចំពោះអាកប្បកិរិយារបស់គេ ។ស្រីប្រឹងប្រែងទប់កំសួលចិត្តខឹង ដោយធីតាព្យាយាមស្រូបខ្យល់ដង្ហើមចូលទ្រូងវែងៗ ដើម្បីបន្ធូរកំហឹង ។ រួចនាងបែរខ្នងដើរបម្រុងត្រឡប់ទៅកាន់បន្ទប់វិញ ។ កាលបើឃើញឫកពាមិនចំណុះរបស់ពនិតា សំដែងមកលើខ្លួន គុណករខឹងដែរគេស្រែកបង្អាក់ចលនាដើររបស់នាង :

-ឈប់ !

ពនិតាឈប់ដើរភ្លាម នាងធ្វើកាយវិការហាក់ដូចជានាងជារបស់អ្វីម្យ៉ាងដែលត្រូវគេចុចឱ្យអាក់ចលនាយ៉ាងនោះ ។ តែទឹកមុខនាងកំពុងរិះគិតដើម្បីត្រៀមនូវប្រយោគតបតជាមួយបុរសឫកពាឈ្លើយនេះ ដោយនាងមិនខ្វីងាកមកមើលមុខគេឡើយ ។ នេះជាចរិតដែលពនិតាមិនចុះញ៉មបុរសដោយងាយៗ ។ មុខគុណករក្រញូវ សម្លឹងមកពនិតាពីក្រោយ ទាំងស្រដី :

-អ្នកណាអនុញ្ញាតឱ្យនាងដើរគេច ក្នុងពេលដែលខ្ញុំកំពុងនិយាយមិនទាន់ចប់ ។

ពនិតានៅតែឈរបែរខ្នងឱ្យកំលោះ នាងវាចា :

-សុំទោស នាងខ្ញុំងងុយគេង ទើបនាងខ្ញុំដើរទៅរកគេង តែនាងខ្ញុំមិនបានដើរគេចចេញពីលោកទេ ។

-ឬកឈ្លើយមែនតើ នាងនិយាយអត់ខ្ចីមើលមុខខ្ញុំ ។ ម្តាយនាងមិនបានប្រដៅនាងទេអ្វី ?

ពនិតាខឹងណាស់ កាលបើត្រូវនរះនិយាយប៉ះពាល់ដល់ម្តាយ បបូរមាត់នាងញ័រដោយការក្រេវក្រោធ នាងឆ្លើយភ្លាម ដោយវាចាមួយៗបែបច្បាស់លាស់ :

-អ្នកម៉ែខ្ញុំប្រដៅនាងខ្ញុំសព្វគ្រប់ តែនាងខ្ញុំមិនចាំ ទើបមកសុំសំណាក់រស់នៅក្នុងផ្ទះលោក ដើម្បីរៀនអក្សរបន្ថែមឱ្យចេះដឹងខ្លះ កុំឱ្យចេះធ្វើតែរឿងភ្លីភ្លើ ដោយដើររករឿងគេមិនដឹងហេតុផល ។

និយាយផ្ទៃផ្តាដាក់ឱ្យគុណាកររួចហើយ ធីតាដើរចេញវឹង ។ ត្រូវមួយផ្លែសម្តីរបស់នាងក្រមុំ គុណាករខាំមាត់សង្កៀតធ្មេញ ដៃក្តាប់កែវស្រាដែលកំពុងកាន់ លើកអុកលើតុ ទាំងភ្នែកតាមសម្លឹងនាងពីក្រោយ ដោយគ្នាន់ក្នាញ់តែមិនដឹងយកពាក្យអ្វីទៅតបតទៅកាន់នាង។

សិទ្ធិយ៉ាដើរចេញពីបន្ទប់គេងរបស់គេ មករកជណ្តើរ កំលោះវាក់អើនឹងស្រីពនិតាដែលដើរបម្រុងចូលបន្ទប់នាង ។ អ្នកប្រុសជាបង សម្លឹងពនិតាបន្តិច គេយល់ថា ពនិតាមានអាការៈចម្លែក ព្រោះនាងដើរយ៉ាងលឿន ហើយស្រីមិនទាំងមើលមុខគេផង ។ កូនច្បងរបស់លោកស្រីម៉ាណោតដើរចូលបន្ទប់

ទទួលភ្ញៀវ គេឃើញឫកពាប្អូនប្រុសឈរដោយកាយវិការទ្រេតទ្រោតរបៀបស្រវឹងបន្តិច របៀបខឹងនឹងអ្នកណាបន្តិច ។ សិទ្ធិយ៉ាជ្រួញចិញ្ចើម គេស្រដីទៅកាន់ប្អូនប្រុស :

-គុណា !

ភ្ញាក់ព្រើត គុណាកររងាកមករកបងប្រុសដោយស្វ័យប្រវត្តិ ជាមួយការផ្លាស់ទឹកមុខពីអាការៈខឹងមកជាញញឹម ភ្ជាប់ប្រយោគ ;

-បងយ៉ាមិនទាន់គេងទេអ្ហេះ ?

-នៅទេ ។

ជាមួយសម្ដីឆ្លើយតបទៅកាន់គុណាករ សិទ្ធិយ៉ាសម្លឹងប្អូនប្រុសរបៀបរាវរកចម្លើយ ។ នរៈជាប្អូនបែរមកលើកកែវស្រាមកអក ធ្វើឫកហាក់ដូចជាគ្មានរឿងអ្វីកើតឡើងពីពេលមុននេះសោះ ។ សិទ្ធិយ៉ាសួរប្អូន :

-អំបាញ់មិញ ឯងឈ្លោះជាមួយពនិតាអ្ហេះ ?

-ទេ បងយ៉ា ខ្ញុំមិនបានឈ្លោះសោះ ។ " គុណាករឆ្លើយទាំងញាក់ស្មាធ្វើឫកបែបព្រងើយ "

សិទ្ធិយ៉ាគ្រវីក្បាលរបៀបមិនជឿ ។ គុណាករមើលមកបងប្រុសគេបន្តសម្ដីយ៉ាងរហ័ស :

-ពិតណាស់បង ខ្ញុំមិនបានឈ្លោះជាមួយនាងទេ ។ ខ្ញុំគ្រាន់តែសួរនាងថា នាងជានរណាតែប៉ុណ្ណេះឯង ។

-មែនអ្ហេះ ?

-ពុទ្ធោ ! បងយ៉ា ខ្ញុំតូចចិត្តណាស់ នាងនេះមកនៅផ្ទះយើងមិនបាន មួយថ្ងៃផង អ្នកផ្ទះយើងក៏នាំគ្នាកាន់ជើងនាងដល់ថ្នាក់នេះហ្ន៎ ។

-បងមិនកាន់ជើងនាងទេ តែកូនខ្លាដូចជាឯងនៅជិតស្រីៗមិនបានទេ។ នែ ! បងហាមមុនណ៎ា ពនិតាមិនមែនជាស្រីដែលឯងអាចលលេងបានទេ ។

គុណករបើកភ្នែកក្រឡង់របៀបដូចជាភ្ញាក់ផ្អើល គេសួរទៅកាន់បង :

-ហេតុអី ?

-គេជាក្មេងស្រីល្អ ហើយសំខាន់នោះ គេជាប្អូនស្រីរបស់យើង ។

គុណករសើចកក្អឹក សម្លឹងកែវស្រោ ស្រដី :

-ប្អូនស្រីបងយ៉ា តែសម្រាប់ខ្ញុំ មិនមែន ... មិនមែន ... ប្រាកដណាស់ ហាស់ ហាស់ ។

R.U.P.P.

~៣~

ស្នូរស្បែកជើងប៊ូតាន់កុប១លើជណ្តើរដែលភ្ជាប់ជាន់ទីមួយ មកជាន់ក្រោមនៃភូមិគ្រឹះលោកស្រីម៉ាណេត ។ ស្នូរនេះ ទាញអារម្មណ៍ម្ចាស់ស្រីនៃវិមានស៊ីមស្ពៃឱ្យងាកទៅកាន់ប្រភពស្នូរ ភ្នែកអ្នកស្រីម៉ាណេតក្រឡេកឃើញកំលោះជាកូនពៅកំពុងចុះជណ្តើរមកល្មម ។ ម្ចាស់ស្រីភូមិគ្រឹះស្តុកស្តម្ភទម្លាក់ទស្សនាវដ្តីដែលកំពុងអានទៅក្បែរខ្លួន ហាមាត់បម្រុងសួរគុណករ តែនរៈញញឹមដាក់ម្តាយ ស្រដីមុនមាតាភ្លាមៈ

-អ្នកម៉ាក់ ! កូនជម្រាបសួរ ។

-ល្អហើយកូនគុណ ។ យប់មិញកូនមកដល់ផ្ទះ ពេលយប់ជ្រៅតាមទម្លាប់មែនទេកូន ?

-កូនមកដល់ផ្ទះនៅម៉ោងប្រាំបួនខ្វះដប់នាទីតើអ្នកម៉ាក់ មិនជាយប់អីទេ តែអ្នកម៉ាក់ឆាប់សម្រាន្តពេកតើ ។ " និយាយដល់ត្រង់នេះ គុណករវេភ្នែកសម្លឹងក្នុងបន្ទប់ទទួលភ្ញៀវ របៀបរកមើលនរណាម្នាក់ ទើបគេបន្តវាចា " ... គេទៅណាហើយអ្នកម៉ាក់ ?

លោកស្រីម៉ាណេតសម្លឹងមុខកូនពៅឥតព្រិច ជាទឹកមុខក្នុងការរិះគិតគាត់វាចា :

-អ្នកណាជាគេរបស់ឯង ហ្អាកកូនគុណ ?

-អ៊ី...

លោកស្រីជាម្ដាយដឹងពេកថា បើគុណករសួររបៀបអត់ឈ្មោះ គឺគេប្រាកដជាសួររកពនិតា តែគាត់ញញឹម ស្រដីបែបហី របៀបធ្វើជាមិនដឹងឬកកូនពៅ :

-បងយ៉ារបស់កូនអ្ហេះ ? កូនយ៉ាទៅធ្វើការបាត់ហើយ ។

-មិនមែនទេអ្នកម៉ាក់ គឺកូនស្រីរបស់អ្នកម៉ាក់ហ្នឹងណ៎ា ។

-អូ ! កូនពនិតាអ្ហេះ ?

-បាទ ។

-គេក៏ទៅរៀនដែរណ៎ាកូន ។ កូនបានជួបនាងហើយអ្ហេះ ?

-បាទអ្នកម៉ាក់ ។ កូនជួបគេកាលពីយប់មិញនេះ ។ គេរៀនដល់ថ្នាក់ណាដែរអ្នកម៉ាក់ ?

-គេរៀននៅមហាវិទ្យាល័យពេទ្យឆ្នាំទី៥ ។

-រៀនពេទ្យផងអ្នកម៉ាក់ ?

-កូនមិនជឿអ្ហេះ ?

-មិនគួរជឿសោះ ។ចុះនាងគិតឃើញយ៉ាងណាបានជាទៅរៀនពេទ្យ ? កូនយល់ថា ធ្វើពេទ្យម្ហ៊ែ១នៅតែក្បែរអ្នកជំងឺដែលគួរឱ្យធុញ ម្យ៉ាងក៏ស្អុយថ្នាំពេទ្យទៀតផង ។

-បើមនុស្សដទៃគិតដូចជាកូន ប្រទេសយើងប្រហែលជាគ្មានពេទ្យព្យាបាលអ្នកជំងឺទេដឹងកូន ?

មុខគុណាករក្រញូវបៀបយល់ថា ម្ដាយកាន់ជើងពនិតាជាងខ្លួនគេ ។ គេវាចា :

-អ្នកម៉ាក់ កូនមិន...

អ្នកស្រីម៉ាណោតហួសចិត្តចំពោះចរិតកូន ដែលឃ្លាក់ដូចជាតូចចិត្តចំពោះការយកចិត្តទុកដាក់របស់អ្នកស្រីទៅលើនាងពនិតា. មាតារូបនេះគ្រវីក្បាលតិចៗ ដោយស្រដី :

-បានហើយ បើកូនគិតផ្សេង ម៉ាក់មិនបានបន្ទោសកូនឯណា ។ តែកូនពនិតាណាំ ជាក្មេងស្រីចូលចិត្តអាណិតគេ ចូលចិត្តជួយគេ ហើយនាងរៀនពេទ្យអ៊ីចឹង ឃើញថាសមនឹងនិស្ស័យនាងហើយ ។

គុណាករពេបមាត់របៀបធុញទ្រាន់នឹងមុខវិជ្ជាដែលពនិតារៀន រួចគេដកដង្ហើមធំមួយឃ្វរ ដោយមិនដឹងជាគេតឹងទ្រូងចំពោះចំណូលចិត្តពនិតាដែលស្រីរៀនមុខវិជ្ជាពេទ្យ ឬគេធុញទ្រាន់ជំនួសនាងដែលមួយថ្ងៃៗនាពេលអនាគតនាងមុខជាត្រូវតែធ្វើការជាមួយមនុស្សឈឺ មិនសូវបានជួបនឹងការរីករាយក្នុងជីវិត ឬក៏ការដកដង្ហើមធំរបស់នរៈនេះ មកពីមូលហេតុអ្វីផ្សេង ក៏យើងមិនដឹងច្បាស់ដែរ ។ អ្នកម្ដាយរបស់នរៈ កាលបើមិនឮបុត្រាឆ្លើយឆ្លងវាចាអ្វីជាបន្ដមកកាន់ខ្លួន លោកស្រីក៏បែរមកលើកទស្សនាវដ្ដី យកមកអាន ។

ស្រីបម្រើមួយរូបលើកកាហ្វេពីរកែវមកជូនលោកស្រីម៉ាណេត និងកូនប្រុស ជូនជាគុណាករកំពុងអង្គុយមុខស្ពុយ ទាំងគេសម្លឹងម្ដាយ របៀបគិតអ្វីម្យ៉ាង ទទួលឃើញអ្នកបម្រើលើកកាហ្វេមកដល់ យុវជនក៏ស្រាយទឹកមុខរិះគិតដោយគេយកកាហ្វេមកក្រេប ស្របពេលសំឡេងមាតាវាចាមកកាន់គេ :

-អ៊ូ ! ពីព្រលប់ម្សិលមិញ មិត្តស្រីរបស់កូនបានទូរសព្ទមក ។ កូនគុណអត់ទៅជួបគេទេអ្ហេះ ?

-អ្នកណាគេម៉ាក់ ? ម្លិះ ឬកីរិនដា ?

ម្ដាយមុខក្រញូវ ស្រដី :

-ម៉ាក់ទៅដឹងថា ម្លិះ ឬរិនដាអ្ហេះ ?

គុណាករដាក់កែវកាហ្វេចុះ គេចាប់ដៃម្ដាយយកមកថើប មុខញញឹមវាចារបៀបលួងចិត្តមាតា ចៀសកុំឱ្យលោកស្រីជាម្ដាយខឹងគេ :

-សុំទោសអ្នកម៉ាក់ ពួកនាងរំខានអ្នកម៉ាក់មែន ។ ចាំកូនទៅរករឿងពួកគេណាំអ្នកម៉ាក់ ។

ចប់វាចា គុណាករងើបឈរភ្លែត ញញឹមទាំងញាក់ស្មាជាការលលេងជាមួយម្ដាយ ហើយដើរចេញទៅ ។ លោកស្រីម៉ាណេតហួសចិត្តនឹងអាកប្បកិរិយាកូនពៅ ដែលមាណពហាក់ដូចជាមានឫកពាបែបព្រាននារី តែកន្លងមកគុណាករមិនដែលនាំបញ្ហាស្មុគ្រស្មាញ មកឱ្យអ្នកស្រីលំបាក និងដោះស្រាយពីរឿងមិត្តស្រីទាំងនោះរបស់គេទេ ។ ម្យ៉ាងទៀតនោះ បើពេលណាដែលអ្នកស្រីសួរពីរឿងគូអនាគតសម្រាប់ជីវិតគេ គុណាករតែងតែគ្រវីក្បាលញញឹម ដោយ

ស្រដីតែពាក្យយ៉ាងខ្លីថា " កូនមិនទាន់ចង់បានប្រពន្ធទេអ្នកម៉ាក់ " ។ តែទោះជាគុណករមានមិត្តស្រីច្រើននាក់មែន យ៉ាងណាអ្នកប្រុសជាមនុស្សដែលមានការទទួលខុសត្រូវម្នាក់ ព្រោះអ្វីដែលគេធ្វើ អ្វីដែលគេចង គេតែងតែស្រាយដោយខ្លួនគេ ។ កាលបើយល់យ៉ាងនេះ អ្នកស្រីក៏មិនបានរារាំងបំណងកូនទាំងស្រុងទេ គ្រាន់តែគាត់មិនបង្ហាញនូវការគាំទ្រទង្វើកូនពៅដែរ ។

យើងបែរមកមើលកញ្ញាពនិតាម្ដងវិញ វេលាម៉ោងដប់មួយនេះ ពនិតានិងមិត្តនារីរបស់នាងម្នាក់ឈ្មោះមេត្រី កំពុងបណ្ដើរគ្នាចេញពីមហាវិទ្យាល័យពេទ្យ តម្រង់មករកផ្លូវ ដើម្បីធ្វើដំណើរទៅកាន់គេហដ្ឋាន ដ្បិតជាវេលាដែលពួកនាងត្រូវចេញពីរៀន ។ នៅពេលមកដល់ជិតចិញ្ចើមផ្លូវ មេត្រីក៏ងាកមកពនិតា ភ្ជាប់ប្រយោគ :

-គ្នាទៅយកម៉ូតូគ្នាសិនណ៎ា ចុះឯងទៅផ្ទះជាមួយគ្នាទេ ?

-គ្នាមិនរំខានឯងទេមេត្រី ឯងទៅចុះ ។

-អីចឹងគ្នាលាហើយ ។

មេត្រីដើរទៅរកកន្លែងដែលដាក់ម៉ូតូ ឯពនិតាក៏ដើរសរសៀតតាមចិញ្ចើមថ្នល់ ក្នុងបំណងសំដៅទៅកាន់គេហដ្ឋានរបស់ម្ដាយចិញ្ចឹម ។ ជារៀងរាល់ថ្ងៃ តាំងតែពីពេលនាងមករស់ក្រោមដំបូលវិមានរបស់លោកស្រីម៉ាណេតចំពោះការធ្វើដំណើរពីផ្ទះទៅកាន់សាលា ឬពីសាលាមកកាន់ផ្ទះ ពនិតាមិនដែលហ៊ានជិះម៉ូតូឌុបទេ ដោយនាងជាក្មេងស្រីដែលមានការប្រិតប្រៀងក្នុងការចាយវាយលុយ ទោះជាមាតាចិញ្ចឹមបានផ្ដល់ប្រាក់សម្រាប់ចាយប្រចាំថ្ងៃដល់នាង

ដែលប្រាក់នោះ ស្រីអាចប្រើប្រាស់វាដើម្បីចាយវាយបានលើមធ្យោបាយធ្វើដំណើរ លើថ្លៃនំចំណី លើថ្លៃទិញសៀវភៅក្ដី ជាប្រចាំថ្ងៃក្ដី តែពនិតាមិនបានចំណាយផ្ដេសផ្ដាសទេ នាងប្រើប្រាស់លុយទាំងនោះ ក្នុងករណីដែលចាំបាច់តែប៉ុណ្ណោះ ។

កំពុងតែដើរលើចិញ្ចើមថ្នល់ រថយន្ដមួយបានឈប់ក្បែរខ្លួនពនិតា ។ ជារថយន្ដរបស់សិទ្ធិយ៉ា ។ អ្នកប្រុសអើតមុខមកតាមប្រឡោះបង្អួចយានហៅពនិតាដោយសំឡេងតិចៗ :

-ប្អូនពនិតា ។

-លោកយ៉ាទេអ្ហេះ ?

-បងមកទទួល ។ ប្អូនឡើងឡានមក ។

-កុំរំខានលោកអី ខ្ញុំដើរក៏ដល់ផ្ទះដែរ ។

-ហៅបង ថាបងបានទេ ? យើងជាបងប្អូននឹងគ្នាតើ ។

មុខពនិតាអេះអុញ នាងស្រដីទាំងរដិបរដុប :

-អ្ហី... អ្ហី...បងយ៉ា កុំ...

សិទ្ធិយ៉ាបើកទ្វារឡានពីខាងក្នុងរថ ភ្ជាប់ប្រយោគមកកាន់ស្រី :

-ឡើងឡានមកប្អូន គឺអ្នកម៉ាក់ឱ្យបងមកទទួលអូនណា៎ ព្រោះគាត់ដឹងថា អូនតែងតែដើរទៅមកក្នុងការមកសាលា ។

ពនិតាធ្វើតាមសម្ដីអ្នកប្រុស នាងចូលអង្គុយក្នុងឡានទន្ទឹមសិទ្ធិយ៉ា ។ បុរសបញ្ជាយានឱ្យទៅមុខ ។ នារីងាកមកសិទ្ធិយ៉ា និមលស្រដី :

-មិនគួរឱ្យបងយ៉ាវរវល់ដោយសារខ្ញុំសោះ ។

-មិនជារវល់ ឬពិបាកអីដល់បងទេ ។ តាមផ្លូវនេះ បងក៏ទៅមកធ្វើការ តែរាល់ថ្ងៃ ។

ចប់វាចា កំលោះងាកមកសម្លឹងមុខឆោមយង់ ដោយភក្ត្រញញឹម ។ ប្រុសល្អសម្លឹងមុខនាងមិនដាក់ភ្នែក គេមិនបានមើលទៅកាន់ផ្លូវ ជាហេតុធ្វើឱ្យរថយន្តរបស់នរៈចេះតែរំកិលទៅមុខ តែស្រីស្រស់សម្លឹងទៅមុខ នាងបានឃើញភ្លើងស្តុបពណ៌ក្រហមប្រាកដមកល្មម ទើបពនិតាស្រែកតិចៗដោយការបារម្ភ :

-បងយ៉ា ! ភ្លើងស្តុបណាំបង ។

សិទ្ធិយ៉ាភ្ញាក់ព្រើត ព្រោះមុននេះគេភ័ន្តភាំងជាមួយនឹងសម្រស់របស់ស្រី ។ ជើងបុរសជាន់ហ្វ្រាំង ជាមួយវាចារដាក់រដុបលាន់ពីមាត់គេ :

-អូ៎! បងអ្ហ៎...

-នេះបងយ៉ាកំពុងគិតអីហ្នឹង ?

-បងអត់...គិត ...គិតអីទេ ។

ជាមួយវាចាខាងលើ សិទ្ធិយ៉ាក៏ងាកមកមើលស្រីជាថ្មី បុរសសម្លឹងនាងមិនដកភ្នែក ។ កល្យាណមានអារម្មណ៍ថា នាងខ្លាចខ្សែភ្នែករបស់ប្រុសកំលោះ ស្រីងាកទៅម្ខាងដើម្បីគេចពីនេត្រាដ៏មុតថ្លារបស់គេ ។ សិទ្ធិយ៉ានៅតែគយគន់ភក្ត្រស្រី ស្រាប់តែគេភ្ញាក់ព្រើតដោយមានស៊ីប្លេរថយន្តមួយលាន់មកពីខាងក្រោយយានរបស់គេ ។ នរៈប្រញាប់បញ្ជាឡានឱ្យអែបទៅម្ខាងដើម្បីឱ្យអ្នកខាងក្រោយវ៉ាទៅមុខ ប៉ុន្តែទោះជារថវិទ្យាសាស្ត្ររបស់កំលោះ

កូនច្បងរបស់លោកស្រីម៉ាណោតសសៀវមកជិតចិញ្ចើមផ្លូវក្តី ក៏ស៊ីប្លេរថយន្តខាងក្រោយនៅតែបន្លឺមិនឈប់ឈរ ។ ឆ្ងល់ណាស់ សិទ្ធិយ៉ាមើលតាមកញ្ចក់ ដើម្បីចង់ដឹងថា តើរថយន្តខាងក្រោយជារបស់នរណា ព្រោះសំឡេងស៊ីប្លេដូចជាសំឡេងស៊ីប្លរថយន្តរបស់ប្អូនប្រុសគេ ។ ពេលនោះ សិទ្ធិយ៉ាឃើញជាក់ជារថយន្តរបស់គុណាករមែន គេភ្ញាត់មាត់ :

-យី ! គុណាតើ ។

សិទ្ធិយ៉ាអែបឡានមកជិតចិញ្ចើមថ្នល់ ។ រថយន្តគុណាករក៏បរមកឈប់ពីក្រោយរថយន្តសិទ្ធិយ៉ា ។កំលោះប្អូនចេញពីយាន ដើរមករកបងប្រុស ។ ពេលប្អូនមកជិត សិទ្ធិយ៉ារវើកញ្ចក់យានជំនិះ គេពោលវាចាសួរប្អូន :

-មានការអីគុណា ?

គុណាករមិនបានឆ្លើយតបទៅបងប្រុសភ្លាមទេ គេផ្តោតនេត្រាទៅចំភក្រ្តាពនិតា ។ អ្នកប្រុសឃើញពនិតាសម្លឹងទៅទិសខាងមុខ ស្រីធ្វើឫកបែបហីហាក់មិនចាប់អារម្មណ៍ពីវត្តមានគុណាករ ។ ក្តាញ់ណាស់កំលោះកូនពៅម្ចាស់បុរីកៃលាស បញ្ចេញទឹកមុខពេបជ្រាយ បណ្តាលឱ្យវាចាមួយឃ្លារបូតពីមាត់គុណាករ :

-អត់មានការអីទេបង គ្រាន់តែចង់មើលមុខផ្កាព្រៃ តើមានក្លិន ឬក៏អត់ ?

មែន ! ប្រយោគផ្ញែផ្ការបស់គុណាករ ធ្វើឱ្យពនិតាងាកមកសម្លឹងនរៈជាមួយក្រសែភ្នែកដិតដោយកំហឹង តែនាងមិនបានស្តីអ្វីទេ ។ គុណាករញោក់មុខដាក់នាង សើចក្នុងដើមកតិចៗ ស្រដីបញ្ឈឺស្រិបន្ត :

-ខ្ញុំស្មានតែអ្នកណា...បាស់ បាស់ ... តាមពិត... គ្មានក្លិនសោះ ។ "

គុណាករងាកមកសិទ្ធិយ៉ា ស្រដីបន្ត" ... បងយ៉ាទៅណាទៀតហ្នឹង ?

សិទ្ធិយ៉ាមុខក្រញូវហួសចិត្តនឹងអាកប្បកិរិយាប្អូនប្រុស ដែលសំដែងភាពមើលងាយមកលើពនិតា ដោយមិនសមទំនងបែបនេះ ហើយលុះឮសំណួរប្អូនសួរ សិទ្ធិយ៉ាឆ្លើយទាំងកំបុតកំបុយ :

-ទៅផ្ទះ ។

គុណាករមិនបានសម្តែងអ្វីជាការបង្ហាញថា គេខឹងនឹងភាពកំបុតកំបុយរបស់បងប្រុសទេ តែគេបែរជាបញ្ចេញឫកពាសើចរបៀបដូចជាគេ បានស្តាប់រឿងកំប្លែងអ្វីម្យ៉ាង ហើយគេវាចា :

-ទៅផ្ទះ បាស់ បាស់ បងសុភាពមែន ។

សិទ្ធិយ៉ាមុខកាន់តែក្រញូវ គេតំហកតិចៗមកកាន់គុណាករ :

-ឯងគ្មានការអីទេអ្ហែះ ? បងទៅផ្ទះ ។

និយាយចប់សិទ្ធិយ៉ារវើកញ្ចក់ឡានបិទវិញ ។ គុណាករយកដៃទប់សង្កត់កញ្ចក់យានដែលមានចលនា ដើម្បីទប់មិនឱ្យបងប្រុសបិទកញ្ចក់នោះទាំងគេស្រដី :

-បងហ្នាក ! ហិតផ្កាព្រៃមានតែពណ៌ល្អស្អាត ដែលខ្វាតមកដុះតាមចិញ្ចើមថ្នល់អ៊ីចឹង តើមានក្លិនក្រអូបអីទៅបង ?

និយាយផង ភ្នែករបស់គេដៀងលួចមើលពនិតាផង ។ លុះចប់វាចាគុណាករដកដៃពីទប់កញ្ចក់ឡាន គេបញ្ចេញសំណើចតិចៗ ដើរវិលទៅរករថយន្តរបស់គេវិញធ្វើព្រងើយ ដោយមិនទាំងខ្វីរង់ចាំចម្លើយពីសិទ្ធិយ៉ាផង។ កំលោះច្បងហួសចិត្ត គេរវែកញ្ចក់ឡាន ដើម្បីបិទ ទាំងមិនស្តីអ្វី ។ បន្ទាប់មកគេបែរមកមើលមុខពនិតា គេឃើញមុខស្រីស្ងួតក្រៀមក្រំ សិទ្ធិយ៉ាបញ្ជាយានឱ្យរំកិលទៅមុខ ទាំងនរៈស្រដី :

-កុំប្រមូលយកពាក្យគុណាករមកដាក់ក្នុងចិត្តអីណាំពនិតា ។ គេនេះជាមនុស្សតែយ៉ាងនេះឯង តាំងតែពីណាពីណើមកម្ល៉េះ ។

-ចាស ខ្ញុំយល់ហើយ ។

ភ្លាមនោះ ដើម្បីបំភ្លៃបរិយាកាសកុំស្រីពនិតាមួហ្មងពេក អ្នកប្រុសព្យាយាមប្រើប្រយោគក្នុងន័យបង្វែរអ្វីដែលគុណាករបានបង្កនាពេលមុននេះ :

-អ្នកម៉ាក់និយាយប្រាប់បងថា ប្អូនរៀនពេទ្យជាការល្អណាស់ តើពេលដែលប្អូនរៀនចប់ ប្អូនគិតថា នឹងទៅធ្វើការនៅកន្លែងណា ?

-ចាស ខ្ញុំនឹងទៅធ្វើការតាមស្រុកកំណើតខ្ញុំ ព្រោះនៅទីនោះ មានបញ្ហាពិបាក ដោយមានការខ្វះខាតគ្រូពេទ្យសម្រាប់ព្យាបាលអ្នកស្រុក។ ខ្ញុំអាណិតពួកគាត់ ព្រោះពួកគាត់ភាគច្រើនជាអ្នកក្រ ម្យ៉ាងទៀតទីនោះមានអ្នកម៉ែរបស់ខ្ញុំរស់នៅផង ធ្វើឱ្យខ្ញុំបាននៅជិតគាត់។

-ប្អូនគិតថា ទៅធ្វើការនៅស្រុកកំណើតមែនអ្ហេះ ?

-បងសួរបញ្ជាក់ធ្វើអី ?

-បង អ្ហឺ...អ្ហឺ...

សិទ្ធិយ៉ាកំពុងតែមានអារម្មណ៍ថា ពេលនេះ គេលង់ស្នេហ៍ស្រឡាញ់ពនិតាយ៉ាងងប់ងល់ អ្វីដែលជាសំណួររបស់គេ ក្នុងគំនិតដែលគេគិតថា បើនាងទៅធ្វើការនៅទីណា គេអាចនឹងទៅធ្វើការនៅទីនោះតាមនាង ដោយគេមានបំណងថា ដល់ពេលនោះគឺជាពេលដែលគេអាចសារភាពពីទឹកចិត្តប្រាថ្នាសាងអនាគតរួមជាមួយនាង ។ ប៉ុន្តែនៅពេលដែលស្រីសួរចំចំណុចនេះ សិទ្ធិយ៉ាសឹងតែរកចម្លើយឆ្លើយតបទៅកាន់នាងមិនបាន ប៉ុន្តែគេក៏មិនអាចគេចមិនឆ្លើយបានដែរ ទើបគេឆ្លើយទាំងរដាក់រដុប :

-គឺជួនកាល ... បងអាចនឹងផ្លាស់ ... ទៅនៅឯខេត្តនោះជាមួយអូនក៏បានដែរហ្នឹងណា ។

ពនិតាមិនបានចាប់អារម្មណ៍ថា បុរសមានបំណងគួចមេត្រីមកលើនាងនោះឡើយ តែចម្លើយរបស់នរៈ បែរជាធ្វើឱ្យនាងគិតថា មាណពជាមនុស្សមានសន្តានចិត្តល្អ ប្រហែលជាគេទុកនាងដូចជាប្អូនស្រីម្នាក់ ដែលគេមាននាទីជួយថែរក្សា។ គិតយ៉ាងនេះ ស្រីញញឹមភ្ញាប់សម្តី :

-អរគុណណាស់បងយ៉ា ដែលបងបារម្ភ និងគិតគូរដល់ខ្ញុំយ៉ាងនេះ ។

ថ្ងៃអាទិត្យមកដល់ អ្នកស្រីម៉ាណេត និងសិទ្ធិយ៉ា បាននាំពនិតាទៅទិញសម្លៀកបំពាក់ និងគ្រឿងប្រើប្រាស់មួយចំនួនសម្រាប់នាង ។ នៅពេលមកដល់ហាងលក់សម្លៀកបំពាក់នៅក្នុងផ្សារសុរិយា សិទ្ធិយ៉ាលើកដៃចង្អុលទៅសម្លៀកបំពាក់មួយសម្រាប់ ដែលជាប្រភេទសម្លៀកបំពាក់មានតម្លៃខ្ពស់ និងជាម៉ូតទាន់សម័យទំនើប ដោយនរះភ្ញាប់ប្រយោគ :

-អ្នកម៉ាក់ ! មួយកំប្លេនេះសមនឹងអូនពនិតាណាស់ ។

-មែនហើយ ម៉ាក់ក៏ពេញចិត្តដែរ ។

ពនិតាបើកភ្នែកធំៗ ស្រដីញាប់មាត់ :

-អត់ទេ...អត់ទេ អ្នកម៉ាក់ ។ កូនមិនស្លៀកទេ សំពត់នោះខ្លីណាស់ ។

សិទ្ធិយ៉ាញញឹមហួសចិត្ត កាលបើឮស្រីជើកែកញាប់មាត់យ៉ាងនេះ ទើបងាកមកម្ខាង ចង្អុលទៅខោអាវមួយឈុតផ្សេងទៀត វាចា :

-អីចឹងយកអានេះអ្ហេះ អូនពនិតា ?

-អត់ទេ អាហ្នឹងក៏អត់យកដែរ ព្រោះពណ៌ក្រហមពេក ។

-តែបងថា សាច់អូនសអីចឹង ពាក់ពណ៌ក្រហមឆ្លុះសាច់តើ ។

-ទេ អូនមិនហ៊ានពាក់ទេ ។

នាងធ្វើមុខជូរ ងាកមកអ្នកស្រីម៉ាណេត ស្រដី :

-អ្នកម៉ាក់កូនមិនស្លៀកខោអាវពណ៌ឆើតៗទេ ព្រោះកូនមិនចូលចិត្ត ។

អ្នកស្រីញញឹម វាចា :

-បានតើកូន តាមចិត្តកូនចុះ តែម្តងនេះទុកឱ្យម៉ាក់ជាអ្នករើសឱ្យកូនវិញចុះ ។

-តែកូនថា មុននេះអ្នកម៉ាក់និងបងយ៉ាបានទិញឱ្យកូនច្រើនកំប្លេហើយតើ ដូច្នេះមិនចាំបាច់ទិញទៀតទេ ។

-តែពេលនេះ លុយបងនៅពេញហោប៉ៅនៅឡើយទេអូន ។

-ហើយវាក៏មិនច្រើនអីដែរ បើម៉ាក់ទើបតែទិញឱ្យកូនបានប្រាំប្រាំមួយកំប្លេហ្នឹង តើយកទៅស្លៀកបានប៉ុន្មានថ្ងៃទៅកូនស្រី ? តោះ!កូនយ៉ានាំប្អូនទៅផ្ទះវិញសិនទៅ ព្រោះបើតាមកូនពនិតា ប្រហែលទិញអ្វីក៏មិនបានទៀតដែរ ចាំស្អែកទុកឱ្យម៉ាក់ និងកូនយ៉ាមកទិញឱ្យប្អូនចុះ ។

ពនិតាលូកដៃមកចាប់ដៃម្តាយចិញ្ចឹមយកមកឱបនឹងទ្រូង នាងស្រដី :

-កូនអង្វរណាអ្នកម៉ាក់ កុំទិញអ្វីឱ្យកូនទៀតអី ព្រោះអ្នកម៉ាក់ និងបងយ៉ាបានទិញឱ្យកូនច្រើនមកហើយ ។

-កូនជាកូនរបស់ម៉ាក់ កូនត្រូវតែតាមម៉ាក់ ។

មុខពនិតាស្រងូត នាងស្ញប់ស្ញែងពីទឹកចិត្តករុណារបស់ម្តាយចិញ្ចឹមមកលើរូបនាង ស្រីរំភើបចំពោះសន្តានចិត្តអ្នកស្រីម៉ាណេត និងសិទ្ធិយ៉ា ដែលស្រឡាញ់ថ្នាក់ថ្នម និងផ្គត់ផ្គង់រូបនាង ។ ដោយនាងបន្លឺតែមួយម៉ាត់ :

-អ្នកម៉ាក់ !

សិទ្ធិយ៉ាញញឹមពព្រាយ ដើរមកជិតស្រី ស្រដីលេងមកកាន់នាង :

-កូនល្អកុំប្រកែកណាអូន ។ គឺម៉ាក់ធ្វើ ព្រោះម៉ាក់ស្រឡាញ់អូន ។

អ្នកស្រីម៉ាណេតញញឹម សម្លឹងមុខពួកគេទាំងពីរដែលបង្ហាញពីភាពចុះសម្រុង និងចេះស្រឡាញ់រាប់អានគ្នា ។ នៅក្នុងចិត្តអ្នកស្រី ក៏មានបំណងចង់ឱ្យពនិតាក្លាយជាគូនឹងកូនប្រុសច្បងរបស់គាត់ដែរ ប្រសិនបើពួកគេទាំងពីរមានការយល់ចិត្តថ្លើមគ្នា ។

ក្នុងពេលជាមួយគ្នានេះ បើយើងបែរមកមើលគុណាករម្តងវិញ យើងឃើញថា អ្នកកំលោះកំពុងតែគេងនៅលើគ្រែពូកដ៏ប្រណិតមួយទន់មនឹង ស្រស់ស្រីម្លិះជាកំពូលស្នេហ៍របស់គេ ។ ដៃនរៈឱបកាយម្លិះ តែភ្នែករបស់គេសម្លឹងពិដានបន្ទប់ធ្វើភ្លឹះៗ ហាក់ដូចជាខួរក្បាលស្មុគស្មាញទៅដោយបញ្ហារាប់ពាន់ជំពូក ។ ម្លិះវិញ នាងលោភក្រោយកនាសាមកថើបថ្ពាល់គុណាករ តែគុណាករនៅស្ងៀមឈឹងមិនកម្រើកសូម្បីដៃជើង ឬខ្លួនប្រាណ ។ ជាមួយអាកប្បកិរិយាធ្ងឹងៗរបស់អ្នកប្រុស ម្លិះកើតការមួហ្មងនៅក្នុងចិត្ត នាងបញ្ចេញទឹកមុខងរង៉ក់វាចាបែបម្ញិកម្ញ៉ក់ :

-ស្អប់បងគុណាណាស់ នេះបងអត់ស្រឡាញ់ម្លិះទេអ្ហេះ ?

គុណាករងើបអង្គុយ ទាញអាវមកពាក់ ស្រដីទាំងមុខមិនរីក :

-ម្លិះ!បងមិនស្រួលខ្លួនណាំថ្ងៃនេះ ។ បងទៅផ្ទះវិញហើយ ។

មុខងរង៉ក់របស់ម្លិះកាន់តែងរង៉ក់ឡើង នាងលូកដៃទាំងពីរមកស្រវាឱបកគុណាករ ទាំងផ្តេកខ្លួនមកលើកាយអ្នកប្រុស វាចាបែបមាយា :

-បងខឹងនឹងម្លិះអ្ហេះ ?

-ទេ បងអត់ទេ តែបងមិនទំនេរ ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

-អូនមិនព្រមទេអីចឹង បងឯងធ្វើបែបនេះ អូនខឹងណា៎ ។

គុណករទាញកាយនាងមកឱប ហើយគេឱនថើបនាងមួយខ្សឺត វាចាលួងលោមស្រី :

-ម្លិះ!បងមានការមែនណា៎ ។ អូនកុំខឹងនឹងបងអី ស្អែកនេះបងនឹងមកគេងជាមួយអូន បងសន្យាណា៎ ។

ជាមួយវាចា គេថើបម្លិះមួយខ្សឺតទៀត រួចគេព្រលែងដៃពីកាយនាង ម្លិះបើកភ្នែកធំៗ សួរដោយមិនអស់ចិត្ត :

-បងទៅមែនអ្ហេះ ?

ជាមួយប្រយោគនាងលូកដៃមកចាប់ដៃគេមកឱបជាប់ទ្រូង គុណករបេះដៃនាងចេញពីដៃគេ ស្រដី :

-បងទៅមែន ។

-បងគុណ ! " ម្លិះនិយាយទាំងមុខងរង៉ក់ "

-ស្អែកបងនឹងមករកអូនតើ កុំខឹងនឹងបងណា៎ បងនឹងមករកអូន ។

ពោលចប់ នរៈដើរចេញទៅ ម្លិះញញឹម បន្លឺវាចា :

-កុំភ្លេចពាក្យសន្យាណា៎បង ។

នរៈងាកមកញញឹមស្រស់ដាក់នាង ជាមួយការងក់ក្បាលជាសញ្ញាទទួលនូវពាក្យសម្ដីស្រី ។ ម្លិះក៏ញញឹមតបប្រុសស្នេហ៍របស់នាងវិញដែរ ។

នៅពេលដែលបុរសដើរមកដល់រថយន្តរបស់គេ គេចូលទៅអង្គុយនៅត្រង់កន្លែងចង្កូត ស្រាប់តែមុខរបស់គេស្រមៃឃើញពនិតា ដែលអង្គុយនៅក្នុង

រថយន្តសិទ្ធិយ៉ា ដោយស្រីបើកភ្នែកធំៗសម្លក់សម្លឹងមកកាន់គេ នាគ្រាដែលគេនិយាយដៀមដាមឱ្យនាងថា ជាផ្កាព្រៃគ្មានក្លិន ។ កាលបើនីកឃើញដល់ពនិតាគុណាករស្រែកតិចៗតែឯង :

-នាងពេទ្យឯងពូកែអេ្ហះ ? យើងចង់សាកនាងមើល នាងផ្កាដុះតាមចិញ្ចើមផ្លូវ ។

កាលបើនីកគ្នាន់ក្នាញ់ដោយភាពមិនចុះញ៉មរបស់ពនិតា កំលោះចិត្តក្តៅមួម៉ៅជាខ្លាំង គេជាន់ហ្គាររថយន្តកប់ជើង ធ្វើឱ្យសន្ទុះយានបោលទៅមុខដូចព្យុះ ។ ប៉ុន្មាននាទីក្រោយមក រថវិទ្យាសាស្ត្របាននាំកំលោះរូបសង្ហាជាបុត្រាពៅរបស់អ្នកស្រីម៉ាណោតមកដល់មុខភូមិគ្រឹះល្មម ។ គុណាករចេញពីឡាន ដើរចូលទៅក្នុងផ្ទះយ៉ាងរលះរលាំង ។ នរៈបានមកជួបពូឈួនជាអ្នកបម្រើ គេបន្លឺវាចា :

-បងយ៉ាមិនទាន់មកវិញទេអេ្ហះ ពូឈួន ?

-បាទ អ្នកប្រុសធំអញ្ជើញមកម្តងហើយ តែក៏បានចេញទៅជាមួយលោកស្រីវិញដែរ ។

-ពួកគាត់អញ្ជើញទៅណា ?

-បាទ លោកស្រី និងអ្នកប្រុសធំអញ្ជើញទៅជប់លៀងនៅផ្ទះលោកស្រីផាន់នី ។

ចិត្តកំលោះឆេវឆាវមានបំណងចង់សួររកពនិតា តើនាងនៅផ្ទះ ឬក៏ស្រីទៅជាមួយម្តាយ និងបងប្រុសរបស់គេ តែចរិតជាមនុស្សមិនចង់ចុះចាញ់

នរណា ធ្វើឱ្យគេត្រូវប្រើសំណួរមុក្រាង ដែលមិនចាំបាច់និយាយដល់ឈ្មោះពនិតា ក៏អាចធ្វើឱ្យគេដឹងថា នាងនៅទីណាដែរ ។ គិតយ៉ាងនេះ គុណាករសួរទៅកាន់ពូឈួន :

-ពួកគាត់ទៅតែពីរនាក់ទេអេ្ហះ ?

-បាទ ពួកគាត់អញ្ជើញទៅតែពីរនាក់ទេ គឺលោកប្រុសធំ និងលោកស្រីជាម្ដាយ ។

មុខគុណាករញញឹមយ៉ាងមានន័យ គេបន្លឺ :

-អ៊ីចឹងអេ្ហះ? បានហើយ ។ ពូទៅធ្វើការរបស់ពូចុះ ។

ពូឈួនដើរទៅម្ខាង កំលោះរូបសង្ហាប៉ោះជំហានធ្ងន់ៗសំដៅទៅកាន់បន្ទប់ពនិតា ។ មកដល់មុខទ្វារបន្ទប់ ប្រុសកំលោះលើកដៃគោះទ្វារជាសញ្ញាឱ្យម្ចាស់បន្ទប់បើកទ្វារ ។ សំឡេងពនិតាលាន់ពីក្នុង :

-អ្នកណា ?

គុណាករមិនខ្វីឆ្លើយ តែដៃគេនៅតែគោះទ្វារកាន់តែខ្លាំងជាងមុន ។ ឯក្នុងបន្ទប់ ស្រីពនិតាកំពុងអានសៀវភៅ ។ លុះឮសូរគោះទ្វារខ្លាំងយ៉ាងចម្លែក នាងបានដាក់សៀវភៅចុះ ជ្រួញចិញ្ចើមជាសញ្ញាឆ្ងល់ ដើរសំដៅមករកទ្វារ ។ ទ្វាររបើក ពនិតាភ្ញាក់ព្រើត ព្រោះវង្វង់ភក្ត្ររបស់គុណាករញញឹមស្រស់ សម្លឹងមកចំមុខកញ្ញា ។ ពនិតាញញោចក្នុងអារម្មណ៍ នាងហាក់ដូចជាខ្លាចខ្សែភ្នែករបស់អ្នកប្រុស នាងថយក្រោយ ដោយរុញទ្វារបិទមកវិញ ។ គុណាករស្រែកគំហកដាក់នាង :

-ហេតុអីក៏បិទទ្វារ ?

-ព្រោះខ្ញុំមិនចង់ជួបលោក ។

-តែយើងចង់និយាយជាមួយនាង ។

-តែខ្ញុំគ្មានពាក្យអ្វីត្រូវនិយាយជាមួយលោកទេ ។

និយាយចប់ ទ្វារក៏បិទវិញភ្លាម ។ គុណាករសើចយ៉ាងស្រស់ សម្លឹងទ្វារដែលបិទ រួចដើរត្រឡប់ក្រោយធ្វើវ៉ាហឺ ។ ឯពនិតាវិញ នាងឈរផ្អែកទ្វារមានអារម្មណ៍មិនយល់ពីចិត្តគុណាករ មិនដឹងថា គេមានបំណងអ្វីមកលើនាងឱ្យប្រាកដ ។ ប៉ុន្តែយ៉ាងណា នាងត្រូវតែមានការប្រយ័ត្នទាំងពាក្យសម្ដី ព្រមទាំងឫកពានៅចំពោះមុខប្រុសកំលោះម្នាក់នេះ ។

គុណាករដើរមកដល់បន្ទប់ គេប្រះដេកលើពូក គេបន្លឺតែម្នាក់ឯង :

-ស្មានតែគ្រាន់បើ ខ្លាចយើងដែរតើ ។

..........................................................................................

..........................................................................................

ព្រឹកស្អែកឡើង លោកស្រីម៉ាណេតដើរនៅចន្លោះកណ្ដាលកូនប្រុសទាំងទ្វេ ដោយដៃសិទ្ធិយ៉ាមានយូរវ៉ាលីសមួយ ហើយដៃគុណាករក៏មានយូរវ៉ាលីសមួយដែរ ។ អ្នកទាំងបីយាត្រាសំដៅមករកយានជំនិះដែលចតនៅមុខវិមាន ។ ជាមួយជំហានដើរ អ្នកស្រីម៉ាណេតស្រដីទៅកាន់គុណាករ :

-កូនគុណកុំដើរចោលផ្ទះពេកណ៎ា ព្រោះម៉ាក់និងកូនយ៉ាមិននៅផ្ទះផង

-អ្នកម៉ាក់អញ្ជើញទៅបុណ្យលោកអ៉ំណារីនៅឯបាត់ដំបងប៉ុន្មានថ្ងៃ?

-ម៉ាក់ និងកូនយ៉ាទៅតែបីថ្ងៃទេកូន ។ កូនគុណាមើលប្អូនស្រីផងណាំ ហើយកុំរករឿងប្អូនអី ។

-បាទ កុំព្រួយអីអ្នកម៉ាក់ ខ្ញុំមិនធ្វើអីកូនស្រីអ្នកម៉ាក់ទេ ។ ចុះឥឡូវនេះគេទៅណាហើយ បានជាមិនឃើញមកជូនដំណើរអ្នកម៉ាក់ និងបងប្រុស ?

-អូ៎ !គេទៅរៀនតាំងពីព្រលឹមម្ល៉េះកូន ។

-អ៊ីចឹងទេអ្ហេះអ្នកម៉ាក់ ?

ទាំងបីនាក់បានដើរមកដល់រថយន្តល្មម គុណាករលូកដៃមកបើកទ្វារយានជូនម្ដាយ ។ ក្រោយពីទុកដាក់វ៉ាលីសរួចរាល់ សិទ្ធិយ៉ាដើរចូលទៅកាន់ចង្កូត ។ យានបានចាកចេញទៅ គុណាករក៏ដើរត្រឡប់មកកាន់ភូមិគ្រឹះវិញ ។

ម៉ោងប្រាំពីរយប់ គុណាករដើរចេញពីបន្ទប់គេង សំដៅមករកបន្ទប់បរិភោគអាហារ ភ្នែកគេក្រឡេកឃើញមីងណាយជាស្រីបម្រើកំពុងរៀបចំបាយម្ហូបនៅលើតុ ។ កំលោះកូនពៅដើរមករកតុអាហារ គេលូកដៃយកស្លាបព្រាមួយ មកដួសសម្លដែលនៅលើតុ មកភ្លក់ ។ រសជាតិសម្លដល់មាត់ គុណាករលាន់ប្រយោគ :

-អីយ៉ា ថ្ងៃនេះបងណាយស្ល ឆ្ងាញ់មែន ។

មីងណាយញញឹមស្រស់ ដៀងភ្នែកមើលទៅពនិតាដែលកាន់ចានម្ហូបដើរមករកតុបាយ រួចមីងងាកមករកអ្នកប្រុស ដោយគាត់និយាយ :

-ជាស្នាដៃអ្នកនាងតើអ្នកប្រុស ។ អ្នកនាងស្លធ្ងាញ់ណាស់ ។

គុណាករធ្វើមុខដូចជាចង់ក្អួត ស្រដីឡា១ :

-អ្វី ... សម្លលេបមិនចូលទេ ធំក្លិនព្រៃៗ ស្រែៗ ។

ពនិតាលបមើលមុខអ្នកប្រុស នាងឃើញមុខគេដែលកំពុងធ្វើឫកដូចជាចង់ក្អួតរបៀបខ្ពើមសម្លដែលនាងស្ល។ ពនិតាហួសចិត្ត នាងពេបមាត់បែរមុខមកម្ខាងធ្វើហី ។ គុណាករនិយាយទៅកាន់មីងណយ ទាំងចង្អុលសម្លស្ងោរមាន់ណាំង៉ូវដែលគេទើបនឹងភ្លក់រួចនាពេលមុននេះ :

-ចេញ...ចេញ...យកសម្លចេញបងណយ ។

មីងណយមីងមាំងនឹងសម្ដីគុណាករ គាត់លបមើលមុខគេបន្តិច ហើយដៃស្រីបម្រើក៏ប្រញាប់លើកសម្លស្ងោរមាន់ណាំង៉ូវចេញពីតុ ។ ទាំងរអ៊ូតិចៗ :

-អំបាញ់មិញស្រែកថា ឆ្ងាញ់ ឥឡូវស្រាប់តែព្រៃៗ ស្រែៗស្អីចេះអ្នកប្រុសនេះ ។

-រអ៊ូអីបងណយ ? ខ្ញុំថាឱ្យយកចេញ យកចេញទៅ ហើយយកទៅចាក់ចោលផង ។ រួចបងណយឯងទៅទិញសម្លឯហាងមកឱ្យខ្ញុំមក។

មីងណយកាន់ចានដើរចេញទៅ ។ ពនិតាងាកមកមើលមុខបុរសសម្ដីអាក្រក់ នាងមិនមាត់មិនក នាងដើរបែរក្រោយ កាន់ចានម្ហូបឆាម្ទេសប្លោកហាវ៉ៃ ដើរទៅរកចង្ក្រានបាយវិញ ។ នៅពេលពនិតាមកដល់ក្នុងបន្ទប់ដាំបាយជួនជាមីងណយដើរមកជិតនាង ហើយមីងណយនិយាយមកកាន់និមល :

-ខ្ញុំដូចជាឆ្ងល់នឹងអ្នកប្រុសគុណណាស់អ្នកនាង ថ្ងៃនេះមិនដឹងជាយ៉ាងម៉េចប្រែប្រួលភ្លាមៗ មើលតែភ្លើងស្ទុប ។

ពនិតាញញឹម វាចា :

-កុំទៅឆ្ងល់អីបងណាយ មនុស្សប្រុសឫកធំតែប៉ុណ្ណឹង ។

-ខ្ញុំថាអ្នកនាងស្លួឆ្ងាញ់សឹងអី ប្រែរជាប្រើខ្ញុំឱ្យយកសម្លទៅចាក់ចោល ហើយប្រើឱ្យខ្ញុំទៅទិញសម្លនៅឯហាងទៀត ។

-ឥឡូវបងណាយធ្វើតាមខ្ញុំណាំ គឺបងណាយឯងមិនបាច់ហត់ដើរទៅទិញសម្លឯហាងផង និងយើងបានផ្ចាញ់មនុស្សឫកធំនេះផង ។

-អ្ហឹ...យើងធ្វើយ៉ាងម៉េចអ្នកនាង ?

-បងចាំខ្ញុំមួយភ្លែតចុះ ។ ខ្ញុំនឹងចាត់ចែងឱ្យបងបានផ្ចាញ់អ្នកប្រុស ។

ពនិតាងាកមកដួសសម្លការីដែលកំពុងពុះព្រិចៗនៅលើភ្លើង មកដាក់ក្នុងចានមួយ ។ បន្ទាប់មក នាងដួសម្ទេសក្រៀមដែលបុកជាស្រេច ចំនួនពីរកូនស្លាបព្រា មកច្របូកចូលក្នុងសម្លការីដែលនៅក្នុងចាន ។ កាលបើដាក់ម្ទេសបុកលាយនឹងសម្លការី ឱ្យរលាយចូលសាច់មួយហើយ នាងហុចចានសម្លមួយចាននេះ ទៅឱ្យមីងណាយ ទាំងស្រដីភ្ជាប់ស្នាមញញឹម :

-គេមិនដឹងថា យើងមានស្លការីទេបងណាយ ។ អីចឹង បងយកសម្លការីថែមម្ទេសបុកនេះ ទៅជូនមនុស្សឫកធំនេះចុះ ហើយបងជម្រាបគេថា ជាសម្លដែលបងទិញពីហាងដែលគេកុម្ម៉ង់ ។ ចាំមើលពេលគេញ៉ាំ គេលោតកញ្ឆោញចេកម្ដងបងណាយ ។

-អ្នកនាងចេះនឹកឃើញវិធីធ្វើបាបអ្នកប្រុសតើ ។

និយាយចប់មីងណាយប្រុងកាន់ចានសម្លការីដើរចេញទៅ ភ្លាមនោះពនិតាបានឃាត់មីងណាយ :

-បងកុំអាលយកសម្លនេះទៅឱ្យគេ ទុកឱ្យខ្ញុំចេញទៅមុនបងចុះ ។ រួចចាំមួយសន្ទុះសិន សឹមបងយកសម្លនេះយកទៅជូនគេ ។ គឺធ្វើបែបនេះ មិនអាចឱ្យគេសង្ស័យថា ជាសម្លមិនមែនទិញពីហាងទេ ។

-ចាសអ្នកនាង ខ្ញុំធ្វើតាមគំនិតអ្នកនាង ។

ពនិតាក៏ដើរត្រឡប់មកកាន់បន្ទប់ញុំាអាហារវិញ នាងដើរទៅបើកទូរទស្សន៍មើលធ្វើពើ ។ នៅក្បែរទូរទស្សន៍ គុណាករកំពុងឱ្យចំណីត្រីក្រឹមគេលួចដៀងភ្នែកមើលមកស្រស់ស្រី ។ ធីតាកំពុងតែតាមដានការផ្សាយរបស់ទូរទស្សន៍ ស្រាប់តែគុណាករស្រែកឱ្យនាង :

-ថ្លង់ ធុញ ។

ពនិតាមិនខ្ចីធ្វើព្វ នាងនៅតែបន្តមើលទូរទស្សន៍ធ្វើព្រងើយ ។ គុណាករដើរទៅបិទទូរទស្សន៍ ។ ធីតាមិនមាត់ នាងងើបដើរចេញពីបន្ទប់បរិភោគអាហារមកក្រៅ ។ ពេលមកដល់បន្ទប់ចង្ក្រានបាយ ពនិតាស្រដីទៅកាន់មីងណយ :

-ដល់ពេលហើយបងណយ យកសម្លបុកម្ទេសទៅជូនគេទៅ ។

-ចាស អ្នកនាង ។ " ណយឆ្លើយទាំងញញឹម "

មីងណយកាន់ចានសម្លការីលាយម្ទេសបុក ដើរទៅរកតុអាហារ នួនលួងដើរលបៗតាមក្រោយមីងណយ ។ នៅពេលដែលមីងណយយកសម្លទៅដាក់លើតុ និងស្រីបម្រើអញ្ជើញអ្នកប្រុសសម្តីអាក្រក់ចូលបរិភោគនោះ ពនិតាបានលបពួនចាំមើលអាការៈនរៈ ។ ស្រីឃើញគុណាករយកស្លាបព្រាដួសសម្លការី

មកបរិភោគ ។ ស្រាប់តែ នាងឃើញគុណករធ្វើមុខស្មេញ រួចលូកដៃមកយកកែវទឹក មកបរិភោគ ទាំងអ្នកប្រុសស្រែកទៅកាន់មីងណយ :

-ហឹរៗ ... ហឹរណាស់បងណយ ។

-ចាស ខ្ញុំមិនដឹងដែរអ្នកប្រុស ប្រហែលសម្លហាង សម្លអ្នកភ្នំពេញហឹរអីចឹងហើយ ។

-ហឹរសឹងតែញ៉ាំមិនបាន ។

គុណករញ៉ាំសម្លបណ្ដើរ ញ៉ាំទឹកបណ្ដើរ ដោយគេធ្វើមុខដូចជាសម្លពិបាកលេបណាស់ ។ ពនិតាសើចតិចៗ រួចប្រុងនឹងបែរខ្លួនដើរចេញ ។ សំណើចកល្យាណពួដល់ត្រចៀកបុរសឫកកម្ពស់មេឃ នាំឱ្យគុណករងាកមកមើលនាង គេឃើញស្រីកំពុងសើច គេក៏ស្រែក :

-នាងសើចអី ?

-ចាស សើចកញ្ជាញ់ចេកឃោតកញ្ជ្រោង ព្រោះវាចូលភ្លើងកំពុងរលាកមាត់ ។

គុណករសម្លឹងនាងដោយមុខមាំ គេដឹងក្នុងចិត្តថា នាងកំពុងចំអកឱ្យគេដែលពិបាកបរិភោគសម្លហឹរ ។ ឯស្រីពនិតាវិញ នាងនិយាយផ្ទៃផ្ទាឱ្យអ្នកប្រុសតែប៉ុន្មានម៉ាត់នេះ ធីតាក៏ដើរចូលទៅក្នុងធ្វើព្រងើយ ។ គុណករមួម៉ៅដែលនាងឡកឡឺយឱ្យគេ តែគេគ្មានលេសអ្វីនឹងនិយាយបន្ទោសនិមល គេបែរជាមកមើលមីងណយ គេឃើញគាត់ឈរស្ងៀមបែបស្លូតៗ ដែលតាមពិត

មីងណាយប្រឹងទប់សំណើចសឹងតែធ្លាយមកទៅហើយ ។បុរសជើងល្អខឹងនួននាង ពេក គេក៏ជះកំហឹងមកលើស្រីបម្រើ ដោយគេស្រែកគំហកឱ្យគាត់ :

-ចេញទៅ ។

មីងណាយបែរកាយមកម្ខាង គាត់លបសើចញ៉ឹមៗ ហើយដើរចេញទៅ តាមពនិតា ។ពេលទៅដល់បន្ទប់ផ្ទះបាយ ស្រីទាំងពីរឱបពោះសើចទល់មុខគ្នា ។

ស្អែកឡើង នាពេលព្រលឹម គុណាករបើកទ្វារបន្ទប់គេងរបស់គេ អើតមុខពីមាត់ទ្វារស្រែកឮៗ តាមនិស្ស័យជាមនុស្សមាត់ខ្លាំងៗ :

-អើបងណាយ មកណេះឱ្យលឿនឡើង ។

ពនិតាកំពុងបោសផ្ទះនៅជាន់ខាងក្រោម នាងឮសំលេងប្រកូកសឹង បែកត្រចៀករបស់គុណាករ ស្រីក៏រត់មករកគេ ។ ពេលមកដល់មុខបន្ទប់ ធីតា និយាយទៅកាន់អ្នកប្រុស :

-បងណាយមិនបាននៅផ្ទះទេ គាត់ទៅទិញគុយទាវអ្នកភ្នំពេញមកជូន លោកណា ។

-ហ៊ឺះ ។

ជាសំឡេងគ្រហឹមដើមករបស់គុណាករ ដែលខឹងនឹងពាក្យផ្ដាញ់ផ្ដាល របស់ធីតា ដែលប្រើពាក្យថា "គុយទាវអ្នកភ្នំពេញ " មកតបនឹង ពាក្យដែលគេបាននិយាយថា សម្លដែលពនិតាស្ងួមានក្លិនព្រៃ ក្លិនស្រែ។ ពនិតា មិនធ្វើពូនឹងស្នូរគ្រហឹមដើមក ឬតបវាចាអ្វីទៅកាន់គេទេ ស្រីដើរត្រឡប់ទៅ

រកជាន់ខាងក្រោមវិញ ដើម្បីធ្វើកិច្ចការបោសសម្អាតផ្ទះ ជាបន្ត។ តែគុណាករបានស្រែកហៅនាងជាថ្មី :

-នែ៎ ! នាងមកណេះ ខ្ញុំមានការប្រើ ។

ពនិតាបែរកាយងាកមកសម្លឹងគេ មុខនាងក្រញូវ ស្រីសួរអ្នកប្រុស :

-លោកមានការអី ?

-រៀបពូកឱ្យខ្ញុំបន្តិច ។

-ក្រែងចាំក្លិនព្រៃ១ណាំលោក ។

-ព្រៃមិនព្រៃ គង់នឹងដឹងទេ ។ រៀបពូកទៅ ខ្ញុំឈរមើល ។

ពនិតាដើរទៅរកគ្រែពូករបស់កំលោះមាត់អាក្រក់ ។ ស្រីម្នីម្នារៀបចំពូកខ្នល់ខ្មើយនៅលើគ្រែរបស់នរៈឱ្យមានរបៀបរៀបរយ ។ គុណាករឈរមើលសកម្មភាពនារី ក្នុងគំនិតដើម្បីចាំចាប់ផ្ទាក់ពីកំហុសនាង ។ ប៉ុន្តែកល្យាណរៀបគ្រែពូករបស់មាណពយ៉ាងស្អាត ដែលមិនអាចឱ្យបុរសមាត់អត់គម្របនេះ អាចនឹងរករឿងបន្ទោសនាងបានឡើយ ។ កាលបើធ្វើកិច្ចការរួចរាល់ ស្រីពនិតាដើរបកមករកទ្វារ បម្រុងចាកចេញទៅ ។ ភ្លាមនោះ សំឡេងកំបុតកំបុយរបស់គុណាករលាន់មក :

-ឈប់ ។

ធីតាឈប់ង៉ក់ តាមសម្ដីស្រែកឃាត់របស់កូនពៅលោកស្រីម៉ាណែត តែពនិតាមិនបានងាកភក្ត្រមកមើលមុខបុរសទេ ។ នាងឈរបែរខ្នង ធ្វើហីរបៀបចាំមើលអាការៈរបស់គេ ។ នាងបន្លឺវាចា :

-លោកមានការអីទៀត ត្រូវប្រើខ្ញុំម្ចាស់លោក ?

-ខ្ញុំមិនចេះប្រើខ្ញុំងទេ ។ "គុណាករនិយាយទាំងមុខម៉ា"

-តែត្រចៀកខ្ញុំអត់ថ្លង់ឯណា លោកបញ្ជាមកចុះ ។

- ហ៊ឺះ ! នាងប្រាកដហើយម្អេះ ថាពូកខ្ញុំស្អាតនោះ ?

-ចាស ក្បួនមនុស្សព្រៃ មានតែត្រឹមនេះ ។

-នាងត្រូវទៅរៀបពូកម្តងទៀត គឺរៀបឱ្យស្អាត ។

-ចាស លោក ។

ស្រស់ស្រីដើរមករកគ្រែជាថ្មី ឆោមឆាយចាប់ភើចកម្រាលពូក ដោះស្រោមខ្នើយកើយ ស្រោមខ្នើយឱប ទម្លាក់មកលើអិដ្ឋ ។ បន្តមក នាងដើរទៅក្រៅបន្ទប់យ៉ាងរហ័ស រកតែគុណាករឃាត់ក៏មិនទាន់ ។ មួយភ្លែតភ្លាមសោះពនិតាកាន់កន្ទេលក្រហាមមួយ ដើរចូលមកវិញ ។ នាងក្រាលកន្ទេលក្រហាមលើពូក ។ គុណាករស្រែកសួរនាង :

-នែ ! រៀបពូកម៉ូតអីហ្នឹង ?

-ម៉ូតស្អាត ។

និយាយតែប៉ុណ្ណោះ ពនិតាបែរមកត្រកងស្រោមខ្នើយ កម្រាលពូកទាំងរអ៊ូបណ្តើរ :

-របស់មិនស្អាតអស់នេះ ទាល់តែយកទៅឱ្យទឹកជំរះស្មាមកខ្វក់ ទើបបាន ហើយខ្លួនលោកក៏ធំក្លិនមិនស្អាតដែរ ល្មមទៅងូតទឹកផងទៅ ។

ចប់វាចា ស្រីដើររឹងទៅបាត់ ។ គុណាករនឹកស្មានថា ខ្លួនគេធំក្លិនមិនល្អ នរៈប្រឹងហឹតក្លិនខ្លួនសព្វកន្លែង តែច្រមុះមិនបានទទួលក្លិនញើសអ្វីបន្តិចសោះ។ គេហួសចិត្តដោយដឹងថា គេចាញ់កលស្រី ។ នរៈត្រវីក្បាលតិចៗតែឯង ។

-៤-

រថយន្តទំនើបមួយបានលូនមកឈប់ពីមុខវិមានលោកស្រីម៉ាណែត ។ ទ្វារយានរបើក លេចស្រីពនិតាចេញពីរថ ។ បុរសរូបសង្ហាវ័យប្រហែលជាងសាមសិបឆ្នាំម្នាក់ចេញពីទ្វារយានម្ខាង គេញញឹមសម្លឹងមកពនិតា ។ ពនិតាសំពះបុរសនោះ នាងបន្លឺ :

-ពនិតាសូមអរគុណលោកគ្រូ ដែលជូននាងខ្ញុំមកដល់ផ្ទះ ។

-អរគុណអីពនិតា ផ្ទះលោកគ្រូត្រូវមកតាមផ្លូវហ្នឹងដែរតើ ។

ជួនជាវេលានោះ រថយន្តរបស់គុណាករបើកមកដល់ល្មម ព្រោះកំលោះទើបតែវិលមកពីបុរីកៃលាស ដ្បិតនាពេលមុននេះ មានមនុស្សត្រូវមកទំនាក់ទំនងទិញភូមិគ្រឹះមួយក្នុងបុរីកៃលាស ដែលអ្នកកំលោះចាំបាច់ត្រូវទៅជួបអ្នកទិញ ដើម្បីបំពេញសំណុំបែបបទក្នុងការទទួលប្រាក់ និងប្រគល់ផ្ទះដល់អ្នកទិញ ។កាលបើនរៈរូបសង្ហាមកទាន់ពនិតាកំពុងឈរញញឹម និងនិយាយសាសងជាមួយមនុស្សប្រុសមិនស្គាល់មុខ គុណាករស្រាប់តែមានភក្ត្រក្រញូវ សម្លឹងស្រីមិនដកនេត្រា ។ ស្រីពនិតាល្អឯកមិនបានចាប់អារម្មណ៍ពីវត្តមានអ្នកប្រុសទេ ក្រោយពីជម្រាបលាលោកគ្រូរបស់នាង ធីតានាំកាយដើរមករកទ្វារ របងវិមានតែម្តង ។ ទ្វាររបងគេបាដ្ឋានរបើកដោយសារមីងណាយបើកជូនស្រីល្អ ។ និមលយាត្រាទៅរកផ្ទះ ដោយរលះរលាំង ។ គុណាករវិញ បុរសនៅតាមសម្លឹងធីតាពីក្រោយខ្នង ទាំងរអ៊ូតិចៗតែឯង :

-ប្រុសម្នាក់នោះ ជាអ្នកណាអីចេះ ?

ស្របវាចា អ្នកកំលោះបញ្ជាយានឱ្យរំកិលទៅរកពនិតាកំពុងដើរទៅជិតដល់ទ្វារវិមានទៅហើយ" ។ យានពន្លត់ម៉ាស៊ីន គុណករបោះជំហានធ្ងន់ៗ ដើរលឿនស្ទើរទៅរកនិមល ។ គេមកទាន់នាង នាពេលស្រីបោះជើងឈានចូលក្នុងផ្ទះ។ គុណករបន្លឺប្រយោគសួរពនិតា ដោយនិយាយអត់ឈ្មោះ :

-នរណាជូនមកផ្ទះ នាពេលមុននេះ ។

-គាត់ជាលោកគ្រូខ្ញុំ ។

-ជិះឡានតែពីរនាក់មនុស្សប្រុស វាល្អអ្ហេះ ?

-គឺមាត់មនុស្សទេដែលវែងជាងផ្លូវ ហើយមានតែមនុស្សចុនអន់ទើបនិយាយបែបអត់ពិចារណា ។

-ហ៊ឺះ ! និយាយបានពិរោះមែន។ តើជាអ្នកណាដែលនិយាយបែបពិចារណា ឬមិនពិចារណា ? ជានរណា ?

ជាមួយវាចាពោរពេញដោយកំហឹង បុរសលូកដៃមកចាប់អង្រួនស្មានាងទាំងពីរ ព្រមទាំងផ្តោតនេត្រាចំភក្ត្រស្រី ។ ពនិតាខ្លាចក្រសែភ្នែកពោរពេញដោយរស្មីកំហឹងនេះ នាងបម្រះពីដៃគេ ស្រែកតិចៗ :

-លែង ! លោកឯងឆ្កួតទេអ្ហេះ ?

គុណករទាញកាយស្រីមកផ្ទប់ទ្រូងដ៏មាំរបស់គេ គេរលាក់សំណើចយ៉ាងរណ្តំ បន្លឺវាចាស្រទន់ជាងមុន ក្បែរត្រចៀកស្រី :

-មែន ! មនុស្សប្រុសៗតែកាលណានៅជិតស្រីរូបស្អាត វាឆ្កួតអីចឹង ។

ពនិតាខឹងនឹងសម្ដីលែបខាយខុសទំនងរបស់គេ កល្យាណបម្រះទាល់តែរបូតពីការក្រសោបរបស់មាណព ព្រមទាំងស្រីយារដៃទះកំភ្លៀងគេ ទាំងស្រែក :

-មនុស្សឆ្កួត !

ធីតារត់ទៅមុខ ទឹកភ្នែកឈឺចាប់ដោយការប្រមាថពីមនុស្សប្រុស ចិត្តពាល ហួរមករហាម ។ គុណករត្រូវមួយកំភ្លៀង គេស្រឡាំងកាំងមួយភ្លែត គេឈរសម្លឹងដំណើររត់ទៅមុខរបស់នាង បន្ទាប់មកគេញញឹមស្រាល យកដៃស្ទាបថ្ពាល់ដែលស្រីទើបតែទះរួចនាពេលមុននេះ ។

ពនិតាពួនសម្ងំយំក្នុងបន្ទប់ នាងតូចចិត្តដែលគុណករហ៊ានប៉ះពាល់ប្រាណស្រី គេជាមនុស្សគួរស្អប់ គួរឱ្យខឹង គួរឱ្យខ្លាច... នាងព្យាយាមចៀសឆ្ងាយពីគេដែរ តែកំលោះគុណករព្យាយាមបង្កទំនាស់ដោយមូលហេតុមិនគួរគាប្បីជាច្រើនយ៉ាង ដើម្បីបានទាក់ពាក្យទាក់សម្ដីជាមួយនាង ។ ស្រីអាក់អន់ចិត្តចំពោះទង្វើគេដែលលូកលាន់ប្រាណនាង តែភ្លាមនោះ សម្ដីមួយឃ្លារបស់កំលោះមាត់អាក្រក់ដែលពោលថា " មែន ! មនុស្សប្រុសៗតែកាលណានៅជិតស្រីរូបស្អាត វាឆ្កួតអ៊ីចឹង ។" នាងហាក់ដូចជាយល់ថា នេះជារឿងមិនគាប្បីរបស់ខ្លួនឯង ដែលស្រីហ៊ានជិះរថយន្តជាមួយលោកគ្រូចិត្រាតែពីរនាក់ ថ្វីបើលោកគ្រូរបស់នាងជាមនុស្សសុភាពរាបសា មានភាពថ្លៃថ្នូរ មានការផ្ដល់កិត្តិយសដល់មនុស្សទូទៅ មិនថា មនុស្សនោះជាសិស្ស ឬជាគ្រូឡើយ តែយ៉ាងណាមនុស្សស្រី និងមនុស្សប្រុសជិះក្នុងរថយន្តតែពីរនាក់ ពិតជាមិន

សមរម្យសម្រាប់ភ្នែកញាតិមែន ។ ប៉ុន្តែមូលហេតុដែលនាងជិះរថយន្តលោកគ្រូមកកាន់ផ្ទះ ក៏ព្រោះតែកញ្ញាមេត្រីមិនបានមកសាលា ដោយនាងត្រូវទៅស្រុកកំណើតនៅតាមខេត្ត ទើបពេលដែលពនិតាត្រូវដើរពីសាលាមកកាន់ផ្ទះតែម្នាក់ឯង ហើយជាទម្លាប់ពនិតាមិនសូវដែលជិះម៉ូតូឌុបផង ។ នៅពេលកំពុងដើរពនិតាមានអាការៈដូចជាវិលមុខ ទើបនួននាងក៏ឈប់សម្រាកកបន្តិចនៅក្រោមដើមឈើមួយដើមនាចិញ្ចើមថ្នល់ ហើយពេលនោះលោកគ្រូចិត្រាបានបើកឡានមកដល់ក្បែរស្រី គាត់ឃើញអាការៈពនិតាមិនស្រួល គាត់ក៏ហៅនាងឱ្យជិះរថយន្តជាមួយគាត់ ព្រមទាំងគាត់បានឆៀងចូលទិញថ្នាំសម្រាប់ការព្យាបាលជំងឺខ្យល់ចាប់ យកមកព្យាបាលឱ្យស្រីផង ។ បន្ទាប់មក លោកគ្រូចិត្រាជូនធីតាមកកាន់ផ្ទះ ។ ការពិតនៅក្នុងបេះដូងលោកគ្រូកំលោះមានលាក់កំណួចចិត្តលួចគួចមេត្រីលើសិស្សក្រមុំ តែលោកគ្រូមិនបានសម្តែងអាកប្បកិរិយាអ្វីឱ្យពនិតាដឹងឡើយ គាត់គ្រាន់តែតាមលួចសង្កេត លួចសម្គាល់ស្រីជាសម្ងាត់ ហើយនៅពេលណាមួយដែលលោកគ្រូចិត្រាយល់ថា ជាវេលាដែលគាត់អាចនឹងសារភាពផ្លូវចិត្តប្រាប់ដល់ធីតា នោះគាត់នឹងបំពេញកិត្តិយសតាមប្រពៃណីជូននាង ជាមិនខាន ។ ពនិតាមិនដឹងពីបំណងសម្ងាត់របស់ចិត្រាមកលើរូបនាងទេ ។

បុត្រីអ្នកស្រីណារត្នគេងយំ គេងពិចារណា ដោយមិនចេញមករួមតុអាហារជាមួយកំលោះសម្តីអាក្រក់ ។ មីងណាយបានដើរមកទាន់ត្រឹមតែគ្រាដែលពនិតាយំរត់ចេញពីគុណករ គាត់មិនបានឃើញកំលោះឱបស្រី ឬធីតាទះ

កំភ្លៀងមាណពទេ។ប៉ុន្តែមីងណាយបានឃើញនិមលចេញពីរថយន្តលោកចិត្រា។ ដូចនេះ មីងណាយគិតថា ពនិតាប្រហែលគងពាក្យសម្តីបន្តិចបន្តួចជាមួយនរៈរូបសង្ហាតែប៉ុណ្ណោះ ។ មីងណាយយល់ថា ពនិតាមានចរិតគួរឱ្យស្រឡាញ់ ហើយគាត់ក៏យល់ថា អ្នកប្រុសពៅរបស់គាត់គ្រាន់តែជាមនុស្សមាត់អាក្រក់ តែចិត្តមិនអាក្រក់ដូចមាត់ទេ អ្នកប្រុសគ្រាន់តែឆេវឆាវបន្តិច តែកំលោះជាមនុស្សចូលចិត្តគិតគូរពីអ្នកដទៃ ចូលចិត្តជួយកអាសារគេ ចូលចិត្តឈឺឆ្អាលពីរឿងរ៉ាវមនុស្សជុំវិញខ្លួនក្នុងផ្លូវល្អ ដើម្បីជួយមនុស្សទាំងនោះ ។ ដូចនេះ មីងណាយក៏ដួសម្ហូបយកទៅឱ្យស្រីពនិតាដល់បន្ទប់គេង ដើម្បីដើរតួជាអ្នកផ្សះផ្សាទំនាស់ពួកគេ តាមតែមីងអាចធ្វើទៅបាន ព្រោះអ្នកទាំងពីរសុទ្ធតែជាមនុស្សដែលមីងណាយស្រឡាញ់ និងគោរព។ ពេលដាក់ម្ហូបចុះលើកូនតុក្បែរបង្អួចក្នុងបន្ទប់គេងរបស់ពនិតា មីងណាយស្រដីទៅកាន់ពនិតា :

-អ្នកនាងពិសាបាយណា៎ ។

-អរគុណបងណាយ តែខ្ញុំមិនឃ្លានទេ ។

-អ្នកនាង បងចង់ជម្រាបថា អ្នកប្រុសតូចជាមនុស្សចិត្តល្អទេ គាត់ចូលចិត្តបារម្ភ ចូលចិត្តគិតគូរពីអ្នកដទៃ តែគាត់ជាមនុស្សនិយាយត្រង់ ទើបយើងស្តាប់ទៅ ដូចជាមិនពិរោះណា៎ តែយ៉ាងណាបងចង់ឱ្យអ្នកនាងកុំខឹងជាមួយអ្នកប្រុសតូចអី ។

-ខ្ញុំមិនអាចមិនខឹងគេបានទេបងណាយ គេធ្វើអី ដោយមិនខ្វល់ពីអារម្មណ៍អ្នកដទៃសោះ ។

-ចាស អ្នកប្រុសជាមនុស្សចិត្តក្តៅមែន តែជាមួយអ្នកនាង បងយល់ថា អ្នកប្រុសបានដាក់ចិត្តដាក់ខ្លួន ដោយបង្អន់ចរិតឬកធំជាច្រើនហើយ ព្រោះយ៉ាងណាអ្នកនាងធ្លាប់បានធ្វើបាបគាត់ដែរណា៎ គឺរឿងសម្លុការីលាយម្ទេសបុកនោះអី ។

-រឿងសម្លុការីជារឿងតូចតាចទេបងណាយ តែមានរឿងខ្លះ គឺគាត់ធ្វើអ្វីចម្លែកៗពេក ខ្ញុំពិបាកនឹងអត់ឱនឱ្យគាត់ណាស់បងណាយ ។

-ចាស អ្នកប្រុសធ្វើអីបែបចម្លែកៗជាមួយអ្នកនាងមែន តែបងនៅតែយល់ថា អ្នកប្រុសពៅមិនមានបំណងអាក្រក់ជាមួយអ្នកនាងទេ ... អ្វីដែលគាត់ធ្វើមកលើអ្នកនាង គឺគាត់ដូចជា ... " មីងណាយចង់និយាយថា គុណករមានចិត្តស្រឡាញ់នាង តែគាត់មិនហ៊ាននិយាយពីការយល់ឃើញរបស់គាត់ ទើបគាត់បង្វែរសម្តីទៅបញ្ហាផ្សេងទៅវិញ " ...តែអ្នកនាងមិនគួរណា ខឹងជាមួយអ្នកប្រុស ហើយមកធ្វើបាបខ្លួនឯងដោយបង្អត់បាយយ៉ាងនេះទេ ។

ពនិតានឹកថា មីងណាយនិយាយត្រូវម្យ៉ាងដែរ នាងមិនគួរចុះចាញ់មនុស្សប្រុសមាត់ដាចដែលធ្វើផ្តេសផ្តាសមកលើនាងទេ ហេតុផលម្យ៉ាងទៀតនោះ ហេតុអីគុណករធ្វើបាបទឹកចិត្តនាងបែបនេះ នាងបែរជាបន្ថែមការធ្វើបាបខ្លួនឯង ដោយបង្អត់បាយទៀត ។ មិនត្រូវបណ្តោយខ្លួនឱ្យអត់អាហារដែលអាចនឹងមានជំងឺ ហើយប្រការដែលនាងឈឺអាចជាមូលហេតុនាំឱ្យម្តាយដែលនៅឯស្រុក គាត់នឹងមានការបារម្ភមកលើនាងឡើយ ។ គិតយ៉ាងនេះនាងវាចាទៅកាន់មីងណាយ :

-អរគុណបងណាយដែលជាស់តឿនខ្ញុំ ។

..................................................................................................

..................................................................................................

នៅផ្ទះលោកស្រីណារីវិញ យើងឃើញនៅតុមួយ មានសិទ្ធិយ៉ា ម្ដាយរបស់គេ លោកស្រីណារី និងមេត្រីកំពុងអង្គុយបរិភោគអាហារនៅតុមួយ។ លោកស្រីណារីស្រដីទៅកាន់លោកស្រីម៉ាណេត :

-នេះជាក្មួយស្រីតែម្នាក់របស់ខ្ញុំ គេឈ្មោះមេត្រី ជាក្មេងកំព្រាម្ដាយឪពុកតាំងតែពីអាយុដប់ឆ្នាំមកម្ល៉េះណ៎ាម៉ាណេត ។

-អ៊ូ ! ក្មួយស្រីស្អាតបាតណាស់តើ តែណារីហ្អា ហេតុអីពីមុនមកខ្ញុំមិនដែលឃើញនាងរស់ជាមួយឯង ?

-ពីមុន ក្មួយមេត្រីរស់ជាមួយបងស្រីខ្ញុំនៅភ្នំពេញ ដើម្បីរៀនសូត្រ តែក្រោយពេលគ្រួសារបងស្រីខ្ញុំទៅរស់នៅបរទេស ទើបមេត្រីត្រូវទទួលការឧបត្ថម្ភពីខ្ញុំវិញណ៎ា ។

-អ៊ូ ! អ៊ីចឹងទេអី ។

សិទ្ធិយ៉ាវិញ គេទទួលស្គាល់ថា មេត្រីជាស្រីស្រស់ស្អាតមួយរូបគួរឱ្យគយគន់ ភក្ត្រនាងញញឹមពពព្រាយ កែវភ្នែកមុតថ្លា បបូរមាត់សមនឹងច្រមុះនេត្រាខ្មៅភ្លឺដូចនិលថ្មៃ ចិញ្ចើមកោងសមនឹងត្របកភ្នែក ... ជាសម្រស់ស្រស់ស្រទន់បែបទន់ភ្លន់ ។តែយ៉ាងណាបេះដូងកំលោះត្រូវបាន សម្រស់ពនិតាផ្ដក់

ជាប់ទៅហើយ គេមិនមានសល់ចន្លោះប្រហោងណា ដែលអាចទទួលស្រីផ្សេងឡើយ ។ ជាមួយស្នាមញញឹម បុរសស្រដីសួរមេត្រីជាកិច្ចគួរសម :

-អត់ទោស អ្នកនាងនៅរៀន ឬក៏ធ្វើការហើយ ?

-ចាស ខ្ញុំនៅរៀនទេលោក ។ " នាងឆ្លើយទាំងញញឹម " ចុះលោកធ្វើការអីដែរ ?

-បាទ ជួយធ្វើការក្នុងបុរីកែលាសរបស់អ្នកម៉ាក់ ។

-គេជាអ្នកគូសប្លង់ និងមើលការខុសត្រូវសំណង់របស់មីងទាំងអស់ណាក្មួយស្រី ។

-អ្ហូ ! អីចឹងគាត់ជាវិស្វករសំណង់មែនទេអ្នកមីង ?

-បាទ គឺបែបនោះទេដឹងអ្នកនាង ? " សិទ្ធិយ៉ាឆ្លើយទាំងញឹមៗ បែបរាក់ទាក់ "

ពួកគេបន្តការជជែកដោយភាពស្និទ្ធស្នាល ។ វេលាយប់នេះ នៅក្នុងបន្ទប់លោកស្រីណារី មេត្រីអង្គុយជិតម្ដាយមីងដែលកំពុងឱ្យស្រីបម្រើម្នាក់គក់ច្របាច់ជូនគាត់ ដោយមេត្រីបន្លឺវាចា :

-អ្នកមីង ! ស្អែកនេះ ក្មួយសុំទៅភ្នំពេញវិញហើយ ព្រោះត្រូវប្រឡងមួយមុខវិជ្ជាណាអ្នកមីង ។

-អីចឹងក្មួយមិនទៅដល់ចប់បុណ្យនេះទេអី ?

-ចាស ក្មួយសុំទោស ក្មួយនៅមិនបានទេអ្នកមីង ។

-បើសំខាន់យ៉ាងនេះ ចាំមីងឱ្យតាកែមបើកឡានជូនក្មួយទៅភ្នំពេញពីម៉ោងបួនទាបភ្លឺណា ។

-ចាស អរគុណអ្នកមីង ។

យើងបែរមកតាមដានពនិតាម្ដង តើវាំងនាង និងកំលោះមាត់ដាច អាចមានកើតប្រតិកម្មអ្វីជារឿងទំនាស់នឹងគ្នាទៀតដែរទេ ? អូ ! ពិតជាដូចការស្មានរបស់យើងមែន មើលចុះ! គុណករកំពុងឈរជ្រែងនៅមាត់ទ្វារបន្ទប់ពនិតា ។ នរៈបើកភ្នែកធំៗ សម្លឹងភក្ត្រនួននាង ឯស្រីស្រស់ងាកមុខទៅម្ខាងសួរដោយអាការមួម៉ៅមករកបុរស :

-មានការអីលោក ?

-មានការ ។

គេនិយាយទាំងផ្ដោតនេត្រាចំមុខស្រី ជូនជាពនិតាងាកមុខមកមើលគេព្រោះនាងមិនពេញចិត្តសម្ដីកំបុតរបស់អ្នកប្រុស ... ហើយក្រសែភ្នែកមុតថ្លារាយដោយមន្តស្នេហ៍របស់បុរសបានចាក់ទម្លុះបេះដូងនាង ធ្វើឱ្យស្រីត្រជាក់អស់ចុងដៃចុងជើង បបូរមាត់នាងញ័រទទ្រើក ... នាងខ្លាច នាងមិនស្រួលក្នុងចិត្តស្រងីញ័រៗ :

-អ្វី...អ្វី...

-មុខខ្ញុំវាយ៉ាងម៉េច វាដូចជាខ្លាឬ បានជាឃើញភ្លាមញ័រទៅហើយ ?

-ទេ...ចាស....លោកអញ្ជើញទៅក្រៅទៅលោក ទីនេះមិនសមនឹងនិយាយគ្នាទេ ។

-តែខ្ញុំពេញចិត្តទីនេះ ដើម្បីនិយាយគ្នា ។

និយាយចប់ គេបោះជំហានដើរចូលទៅក្នុងបន្ទប់ស្រី ។ពនិតាភ័យកាន់តែខ្លាំង នាងខិតមករកទ្វារ ដោយពោលវាចា :

-អីចឹង ខ្ញុំនឹងចេញទៅក្រៅវិញ ។

-មិនឱ្យនាងចេញទៅណាទេ ។

ចប់វាចា គុណាករស្ទុះមកកញ្ឆក់ដៃស្រីយ៉ាងខ្លាំង ទាល់តែពនិតាទ្រេតខ្លួនមកលើកាយមាណពទាំងជំហរ ។ នាងភ័យណាស់ ស្រីស្រដីទាំងញ័រៗ :

-លោក ! ហេតុអី...លោកចង់ធ្វើអីខ្ញុំ ?

-នាងឯងល្ងង់មែន ឬក្លែងធ្វើល្ងង់ នាងគួរតែដឹងថា តើខ្ញុំត្រូវការអ្វី ?

ស្ទើរមិនទាន់ចប់ប្រយោគស្រួលបួលផង កំលោះចិត្តក្តៅចាប់ស្រីឱបយ៉ាងស្អិត គេប្រើច្រមុះគួរសមថ្ពាល់នាងពាសពេញផ្ទៃភក្ត្រាចរណៃ ។ ពនិតាជ្រួលច្រាលដោយការភ័យខ្លាច នាងបម្រះផង នាងស្រែកផង :

-លែង...ខ្ញុំស្រែក....លែង....លែងខ្ញុំទៅ មនុស្សអាក្រក់ ។

-ស្រែកទៅ អ្នកម៉ែមិននៅ បងយ៉ាមិននៅ ហើយបងណយក៏គេងលក់បាត់ហើយ ឯពូឈួនក៏ដេកនៅឯបន្ទប់ក្បែររោងឡាន តើនឹងមានអ្នកណាមកជួយនាងបាន ?

ទឹកភ្នែកហូររហាមកាត់ផែនថ្ពាល់ទាំងគូរបស់ស្រី ពនិតាខ្លាចគុណាករនឹងធ្វើផ្តេសផ្តាសមកលើរូបនាង ព្រោះនាងដឹងថា នាងមិនអាចយកឈ្នះកម្លាំងបាយជាមួយបុរសម្នាក់នេះទេ ទើបធីតាស្រដីអង្វរករគេ :

-លោក...ហេតុអីលោកធ្វើយ៉ាងនេះ លែង... លែងខ្ញុំ ។

បានឮវាចាទន់ភ្លន់របស់ស្រី គុណាករបន្ធូរដៃពីការឱបរឹតប្រាណស្រីបន្តិច តែគេមិនបានព្រលែងកាយនាងតែម្តងទេ ។ កំលោះសម្លឹងមុខនាងដោយក្រសែភ្នែកមុតថ្លារបៀបរាវរកចម្លើយអ្វីពីមុខនាង ជាខ្សែភ្នែកមានភាពស្រោបដោយអំណាចអ្វីម្យ៉ាង ។ ពនិតាខ្វាចមែនទែន នាងព្យាយាមរើយ៉ាងខ្លាំង តែមិនរួចពីដង្កាប់ដៃរឹងមាំរបស់គេទេ ។ គុណាករសើចយ៉ាងរណ្តំវាចាបែបចំអកឱ្យស្រីដែលកំពុងភ័យដូចកូនសត្វព្រាត់ពីសំបុក :

-ក្រែងនាងពូកែអេ្ហះ?នាងធ្វើឱ្យខ្ញុំក្តៅញ់ណាស់...នាងរើទៅ ព្រោះនាងធ្លាប់គ្រាន់នោះអី ហើយមនុស្សក្នុងផ្ទះនេះ ទោះអ្នកណាក៏កាន់ជើងនាងដែរ ។ ពេលនេះតើមាននរណាមកជួយនាងបាន ។

ជាមួយការបញ្ចប់ពាក្យសម្តី គុណាករស្រវាឱប ទាញនាងមករកគ្រែរួចគេផ្តួលកាយស្រីទៅលើពូកសក្បុស ។ បុរសចិត្តក្តៅប្រើច្រមុះបបោសអង្អែលសព្វផ្ទៃមុខស្រី ជាមួយចលនាដៃគេដែលស្ទាបសព្វប្រាណធីតា ។ បបូរមាត់គេទម្លាក់មកផ្ចិតលើបបូរមាត់ស្រី ។ ពនិតាលែងមានអ្វីការពារខ្លួនទៀតហើយ ។ នាងល្វើយ នាងលែងមានកម្លាំងបម្រះ នាងបណ្តោយតាមចំណង់ចិត្តបុរសព្រោះដៃដ៏រឹងមាំរបស់គុណាករសង្កត់នាងមិនឱ្យរើរួច ។

ទីបំផុត អ្វីៗជាតម្លៃស្រីក្រមុំរបស់ពនិតាបានរុះរោយកេសរដោយដៃកន្លង់គុណាករ ។ តួចតន់គេងផ្កាប់មុខយំលើពូក ។ នាងឈឺចាប់ នាងតូចចិត្ត ... នាងសោកស្តាយ មិនគួររាងកាយត្រូវប្រឡាក់មន្ទិលដោយដៃប្រុសព្រានស្រេក

ឃ្លានតណ្ហា ... គុណាករងើបពីគ្រែ គេទាញអាវមកពាក់ គេសម្លឹងខ្នងស្រីដែលគេងផ្កាប់មុខយំ គេធ្វើមុខមឹងម៉ាំង គេមានក្ដីងឿងឆ្ងល់ ហេតុអីពនិតាយំខ្លាំងម្ល៉េះ ? នាងមិនពេញចិត្តរូបគេជាបុរសសង្ហាទេអី ?ព្រោះជាធម្មតា មានស្រី១ជាច្រើននាក់តែងតែប្រាថ្នាចង់បានឱ្យគេថ្នាក់ថ្នម ចង់បានរូបគេធ្វើជាសង្សាររបស់នាង១ ។ ចុះពនិតាម្នាក់នេះ អីក៏ចម្លែកម្ល៉េះ បើពេលនេះ នាងនិងគេបានស្និទ្ធស្នាលដល់ថ្នាក់បានផ្ដេកផ្ដិតរូមកាយទៅហើយ ហេតុអីក៏នាងយំមិនឈប់ ? ហើយថែមទាំងនាងមិនមើលមុខគេ នាងហាក់ដូចជាមិនត្រូវការរូបគេសោះ។ គិតយ៉ាងនេះ គុណាករស្រាប់តែប្រែទឹកមុខពីមឹងម៉ាំង មកជាទឹកមុខរិះគិត រួចប្រយោគគ្រោតគ្រាតដូចក្រួសលីងស្រោចមកប៉ះសោតាស្រីពីមាត់បុរស :

-រឿងអីចឹងកើតឡើងរវាងពួកយើង នាងមិនភ្លើទៅជម្រាបប្រាប់អ្នកម៉ាក់ទេមែនទេ ? ឬក៏ចង់ទៅយំប្ដឹងអ្នកម៉ាក់ ក៏តាមចិត្តចុះ ខ្ញុំមិនអង្វរទេ ។

ពនិតាខឹងណាស់ ប្រុសម្នាក់នេះបានធ្វើកំហុសធំមួយមកលើនាងហើយមិនបានពោលពាក្យសុំទោសសូម្បីមួយម៉ាត់ ថែមទាំងនិយាយបញ្ឆោះបន្សោកដល់នាងទៀត ។ ធីតាឈឺផ្សាក្នុងចិត្ត ក្ដៅរោលរាលពេញទ្រូង រួមដោយកំហឹងច្រាលមកផង និមលចាប់លើកសៀវភៅដែលនៅលើក្បាលគ្រែ គប់មកលើគេ យ៉ាងពេញទំហឹង ជាមួយសម្ដីគំហក :

-ចេញទៅ ចេញទៅ ។

អារុំចជាសៀវភៅស្រោចមកលើប្រាណកំលោះរូបសង្ហា ដោយគេមិនបានដឹងជាមុនបែបនេះ បណ្តាលឱ្យនរៈស្ទុះស្ទាគេចផង និងត្រូវចាប់សៀវភៅទាំងឡាយផង ដែលសៀវភៅទាំងនោះហើរច្រវាត់ច្រវែងមករកប្រាណគេ ។ ចុងក្រោយ សៀវភៅដែលស្រីគប់មក នៅសល់តែមួយក្បាលនេះ ទើបគេចាប់បានសៀវភៅចុងក្រោយ ។ ភ្នែកគេបានក្រឡេកឃើញមានសរសេរអក្សរសរសេរធំៗលើក្របដែលមានន័យ " ស្រឡាញ់ និងអាណិត តើសំខាន់យ៉ាងណា" ។ គេមិនយល់ថា ហេតុអីនាងសរសេរបែបនេះ គេចោលនេត្រាមកសម្លឹងស្រីជាថ្មី គេឃើញពនិតាងាករកមើលរបស់អ្វីសម្រាប់គប់មកគេ ព្រោះសៀវភៅដែលនាងបានប្រើសម្រាប់គប់ បានអស់ទៅហើយ ។ ធីតារករបស់សម្រាប់គប់មិនបាន ស្រីងាកមករកបុរស នាងស្រែកគំហកទាំងទឹកភ្នែក សស្រាក់ :

-មនុស្សអាក្រក់ចេញទៅ ចេញទៅ យើងស្អប់ណាស់ ។

គុណាករឈរឆ្ងឹងមួយខណៈខ្លី គេមើលនាង នាងយំខ្លាំងណាស់ នាងយកដៃទាំងពីរខ្ទប់មុខយំ ខ្លួនប្រាណកល្យាណទាំងមូលរង្កើរញ្ជួយ... នាងលែងដេញគេហើយ នាងគិតតែពីយំ យំមិនឈប់ ... គុណាករដូចជាមានចិត្តអាណិតនាង គេមានភក្ត្រស្រងូតស្រងាត់ ហើយគេដាក់សៀវភៅក្នុងដៃទៅលើតុ ។ បន្ទាប់មកគេដើរចេញទៅរកទ្វារ ។ ប្រាណមាណពរំកិលជិតមកដល់ទ្វារ គេលបងាកមកមើលស្រីម្តងទៀត គេឃើញនាងនៅតែយំគគ្រូកកាយស្រីនៅតែញ័ររញ្ជួយ ... បេះដូងគុណាករស្រាប់តែហាក់ដូចជាប្រហោងធ្លុងគេឱនមុខដើរចេញទៅក្រៅបន្ទប់យ៉ាងលឿន ដោយមិននិយាយអ្វីឡើយ ។

កល្យាណយំគគ្រូក សន្ធឹកវាយោបក់ផាត់ស្បៃវាំងននទាមាត់បង្អួចរិច១ ដូចជាកំពុងចំអកឱ្យស្រី កង្ហាររលើពិដានក៏វិលមិនឈប់ ដូចចិត្តស្រីដែលវិលវល់រកទីដៅមិនឃើញ តើនាងត្រូវធ្វើយ៉ាងណា ដើម្បីតបជាមួយទង្វើប្រុសសាមាន្យ... ពនិតាគិតមិនឃើញទេ ... មានតែទឹកភ្នែកជាចម្លើយ... សំឡេងបេះដូងឈឺចាប់រសាត់ចេញជាបទភ្លេងសោកសៅមកកំដរចិត្តប្រេះស្រាំប្រៀបដូចជាសំនៀងចម្រៀងមួយបទដ៏ជូរចត់ :

-ទឹទុយស្រែកយំខ្លែងស្រាក់ថ្ងូចថ្ងូរ
-ទឹកភ្នែកខ្ញុំហូរចុកណែនឱរា
-កូនម្រឹគតូចមួយនៅក្បែរមាត់ខ្លា
-ត្របាក់ប្រហារឈ្លីឥតប្រណី
-ស្តាយក្លិនស្តាយខ្លួនព្រានមកប្រឡាក់
-បក្សីភ្ញាត់ធ្លាក់បង្គងដល់ដី
-ផ្កាអើយផ្កាព្រៃដាច់ទងឥតន័យ
-ឱ !ឱ តម្លៃស្រីដូចលាមក
-យប់យន់ខ្ញុំយំថ្ងូរប្រាប់លោកិយ
-គ្រាប់ពេជ្រចរណៃជ្រុះចូលជ្រាំភក់
-ខ្លួនមនុស្សចិត្តខ្លាប្រាថ្នាតែភ្លក់
-កន្លង់គម្រក់ញក់ញីបុប្ផា
-ទឹទុយខ្លែងស្រាក់ជួយធ្វើសាក្សី

-សូមពេលរាត្រីជួយចាំកត់ត្រា

-រយពាន់សំណើចបិសាចតណ្ហា

-គង់ស្គាល់ខ្លោចផ្សាមុិនសែនទឹកភ្នែក ។

-៥-

ម៉ោងបួនទាបភ្លឺ នៅមុខវិមានរបស់លោកស្រីណារី តាកែមកំពុងបញ្ជូនរថយន្តចេញពីរោងដាក់យាន ដើម្បីចាំជូនដំណើរស្រស់ស្រីមេត្រី ក្នុងការធ្វើដំណើរទៅភ្នំពេញ ។ បន្ទាប់មកមានស្រីបម្រើម្នាក់យួរវ៉ាលីសរបស់កញ្ញាមេត្រីយកមកដាក់ក្នុងរថវិទ្យាសាស្ត្រ ។ ឯក្នុងភូមិគ្រឹះលោកស្រីណារីវិញ កំលោះសិទ្ធិយ៉ាដើរចេញពីបន្ទប់គេង បំណងចេញទៅហាត់ប្រាណឯមុខផ្ទះរបស់លោកស្រីណារី ។ ពេលគេដើរមកដល់បន្ទប់មួយ ទ្វារបន្ទប់នោះស្រាប់តែរបើកមក រួចលេចរង្វង់ភក្ត្រមេត្រីយាត្រាចេញមកល្មម ហើយដោយសារតែសិទ្ធិយ៉ាមិនបានចាប់អារម្មណ៍ថា មេត្រីនឹងចេញពីបន្ទប់មកនោះ ឯនាងវិញ ក៏មិនបានប្រុងប្រៀបកាយថា សិទ្ធិយ៉ានៅកៀកខាងក្រៅបន្ទប់ ទើបធ្វើឱ្យច្រមុះកំលោះវិះនឹងប៉ះថ្ពាល់ស្រីមេត្រី ។ ទាំងកំលោះ ទាំងកញ្ញាមេត្រីស្ទុះជើងពីរជើងបី ថយក្រោយដើម្បីគេចគ្នា ។ សិទ្ធិយ៉ាភ្ញាក់ព្រើត គេប្រញាប់រកពាក្យពេចន៍មកស្រដីដើម្បីចៀសវាងនាងខ្មាស :

-អ្នកនាងមានទម្លាប់ក្រោកថ្មើរនេះដែរអេះ ?

-ចាសទេលោក មិនមែនជាទម្លាប់អីទេ តែព្រឹកនេះ ខ្ញុំប្រញាប់ក្រោកពីព្រឹកបែបនេះ ព្រោះខ្ញុំត្រូវទៅភ្នំពេញ ។

-ហ្អាក ! ហេតុអីអ្នកនាងអញ្ជើញទៅភ្នំពេញថ្ងៃនេះ បើពិធីបុណ្យមិនទាន់បញ្ចប់ផង ។

-ចាស នាងខ្ញុំមានធុរៈសំខាន់នៅភ្នំពេញណាលោក ។

-អ៊ូ ! គឺបែបនេះទេ ។

-ចុះលោកមានទម្លាប់ក្រោកពីព្រឹកបែបនេះមែនទេ ?

-បាទ គឺខ្ញុំក្រោកពីព្រឹកបែបនេះ ដើម្បីហាត់ប្រាណ ។

គេទាំងពីរនាក់ដដែកគ្នាបណ្ដើរ ដើរមករករថយន្តដែលតាកែមបញ្ចេះចាំមេត្រីបណ្ដើរ ។ ធីតាតបវាចាទៅកាន់បុរស :

-លោកមានទម្លាប់ល្អណាស់ ។

មេត្រី និងកំលោះបានដើរមកដល់ជិតយានល្មម មេត្រីសំពះសិទ្ធិយ៉ានាងបន្ទឺ :

-អ៊ូ ! ខ្ញុំជម្រាបលាលោកសិនហើយ ។

-បាទ អញ្ជើញអ្នកនាង ។

ម៉ោងប្រាំបីព្រឹកថ្ងៃនេះដដែល ក្នុងថ្នាក់រៀន ពនិតាអង្គុយសរសេរវិញ្ញាសាដោយអារម្មណ៍ល្ងឹងល្ងើយ ... ដៃនាងសរសេរ តែមុខនាងហាក់ដូចជាពិភពលោកទាំងមូលកំពុងរលំបាក់ ... ជាមុខខ្លោចផ្សា ... មេត្រីលបមើលមិត្តរបស់នាងផង ឱនសរសេរផង ...មេត្រីឆ្ងល់ដែលពនិតមានអាការខុសពីទម្លាប់ ។ បើពីពេលមុនៗ ពនិតាជាសិស្សដែលរៀនពូកែ ដូចនេះចំពោះវិញ្ញាសាបែបនេះពនិតាមុខជាមិនលំបាកសរសេរចម្លើយទេ នាងមុខជាធ្វើកិច្ចការប្រឡងដោយសភាពធម្មតា តែពេលនេះពនិតាប្លែក ... មេត្រីមិនដឹងថា តើហេតុអីពនិតា

មានទឹកមុខដូចជាមិនចេះមេរៀន   មិនអាចប្រមូលអារម្មណ៍សរសេរវិញ្ញាសាប្រឡងបានល្អយ៉ាងនេះទៅវិញ ...

មួយខណៈកន្លងទៅ ពនិតាយកវិញ្ញាសាទៅជូនគ្រូ រួចនាងដើរចេញទៅក្រៅថ្នាក់ ទាំងនាងមិនបានមើលមុខមេត្រី ។ មេត្រីងឿងឆ្ងល់ តែមិនអាចសួរមិត្តបាន ព្រោះនាងជាប់បំពេញវិញ្ញាសាប្រឡងមិនទាន់រួច ។

ពនិតាមកឈរចាំម៉ូតូឌុប   រថយន្តគុណាករបរមកឈប់ជិតនាង   គេស្រែកពីក្នុងយានមកកាន់ស្រី :

-ឡើងឡានមក ។

ពនិតាធ្វើមិនឮ នាងមិនទាំងងាកមើលមុខបុរសគួរឱ្យស្អប់នេះទេ នាងបក់ដៃហៅម៉ូតូឌុប រួចស្រីឡើងជិះពីក្រោយអ្នករត់ម៉ូតូធ្វើព្រងើយ ។ គុណាករគ្រហឹមដើមក គេបើកឡានតាមពីក្រោយស្រី ។ ម៉ូតូឌុបនាំស្រីមកដល់ផ្ទះម្ដាយចិញ្ចឹម ពនិតាចុះពីម៉ូតូ។ នួនល្ហងដើរចូលផ្ទះ ដោយនាងមិនខ្វីបើកទ្វាររបង ដើម្បីឱ្យគុណាករអាចបរយានចូលមកក្នុងបរិវេណផ្ទះឡើយ ។ មីងណាយរត់មកបើកទ្វារផ្ទះ ឱ្យអ្នកប្រុសរបស់គាត់ ។ គុណាករបររថយន្តមកឈប់ពីមុខគេហដ្ឋាននរៈប្រញាប់យាត្រាចូលផ្ទះ ព្រោះគេមានបំណងស្កាត់ទៅជួបនិមល ។ ប៉ុន្តែពេលគេមកដល់មុខបន្ទប់ស្រី ទ្វារបន្ទប់បានបិទជិតទៅហើយ ។ មីងណាយលបមើលគេទាំងពីរ គាត់គិតថា អ្នកទាំងពីរប្រាកដជាឈ្លោះគ្នា ជាមិនខាន ។

លុះដល់ពេលបាយ   ពនិតាមិនចេញមកបរិភោគ   មីងណាយយកអាហារទៅជូននាងដល់បន្ទប់ ។ គាត់សម្គាល់ឃើញថា ពនិតាញ៉ាំបាយតែពីរបី

ស្លាបព្រា និងមិននិយាយអ្វីមកកាន់គាត់សោះ ។ មីងណាយក៏មិនរំខានស្រី គាត់លើកម្ហូបដែលសល់ពីស្រីបរិភោគ ដើរចេញមកក្រៅវិញ ។ មកដល់ក្រៅបន្ទប់គាត់ឃើញគុណករឈរវេរ៉េនៅទីនេះ ។ ភ្នែកគុណករសម្លឹងមកបាយម្ហូបក្នុងថាសដែលមីងណាយកាន់ចេញពីបន្ទប់ពនិតា ។ កំលោះឃើញបាយម្ហូបនៅសឹងតែពេញចានដដែល គេមិនស្តី រួចដើរចេញទៅបាត់ ។ មីងណាយលបគិតក្នុងចិត្ត " បើលួចស្រឡាញ់គេហើយ ម៉េចក៏ចូលចិត្តសម្តីអាក្រក់ឱ្យនាងម្ល៉េះអ្នកប្រុសគុណអើយ" ។

ថ្ងៃថ្មីមកដល់ សិទ្ធិយ៉ា និងមាតាបានវិលមកដល់ផ្ទះហើយ ។រួចព្រឹកនេះ លោកស្រីម៉ាណេត សិទ្ធិយ៉ា និងពនិតាកំពុងអង្គុយបរិភោគអាហាររួមគ្នាដ្បិតស្រីមិនអាចបដិសេធក្នុងការមករួមតុអាហារ ជាមួយគ្រួសារម្តាយចិញ្ចឹមបាន ចៀសវាងនាំឱ្យគាត់មានការសង្ស័យថា នាងមានបញ្ហាអ្វីមិនល្អកើតមានក្នុងចិត្ត ។ ព្រោះថា ទោះខឹង ស្អប់គុណករដែលធ្វើអំពើបំពានរាងកាយ និងភាពបរិសុទ្ធក្តី ក៏ពនិតាមិនអាចហាស្តីជម្រាបមាតារបស់កំលោះព្រាននារីដែរ ។ នាងមិនចង់ក្លាយជាមនុស្សស៊ីបាយបោកឆ្នាំង មិនចង់បង្កការមិនសប្បាយចិត្តដល់គ្រួសារដែលផ្តល់ជម្រកដល់ស្រី ។ អ្វីជាការចុកចាប់ ពនិតាស៊ូខាំមាត់ លេបទឹកភ្នែកដោយមិននិយាយស្តី ។ កំពុងតែនឹកគិត ស្រាប់តែគុណករដើរមកដល់គេចូលមកអង្គុយនៅតុបាយ ។ គុណករលបមើលមុខនាងបន្តិច គេឃើញមុខនាងស្រងូតរបៀបទើបតែយំរួច គេស្លុតចិត្តអាណិតស្រី ។ តែដើម្បីកុំឱ្យមាននរណាសង្ស័យលើទង្វើរបស់គេទៅលើពនិតា គេខំក្លែងធ្វើឬកហឺៗ ដោយចាប់

ស្លាបព្រាមកជូសបាយបរិភោគ ។ ពនិតាវិញ ឃើញមុខប្រុសចិត្តកំណាច ស្រីនីកដល់ការប្រមាថពីសំណាក់កំលោះចិត្តមារមកលើរូបនាងភ្លាម ពនិតាណែនទ្រូង បំពង់កដូចជាស្ទះ នាងលេបបាយមិនចូល ទឹកភ្នែករកកលរមៀលមកតែនាងទប់កុំឱ្យវាហូរចេញ ។ កល្យាណដាក់ស្លាបព្រាចុះលើចាន ជាសញ្ញាឈប់បរិភោគ ។ លោកស្រីម៉ាណេតមានការងឿងឆ្ងល់ ដែលបុត្រីធមិបញ្ឈប់ការបរិភោគបាយ នាពេលដែលមានវត្តមានកូនពៅមកដល់ គាត់សម្លឹងមកស្រីស្រដី :

-ហ្អាក ! ឆ្អែតហើយអ្ហេះកូន ?

-ចាស ខ្ញុំញ៉ាំឆ្អែតហើយអ្នកម៉ាក់ ។

-តែទើបនឹងញ៉ាំបានបន្តិចតើកូន ។

-កូនមិនឃ្លានសោះអ្នកម៉ាក់ កូនសុំទៅបន្ទប់មុនណាំអ្នកម៉ាក់ ។

-បងជូនទៅណាំ ។" សិទ្ធិយ៉ា"

ឮប្រយោគសិទ្ធិយ៉ាថានាជូនស្រីស្រស់ទៅកាន់បន្ទប់ មុខគុណករមិនរីកភ្លាម គេលបមើលមកបងប្រុស តែគេមិនមាត់អ្វីទេ ។ ពនិតាញញឹមស្ងួត នាងបន្លឺវាចា :

-អរគុណបងយ៉ា មិនចាំបាច់ជូនខ្ញុំទេ ។ ខ្ញុំមិនមានកើតអីឯណា ។ កូនជម្រាបលាហើយអ្នកម៉ាក់ ។

ស្រីពនិតាយាត្រាចេញទៅទាំងភក្ត្រស្រពាប់ស្រពោន មាតារបស់កំលោះទាំងពីរតាមសម្លឹងដំណើរចាកចេញរបស់នាង ។ លោកស្រីម៉ាណេតនិយាយទាំងផ្ដោតនេត្រាគន់ពនិតាពីក្រោយ :

-ថ្ងៃនេះ កូនពនិតាដូចជាប្លែក ។

គុណាករមានរំញោចក្នុងចិត្ត តែគេប្រឹងធ្វើអាកប្បកិរិយាឱ្យធម្មតា ។ សិទ្ធិយ៉ាសួរម្ដាយ :

-នាងប្លែកយ៉ាងណាអ្នកម៉ាក់ ? " សិទ្ធិយ៉ា "

-ម៉ាក់មើលទៅពនិតាដូចជាលាក់រឿងកង្វល់អ្វីមួយ នាងដូចជាទើបនឹងយំហើយ ។

ម្ចាស់បុរីកែលាសបែរមកកូនប្រុសពៅ គាត់សួរគេ :

-គុណ!កូនឯងស្អប់រង្កៀសចិត្តនឹងប្អូនស្រីអ្ហេះ ?ហើយកូនមានសម្ដីតូចសម្ដីធំដាក់នាងទេ?

-អ្នកម៉ាក់!ខ្ញុំទៅធ្វើអីគេបាន បើក្នុងមួយផ្ទះនេះ អ្នកណាៗក៏ស្រឡាញ់គេ ហើយម្យ៉ាងទៀតមុខខ្ញុំនេះ គេមិនទាំងចង់មើលផង ទើបរវាងពួកយើងទាំងពីរ ក្នុងមួយថ្ងៃៗគ្មានពាក្យអីដែលត្រូវនិយាយគ្នាមួយម៉ាត់សោះ " និយាយដល់ត្រង់នេះ គុណាករបួញមាត់មករកបងប្រុស បន្តវាចា " ...អ្នកម៉ាក់ គួរតែសួរបងយ៉ាទៅល្អជាង ក្រែងមានការប៉ះពាល់អីជាមួយគេនោះ ។

-ទេ ! ខ្ញុំមិនដឹងទេអ្នកម៉ាក់ ។ ខ្ញុំមិនដែលបាននិយាយអី ឬធ្វើអីឱ្យនាងទាស់ចិត្តទេ ។ " សិទ្ធិយ៉ា "

-កាលពីប៉ុន្មានថ្ងៃមុន ម៉ាក់មើលទៅនាងដូចជាធម្មតា តែព្រឹកនេះ...

កាលបើត្រូវមាតាកំពុងជជីករកមុខអ្នកបង្កបញ្ហាដល់ពនិតា កំលោះជើងល្អលួចបារម្ភក្រែងម្ដាយចុចសង្កត់សួរចម្លើយមកកាន់ខ្លួនជាថ្មីទៀត នោះគេអាចនឹងពិបាករក្សាទឹកមុខកុំឱ្យមាតាចាប់ថ្នាក់បាន ទើបគុណាករក៏ទម្លាក់ស្លាបព្រាឈប់បរិភោគ ។ លោកស្រីម៉ាណេតសួរកូនពៅដោយចម្លែក ក្នុងចិត្ត :

-អ៊ូ ! កូនឯងឆ្អែតម្នាក់ទៀតហើយអ្ហេះគុណា ?

-បាទម៉ាក់ កូនមានណាត់ជួបរិនដា ។កូនជម្រាបលាហើយអ្នកម៉ាក់ ។

ចប់ប្រយោគ គុណាករដើរទៅវឹង ។ ម្ដាយហួសចិត្តដែលគុណាករមានការទាក់ទងជាមួយនារីដល់ទៅពីរនាក់ក្នុងពេលតែមួយ ។ គាត់ស្រដីដោយគ្រវីក្បាលតិចៗ :

-ហ៊ឺ ! មើលទៅ ម៉ាក់ស្លាប់ប្រាកដជាបិទភ្នែកមិនជិតទេ បើកូនគុណានៅតែអ៊ីចឹង ។

-ហើយក៏មិនដឹងជានាងណាមួយឱ្យប្រាកដ ដែលគេត្រូវជ្រើសរើសទៀតផងអ្នកម៉ាក់ ។ បើសង្ហារគេដោតត្រណោតអ៊ីចឹង ។

-ម៉ាក់ព្រួយណាស់ បើថានាងណាមួយ ឱ្យវាប្រាកដទៅ ម៉ាក់មិនខ្វល់ពេកទេ ហើយចុះកូនឯងមានសម្លឹងនាងណាទុកទេកូន ។

-មិនយូរពេលទេម៉ាក់ កូននឹងជម្រាបពីអនាគតកូនប្រសាម៉ាក់ណា ។

-ម៉ាក់សប្បាយចិត្តណាស់ ព្រោះមានតែកូនទេ ដែលម៉ាក់សង្ឃឹមថាបានចៅពដោយសប្បាយចិត្ត បែរទៅកូនគុណមួយជាតិនេះ ម៉ាក់ខ្វល់ពីគេណាស់ ។

-៦-

ម៉ោងដប់មួយនិងសាមសិបនាទី ពនិតាកំពុងឈរចាំម៉ូតូឌុបដូចថ្ងៃពីម្សិល ។ រថយន្តរបស់គុណករលូនមកឈប់ក្បែរខ្លួនស្រី ប្រយោគមួយឃ្លារបូតពីមាត់អ្នកប្រុសសម្តីអាក្រក់ :

-ឡើងឡានមក ជូនទៅ ។

ពនិតាបែរភ្នែកមកមើលកំលោះ មុខនាងមាំលាយស្នាមសំឡក់បុរស ។ គុណករងក់ក្បាលដាក់ស្រី បញ្ចេញស្នាមញញឹមក្រឡៅ ហាក់មិនខ្វល់ពីអារម្មណ៍ក្រេវក្រោធរបស់នារី ជាមួយសម្តីលាន់មក:

-នាងខឹងអ្អេះ ? ស្អប់ខ្ញុំខ្លាំងអ្អេះ ?

ក្តាញ់នឹងមនុស្សមុខក្រាស់ ស្រីខឹងគេពេញដើមទ្រូង មនុស្សម្នាក់នេះមើលងាយស្រីពេញទំហឹង ពនិតាធ្វើមុខក្រញូវ បោះជំហានដើរទៅមុខ ដោយមិនតបសម្តី ។បុរសរូបសង្ហាបើកយានជំនិះតិចៗតាមស្រី ។ ពនិតាណាមួយខ្មាសមនុស្សម្នាតាមផ្លូវ ណាមួយខឹងនឹងភាពមើលងាយដែលគុណករធ្វើមកលើស្រី ពនិតាឈប់ដើរ នាងជះប្រយោគល្មមឮតែរូបគេម្នាក់ :

-មែន ! ខ្ញុំស្អប់អ្នកឯងដល់ឆ្អឹង ។ បើសម្លាប់អ្នកឯងបាន ខ្ញុំនឹងសម្លាប់ភ្លាម ហើយខ្ញុំហុតឈាមអ្នកឯងមិនឱ្យស្រក់មួយតំណក់ដល់ដីទេ ។

គុណករធ្វើជាបើកភ្នែកធំៗ និយាយបែបលេងតបទៅស្រី:

-អ៊ូហ្វូ!ខ្លាចណាស់ ខ្លាចណាស់ហ្ន៎ ។ នាងបានដល់ថ្នាក់ហ្នឹងមែនអេះ?

ឈឺចាប់ណាស់ ប្រុសនេះពូកែបញ្ឆិចិត្តធីតា ស្រីល្អខាំធ្មេញសឹងបាក់ ទឹកភ្នែកសឹងតែរមៀលចេញមកដោយក្តីចុកណែនក្នុងទ្រូង ។ នាងនឹកតែឯង ក្នុងចិត្ត " ហេតុអីគេសាហាវម្ល៉េះ គេចងកម្មពារអីនឹងខ្ញុំហ្ន៎ ? ចុះគេធ្វើមក លើរូបខ្ញុំ តើមិនមែនមានចិត្តស្រឡាញ់សូម្បីបន្តិចទេអី " ។ កំពុងស្លុងក្នុងគំនិត ខឹងនឹងបុរស សំឡេងអ្នកប្រុសមានភាពផ្អែមល្ហែមលាន់មកជាថ្មី :

-ពនិតា ! ឡើងឡានមក បងជូនទៅផ្ទះ ។

សម្តីស្រទន់របស់គុណាករ តែហាក់ដូចគ្រាប់ស្ករដែលស្រោបដោយថ្នាំពុល មកកម្ទេចកិត្តិយសស្រី ពនិតាកាន់តែស័កសៀតក្នុងបេះដូង នាងគ្មានវិធីការពារខ្លួនទេ បើអ្វីដែលជាវត្ថុមានតម្លៃរបស់ស្រី ត្រូវបានមច្ចុរាជបុរសនេះបំផ្លាញអស់ហើយ គ្មានសល់ទេកេរ្តិ៍ជាស្រីក្រមុំ ... ទឹកភ្នែកដណ្តើមហូរមករហាម ដៃស្រីក្តោបចូលគ្នាដោយកំហឹង មុខជូរចត់បង្ហាញលើភក្ត្រាស្រី ... រួចសៀវភៅក៏ជ្រុះពីដៃរបូតទៅលើដី ហើយរាងការល្វតល្វន់ ក៏រលំដួលព្រួសតែម្តង ។ ឃើញស្រីសន្លប់ គុណាករភ័យណាស់ គេបើកទ្វារយាន ស្ទុះមករកនាងទាំងស្រែកដោយរន្ធត់ចិត្ត :

-ពនិតា !

គុណាករបីត្រកងកាយស្រីបណ្តូលចិត្ត ដើរមករករថយន្ត ។ កំលោះស្រឡាញ់នាងណាស់ តែគេមាតិរឹងមិនព្រមបញ្ចេញសម្តីឱ្យនាងដឹងចិត្ត ។

គេដាក់នាងថ្នមៗទៅលើពូកយានយន្ត ។ រួចគេបើករថវិទ្យាសាស្ត្រទៅមុខដោយចិត្តជ្រួលច្របល់ ។

យានជំនិះនាំអ្នកប្រុសមកដល់កូនភូមិគ្រឹះតូចមួយយ៉ាងស្អាតច្រឡឹង។ ស្ទូរយានបាននាំកាយស្រីម្នាក់ឱ្យចេញពីវិមាន គឺជានារីក្នុងវ័យប្រមាណ២២ឆ្នាំមួយរូប ។ នាងមានភក្ត្រស្រស់ស្អាតគួរឱ្យឃ្លាន់ក្លាញ់ រូបរាងសមនឹងដងខ្លួនឥតខ្ចោះ ។ ធីតាឈ្មោះរិនដា ជាសង្សារម្នាក់ទៀតរបស់គុណករ។ ស្រីដើរមកអ្នកប្រុសដែលកំពុងបីពនិតាចេញពីយាន ។រិនដាបន្លឺសួរសង្សារ ទាំងមុខឆ្ងល់ :

-នាងកើតអីហ្នឹងបងគុណ ?

-នាងសន្លប់។ អូនជួយរកកន្សែងទទឹក មកឱ្យបងក្នុងបន្ទប់ទទួលភ្ញៀវណ៎ារិនដា ។

-ចាស បង ។

គុណករបីពនិតាដើរទៅរកបន្ទប់ទទួលភ្ញៀវ ស្រីរិនដារត់ទៅរកកន្សែងនិងទឹក ដើម្បីយកមកឱ្យបុរសតាមបញ្ជាគេ ។ មកដល់បន្ទប់គេងសម្រាប់ទទួលភ្ញៀវ បុរសផ្តេកកាយស្រីពនិតាទៅលើគ្រែ ។រិនដាដើរត្រឡប់មកវិញជាមួយដៃកាន់កន្សែង និងចានដែកដាក់ទឹក ។ នរៈទទួលកន្សែងពីសង្សារ។ អ្នកប្រុសជ្រលក់កន្សែងទៅក្នុងទឹក រួចគេពូតកន្សែងឱ្យស្រស់ទឹក ទើបគេយកមកជូតមុខ ជូតដៃឱ្យស្រីពនិតាយ៉ាងថ្នាក់ថ្នម ។ រិនដាឈរសម្លឹងកាយវិការគុណករដែលថ្នាក់ថ្នមនារីចម្លែកម្នាក់ នៅចំពោះក្រសែភ្នែកនាង ។ រិនដាជាស្រីចិត្តទូលាយ នាងមិនដែលរារាំងបំណងគុណករឡើយ ។ បេះដូងនាង

ថ្ងៃមួយនោះ ស្រាប់តែលឺសំឡេងស្រែកហៅពីខាងក្រោយខ្ញុំ ប្ដីរបស់ខ្ញុំក៏ងាកទៅមើល ហើយក៏ឃើញនារីម្នាក់ដើរមកជិតគាត់ ហើយនិយាយថា ហើយនារីនោះក៏និយាយថា តើលោកចាំខ្ញុំបានទេ ? ... ខ្ញុំឈរមើលគេទាំងពីរ ...

... ទាំងពីរនាក់ ...

: ...

; ...

: ...

...

សង្សារស្រឡាញ់តែខ្លួនម្នាក់វិញ ។ តែជាមួយគុណាករ ... មិនអាចទេ រិនដា ដឹងច្បាស់ ទើបស្រីត្រូវតែបង្ខំចិត្តញញឹម ... នាងញញឹមស្ងួត ។ គុណាករ ពោលវាចារបៀបស្ទាបស្ទង់ចិត្តស្រីរិនដា :

-បើបងប្រាប់អូនថា នាងជាប្អូនស្រីបង អូនជឿបងទេ ?

-បងគុណា ! តែខ្ញុំមិនដែលដឹងថា បងមានប្អូនស្រីសោះ ។

-មែន ! បងមិនធ្លាប់មានប្អូនស្រីមែន តែម៉ាក់បងទើបនឹងទទួលនាង ជាកូនម្នាក់ទៀត ។

-តែអូនមិនជឿថា បងចាត់ទុកនាងជាប្អូនទេ ។

គុណាករសម្លឹងមុខរិនដា របៀបរកចម្លើយពីទឹកចិត្តនាងចំពោះទំនាក់ ទំនងគេ និងពនិតា ។ រួចបុរសងាកមកមើលពនិតា គេគយគន់ភក្ត្រពនិតា យ៉ាងយូរ ។ គេពិបាកចិត្ត មុខគេស្រពោន គេមួម៉ៅដែលពនិតារឹងរូសមិនព្រម បណ្ដោយខ្លួនមកតម្រូវចិត្តរបស់គេ ដែលស្រឡាញ់នាងស្ទើរនឹងលេប តែគេជា ប្រុសប្ញកធំ សម្ដីមិនចេះទន់ភ្លន់ ក៏រហូតឱ្យគេទប់ចិត្តមិនបាន នាំឱ្យប្រព្រឹត្តខុស បែបនេះ ។ អ្វីដែលគេបំពានកាយស្រី ព្រោះគេដឹងទៀតថា ពនិតាខុសពីនារី ដែលគេធ្លាប់ទាក់ទង តែគេត្រូវការរូបនាងជាមិត្តមួយរយឆ្នាំ ដូចនេះវិធីយក ប្រាណនាង គឺអាចជាចំណងចាប់ចិត្តា មិនឱ្យរបូតពីដៃគេ។ រិនដាវិញ សម្លឹងគុណាករ ដោយមិនឃើញគេនិយាយអ្វីបន្ត នាងញញឹមស្ងួត នាងសួរ អ្នកប្រុស :

-បងគុណា ! បង និងនាងនេះមានរឿងអ្វីអ្ហេះ បានជាដល់ថ្នាក់នេះ ?

-នាងនេះចចេសរឹងរូស បងត្រូវការផ្ដល់មេរៀនខ្លះដល់នាង ។ " ស្រដីដល់ត្រង់នេះ បុរសបែរមករិនដា គេចាប់ដៃនាង គេពោលបន្ទរបៀបឆ្ងល់ " ... រិនដា ! កាលអូនស្រឡាញ់បងដំបូង អូនមានស្ដាយខ្លួនប្រាណអូនទេ ?

-អូនស្រឡាញ់បង មានរឿងអីដែលអូនស្ដាយក្រោយ។ អ្វីៗរបស់អូនវាគឺជារបស់បងដែរ ។

ឮវាចារិនដា គុណករស្រាប់តែងាកមកមើលពនិតា ..., គេគិតក្នុងចិត្តថា ចុះពនិតាវិញ ហេតុអីនាងមិនដូចរិនដា ? រូចបុរសនឹកស្រមៃដល់សម្ដីពនិតា ដែលហាបណ្ដេញគេ នាពេលដែលគេហៅនាងឱ្យជិះរថយន្តជាមួយគេ នូវពាក្យដែលគេហាក់ដូចជាញញើតផង មិនយល់ចិត្តនាងផង គឺ" មែន! ខ្ញុំស្អប់អ្នកឯងដល់ឆ្អឹង បើសម្លាប់អ្នកឯងបាន ខ្ញុំនឹងសម្លាប់ភ្លាម ហើយខ្ញុំហុតឈាមអ្នកឯងមិនឱ្យស្រក់មួយតំណក់ដល់ដីទេ ។ " គិតយ៉ាងនេះ គុណករនឹកប្រៀបធៀបពីទឹកចិត្តពនិតា មកជាមួយទឹកចិត្តរិនដា ដែលរិនដាជាស្រីបែបសម័យទំនើប មិនប្រាកដជាមួយស្នេហានៅឡើយ ដោយគ្រាទំនាក់ទំនងភ្លាមៗជាមួយនឹងគុណករ រិនដាក៏ដូចម្លិះ សុទ្ធតែទុកស្នេហាជាគ្រឿងកំដរជីវិត ដែលពួកនាងគិតថា អាចផ្លាស់ប្ដូរតាមចិត្តត្រូវការតែប៉ុណ្ណោះ ។ កាលបើមិនយល់ចិត្តពនិតាច្បាស់ នរៈនិយាយបែបរវើរវាយតែឯង ទៅកាន់រិនដា :

-អូនខឹងបងទេ បើបងមានពនិតាម្នាក់ទៀតរិនដា ?

-ចាស បងមានខ្ញុំ ហើយបងមានម្លិះ បើបងមាននាងម្នាក់ទៀត តើបងទ្រាំបានទេ ?

វិនដានិយាយទាំងល្ងក់ដៃមកច្របាច់ដៃគុណករតិចៗ របៀបពិបាកចិត្ត ជំនួសមាណពទៅវិញ ព្រោះនាងដឹងថា ម្លិះតែងតែបង្ករឿងស្មុគ្រស្មាញដល់មាណព ចំពោះទំនាក់ទំនងស្នេហាត្រីកោណរវាងនាង ម្លិះ និងគុណករស្រាប់មកហើយ ចុះបើបន្ថែមពនិតាទៀតនោះ តើគុណករជួបបញ្ហាអ្វីជាបន្ថែមទៅ ? អ្វីដែលជាសម្ព័ន្ធវិនដា វាជាទឹកចិត្តទូលាយរបស់នាង តែបេះដូងនាងកំពុងចុកណែនដោយការឈឺចាប់ ស្នាមញញឹមជិតលើបបូរមាត់វិនដា តែឱ្យនាងតឹងស្ទើរប្រេះធ្លាយដោយក្ដីសោកសៅ...ព្រោះពេលវិនដាមកជួបគុណករជាគូស្នេហ៍ នាងក៏មានចិត្តស្រឡាញ់គេដោយពិតៗ ដែលខុសពីគំនិតពីមុន ដោយនាងដែលធ្លាប់រស់នៅបែបជានារីសម័យទំនើប ធ្លាប់ទុកស្នេហាជារបស់មិនសំខាន់...

គុណករកំពុងសម្លឹងពនិតា គេមិនបានមើលមុខវិនដាទេ គេមិនដឹងចិត្តស្រីវិនដាកំពុងអួលណែនឯណា បើរវាងគេ និងវិនដាមានការសន្យាមួយយ៉ាងជាក់លាក់ ដោយមិនឃាត់ឃាំងនរណាមិនឱ្យជ្រើសរើសមនុស្សជាទីប្រាថ្នាពិតរបស់បេះដូង ដើម្បីរៀបអាពាហ៍ពិពាហ៍ទេ ទោះជាភាគីវិនដា ឬភាគីគុណករ។ ដោយកិច្ចសន្យានេះ ទើបគុណករមិនសូវជាចាប់អារម្មណ៍ពីទឹកចិត្តរបស់វិនដា ដោយគេគិតថា វិនដាមិនមានក្ដីស្រឡាញ់ពិតប្រាកដជាមួយគេទេ ហើយនាងក៏មិនចងគេដោយចំណងស្នេហ៍ស្មោះដែរ ហើយអ្នកម៉ាក់របស់គេត្រូវការកូនប្រសាបែបណានោះ គឺមិនមែនបែបវិនដា ឬម្លិះ ដែលជាស្រីបែបសម័យទំនើបរបៀបស្រីបរទេស ដែលពួកនាងបានរួមរស់ជាមួយគេយ៉ាងចំហ

មុនអាពាហ៍ពិពាហ៍ឡើយ ។ កំពុងស្លុងជាមួយការពិចារណា ពនិតាស្រែក ទាំងមិនទាន់បើកភ្នែក :

-ខ្ញុំស្អប់អ្នកឯង ... ខ្ញុំស្អប់អ្នកឯង ។

គុណករ និងរិនដាសម្លឹងមុខពនិតា ពួកគេដឹងថា នាងមមើ ហើយ នាងមិនទាន់ដឹងខ្លួនទេ ។ មួយភ្លែតភ្លាមនោះ ពនិតារើកព្រោលពេញគ្រែ ម្តងទៀត ជាមួយសម្រែកខ្លាំងៗ :

-ខ្ញុំស្អប់ ! ខ្ញុំស្អប់ ។

គុណករភ័យពីអាការៈពនិតា គេស្ទុះទៅសង្កត់កាយនាង កុំឱ្យរើ កុព្រោលពេក ទាំងនរៈវាចា :

-ពនិតាយ៉ាងម៉េចហ្នឹង ?

ពនិតាបើកភ្នែកឡើង នាងឃើញគុណករនៅក្បែរកាយ នាងស្ទុះ ងើបអង្គុយភ្លែត មុខស្រីមានភាពភ្ញាក់ផ្អើល នាងខឹងឡើងញ័រមាត់ នាង រលាស់ដៃ ចេញពីដៃគេដែលចាប់ដៃស្រី តែមាណពមិនព្រមព្រលែងដៃធីតា ។ កល្យាណបន្លឺខ្លាំងៗ:

-អ្នកឯង ! អ្នកឯង ... ចេញទៅ ។

ជាមួយសម្រែក ស្រីរើបម្រះទាល់តែរួចពីដៃគុណករ ទាំងស្រីប្រឹង ងើបពីគ្រែផង ។ គុណករស្រវាចាប់ឱបនាង ដើម្បីទប់ការរញ្ជួយចិត្តដែលស្រី មានប្រតិកម្មយ៉ាងរហ័ស ដោយនាងមានកំហឹងចំពោះគេ ។ ពនិតាមិនព្រម

បណ្ដោយឱ្យគុណាករប៉ះកាយនាង ស្រីបម្រះពីការឱបរបស់គេផង ស្រែកផង :

-កុំប៉ះសាច់ខ្ញុំ ខ្ញុំស្អប់អ្នកឯងណាស់ ។

ទីបំផុតគុណាករព្រលែងកាយស្រី នាងងើបឈរភ្លាម បម្រុងរត់ចេញ តែកាយស្រីទ្រេតរកកលដួល ព្រោះនាងហាក់ដូចជាមិនមានកម្លាំងក្នុងខ្លួនសោះ ។ គុណាករស្ទុះមកជួយទប់ប្រាណនួនល្អងកុំឱ្យដួល តែធីតាព្យាយាមគេចពីការជួយរបស់គេ ដោយស្រីភ្ញាប់វាចា :

-មិនបាច់ទេ ខ្ញុំឈរខ្លួនឯងបានហើយ ។

-ពនិតា ! អូនឯងមិនទាន់ស្រួលខ្លួនទេណា ។

-មិនបាច់ទេ កុំព្យាយាមមកទាក់ទងខ្ញុំ ។ ខ្ញុំមិនត្រូវការអ្នកឯងទេ ។

និយាយតែប៉ុណ្ណេះ ស្រីប្រឹងប្រមូលកម្លាំងចិត្តកម្លាំងកាយដែលល្វើយ ដើម្បីរត់ចេញទៅក្រៅបន្ទប់ ទាល់តែបាន ។ គុណាករបម្រុងរត់តាមពនិតា តែវិនដាចាប់ដៃគេជាប់ នាងស្រដីទាំងមុខស្លូត :

-នាងនៅខឹងបងនៅឡើយ តើមានប្រយោជន៍អី បើបងទៅតាមនាងនៅពេលនេះ ។ បងគួរបណ្ដោយឱ្យនាងទៅចុះណា ។

គុណាករងក់ក្បាលតិចៗ គេទម្លាក់ខ្លួនអង្គុយចុះលើពូក ធ្វើមុខស្មុយប៉ៃ។ រួចគេយកដៃទាំងពីរមកច្បូតមុខខ្លួនឯង របៀបទប់ទល់ការឈឺចាប់ដែលកម្រើកក្នុងចិត្ត ដោយសារពនិតាមិនយល់ចិត្តគេ ។ វិនដាមានមុខជូរចត់ ដែលអ្នកប្រុសសម្ដែងចិត្តស្រឡាញ់ស្រីផ្សេងនៅចំពោះមុខនាង តែយ៉ាងណាស្រីបារម្ភពីអ្នកប្រុស ដោយនាងសួរគេ :

-បងញ៉ាំបារីអ្ហេះ ?

ដ្បិតអីជារឿងរាល់ពេលដែលបុរសមានបញ្ហាពិបាកក្នុងចិត្ត គេតែងតែយកបារីមកជក់ ដើម្បីបំភ្លេចការមិនសប្បាយចិត្តទាំងនោះ ។ លុះឮប្រយោគរិនដាបែបនេះ គុណាករពោល :

-បងអរគុណរិនដា ។ អូនល្អនឹងបងជានិច្ច ។

-មិនបាច់អរគុណអូនទេ អ្វីដែលធ្វើឱ្យបងសប្បាយចិត្ត អូនត្រេកអរនឹងបំពេញជូនបងភ្លាម ។

ចាប់វាចា ស្រីរិនដាដើរមកយកបារីមួយដើម មកហុចឱ្យមាណព ។ គុណាករទទួលបារីមកដាក់មាត់ ។ រិនដាគូសដែកកេះ អុចបារីឱ្យគេ ។ បុរសបឺតបារី ជាមួយមុខស្លូតចែស ។រិនដាអង្គុយសម្លឹងគេ ដោយភក្ត្រក្រៀមក្រំ ។

..................................................................................................

..................................................................................................

ថ្ងៃស្អែកឡើង នាមុខមហាវិទ្យាល័យពេទ្យ យើងឃើញពនិតា មេត្រីសិទ្ធិយ៉ាឈរជិតរថយន្តរបស់កំលោះកូនច្បងរបស់លោកស្រីម៉ាណេត ។ ពនិតាញញឹមស្ងួត ស្រដីទៅកាន់អ្នកប្រុស :

-អូនសុំទោស សុំបងជួយជម្រាបអ្នកម៉ាក់ផង គឺអូនមានមេរៀនច្រើន ត្រូវរៀនជាមួយមេត្រីណាំបង ទើបមិនបានទៅគេងឯផ្ទះយើងទេ ។

-បាទ បងនឹងជម្រាបអ្នកម៉ាក់ ។ បងលាហើយអីចឹង ។ អ្នកនាងមេត្រី ខ្ញុំលាហើយអ្នកនាង ហើយនេះខ្ញុំមិនទាន់បានសួរសុខទុក្ខអ្នកនាងផងស្រាប់តែជម្រាបលាអ្នកនាងទៅហើយ ។

-ហ្អា ! បងស្គាល់មេត្រីអ្ហេះ ?

-គ្នាជាក្មួយរបស់អ្នកមីងណារី គ្នាបានជួបលោកសិទ្ធិយ៉ានៅពេលគាត់និងម៉ាក់របស់គាត់ទៅចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានរបស់អ្នកមីងណាំ ។

-អ៊ុំ ! អីចឹងទេ ។

-អីចឹងបងលាម្តងទៀតណាំពនិតា ។ខ្ញុំជម្រាបលាហើយអ្នកនាងមេត្រី

-ចាស បងអញ្ជើញ ។

-ចាស លោក ។

នៅពេលដែលមេត្រីដើរទៅរករថយន្ត ពនិតាក៏ឡើងជិះម៉ូតូមេត្រីពីក្រោយ ដើម្បីធ្វើដំណើរទៅគេងនៅផ្ទះរបស់មិត្តនាង ។ មេត្រីរស់នៅក្នុងផ្ទះជួលមួយល្វែង ដែលលោកស្រីណារីបានជួលឱ្យនាងស្នាក់នៅ ដើម្បីរៀនសូត្រ ។

យើងបែរមកមើលឯវិមានលោកស្រីម៉ាណេតវិញ វេលាម៉ោងជិតដប់ប្រាំបួននាថ្ងៃនេះ កំលោះគុណាករកំពុងចុះជណ្តើរមកពីជាន់ទីមួយ សំដៅមករកមាតាដែលកំពុងអង្គុយមើលបញ្ជីប្រាក់ចំណូលពីការលក់ផ្ទះល្វែង និងភូមិគ្រឹះមួយចំនួននៃបុរីកៃលាស ។ ក្រឡេកឃើញបុត្រាពៅ លោកស្រីភ្ញាក់បន្តិចដែរគាត់លាន់មាត់ ៖

-ថ្ងៃនេះ គ្មានខ្យល់បក់សោះ ម៉េចក៏កូននៅផ្ទះបាន ?

-អ្នកម៉ាក់មានប្រសាសន៍ថាម៉េចហ្នឹង ?

-អើ ព្រោះតែកូនមិនធ្លាប់នៅផ្ទះថ្មើរហ្នឹងណា ។ រាល់ល្ងាច ថ្មើរណោះឯងឈរជើងមិននឹងនោះអី ។

-អ្នកម៉ាក់ឱ្យបងណយរៀបចំបាយទៅ កូនឃ្លានហើយ ។

-ចាំបងឯងបន្តិចសិន គេនឹងត្រលប់មកវិញឥឡូវហើយ ។

-បងយ៉ាទៅណាអ្នកម៉ាក់ ? គឺកូនដូចជាឃ្លានសឹងអីហើយ ។

-កូនយ៉ាគេទៅទទួលពនិតា ។

គុណាករមិនស្រួលក្នុងចិត្តមួយរំពេច គេមួម៉ៅដែលបងប្រុសទៅទទួលពនិតា គេមិនច្បាស់ថា តើគេមួម៉ៅនេះ គឺព្រោះតែបងប្រុសដែលកាត់មុខគេដើម្បីទៅទទួលស្រី ឬខឹងនឹងពនិតាដែលមុខជាព្រមជិះរថយន្តជាមួយបងប្រុសនោះទេ ។ ដោយក្ដីមួហ្មង គេស្រដី :

-ម៉េចចាំបាច់ទៅទទួលគេ គេអាចមកដោយខ្លួនឯងបាន ។ គេមិនមែនកូនក្មេងឯណាអ្នកម៉ាក់ ។

-អើព្រោះតែពនិតាមិនមែនកូនក្មេងហ្នឹងណា ទើបម៉ាក់បារម្ភដល់គេ។ ហ៊ឺ ! មនុស្សអាក្រក់ក៏មានច្រើន វាអាចមានរឿងមិនល្អដល់នាង ដែលជាស្រីក្រមុំរូបស្អាត។

សំឡេងរថយន្តរបស់សិទ្ធិយ៉ាបរមកដល់ក្នុងបរិវេណវិមាន លាន់ស្នូរឮដល់ត្រចៀកអ្នកទាំងពីរ លោកស្រីជាម្ដាយវាចា :

-បងកូនបែបមកហើយ ។

គុណាករស្រាប់តែងើបដើរទៅជិតបង្អួច គេអើតមើលទៅក្រៅផ្ទះដើម្បីរកមើលស្រស់ស្រីបណ្ដូលចិត្ត ។មុខគេមានភាពក្រញូវ ព្រោះមិនពេញចិត្តដែលស្រីនឹងបណ្ដើរមកជាមួយបងប្រុសទេដឹង ។ប៉ុន្តែភ្នែកគេមិនបានឃើញស្រមោលនួនល្អងសោះ ឃើញតែបងប្រុសដើរចូលមករកម្ដាយ តែម្នាក់ឯង ។ មុខមូហ្មងរបស់គុណាករប្រែជាស្រាយមកជាមុខធម្មតាវិញ ។ លោកស្រីម៉ាណេតបន្លឺសួរកូនច្បង :

-ឯណាពនិតាកូនយ៉ា ?

-ថ្ងៃនេះ នាងសុំគេងនៅផ្ទះមិត្តភក្ដិ ។

គុណាករផ្ទៀងត្រចៀកស្ដាប់សម្ដីបងនិយាយពីអ្វី ដែលទាក់ទងពនិតាដោយមិនហ៊ានសំដែងឬកពាឱ្យម្ដាយ ឬបងប្រុសចាប់អារម្មណ៍ឡើយ ។ នរ:ឮម្ដាយសួរសិទ្ធិយ៉ាបន្ត :

-ម៉េចអ៊ីចឹងកូន ?

-នាងប្រាប់ថា មានមេរៀនច្រើនត្រូវរៀនជាមួយមិត្តនាងណាំម៉ាក់ ។

-គេងផ្ទះមិត្តភក្ដិ ! មេរៀនច្រើន ។

គុណាករនិយាយតិចៗតែឯង រួចមិនដឹងគិតឃើញយ៉ាងម៉េច មាណពក៏ងើបដើរទៅរកជណ្ដើរវិញ ។ ម្ដាយងាកមកមើលកូនពៅ គាត់បន្លឺសួរគេ :

-ហ្អាក ! កូនឯងទៅណាទៀតហើយ ក្រែងអំបាញ់មិញប្រាប់ម៉ាក់ថាឃ្លានបាយអ្ហេះ ?

-ឈប់ឃ្លាន ឈប់អីហើយអ្នកម៉ាក់ ។ កូនសុំទៅក្រៅបន្តិច ។

គេឆ្លើយទាំងមុខមិនរីក រួចដើរលឿនរ៉ុយ ដូចជាខឹងនឹងនរណា ។ សិទ្ធិយ៉ាតាមមើលអាការៈប្អូនប្រុស គេពោលវាចា :

-ចុះគេកើតអីទៅហ្នឹងម៉ាក់ ?

-ម៉ាក់មិនដឹងដូចតែគ្នា អំបាញ់មិញគេប្រាប់ថា ឃ្លានបាយ ឥឡូវប្រាប់ថា មិនឃ្លានទៅវិញ ។ យី ! កូននេះចំតែម្តង ។

-តោះ ! កូន ទៅញ៉ាំបាយ ម៉ាក់ដូចជាឃ្លានហើយ ។

-បាទ ម៉ាក់ ។

រាត្រីនេះ ក្នុងបន្ទប់កំលោះកូនច្បង នរៈយកហ្គីតាមកកេះប្រគុំបទភ្លេងលន្លង់លន្លោច ។ ដៃកេះហ្គីតា មុខគេរិះគិត គេស្រមៃឃើញទឹកមុខ និងអាការស្រពោនរបស់ពនិតាដែលសុំទៅគេងនៅផ្ទះមេត្រីជាមិត្ត ។ សិទ្ធិយ៉ាកំពុងគិតថា មុខពនិតាក្រៀមក្រំដូចជាផ្កាដែលស្លោកដោយកម្តៅថ្ងៃ ដូចដីដែលប្រេះបែកក្រហែងនារដូវរាំងស្ងួត ... ពនិតាដូចជាចម្លែក នាងមានបង្កប់ទុក្ខសោកអ្វីមួយក្នុងចិត្ត តែស្រីមិនស្រដីចេញមក ឱ្យនរណាដឹង ។ សិទ្ធិយ៉ាមិនយល់ចិត្តស្រី គេចង់ជួយនាង តែមិនដឹងជួយបែបណា បើនាងស្ងៀមស្ងាត់យ៉ាងនេះ...

យប់ថ្មើរនេះ ពនិតាអង្គុយសំកុកនាមាត់បង្អួចផ្ទះមេត្រី នេត្រាស្រីគន់ផាងដួងដែលយោលយោគតាមព្រះពាយបក់ ឱ្យរេទៅលិចទៅកើត វាដូចជាជីវិតនាងដែលគ្មានលំនឹង ដោយមិនគួរមកប្រឡាក់មន្ទិលដោយដៃព្រានអប្រិយធ្វើឱ្យជីវិតពិបាកកំណត់ទិសដៅ ។ ឯលើគ្រែ មេត្រីគេងបើកភ្នែកមើលមកមិត្ត មេត្រីដឹងថា ពនិតាកំពុងជួបបញ្ហាខ្លោចផ្សាក្នុងដើមទ្រូងហើយ គ្រាន់តែនាង

មិនដឹងប្រាកដជារឿងអ្វី ។ មេត្រីសម្រេចថា ត្រូវតែសួរនាំដល់ពនិតា ដើម្បីរំលែកទុក្ខរបស់មិត្ត ។ គិតយ៉ាងនេះ មេត្រីបន្ទឺ :

-ហ្អាក ! ឯងមិនទាន់គេងទេ ? ម្នាលក់មួយស្រឡេតទៅហើយ ។

-អុះ ! មេត្រីមិនទាន់គេងទេអី ?

-ព្រោះឯងមិនទាន់គេងដែរហ្នឹងណា ។ នែ ! ផ្ទះដ៏ធំនោះ ផ្តល់ក្តីមួហ្មង សម្រាប់ការរស់នៅរបស់ឯងអ្ហេះ ?

ពនិតាងក់ក្បាល ជាមួយមុខជូរចត់ ។ រួចនាងបែរទៅមើលលំហមេឃវិញ ព្រោះក្តីចុកចាប់ពេញទ្រូង វាបង្កឱ្យនាងទៅជាវាចាលាន់មកដូចមមើ:

-ខ្ញុំចង់ទៅរស់នៅឯស្រែជាមួយអ្នកម៉ែខ្ញុំវិញ ។

-យី ! ផ្ទះស្តុកស្តម្ភអីចឹង មានតែមនុស្សចង់ទៅរស់ ឯឯងបែរជាចង់ចាកចេញទៅវិញ ?

-បើដឹងមុនថា មកនៅទីនេះ បានជួបអ្វីនោះ ខ្ញុំសុំរស់ឯស្រែជាមួយម៉ែតាមរបៀបអ្នកក្រខ្សត់វិញ ហើយអាចនឹងមិនបានរៀនទៀតចុះ អាចនឹងធូរស្រាលក្នុងចិត្ត ដោយរង់ចាំពេលណាមានឱកាសមានប្រាក់ សឹមមកបន្តការរៀន។

-ឯងជួបអ្វី ខ្ញុំមិនយល់សោះ ។

-អ្វី...អ្វី...ខ្ញុំជួបអ្វី ? ទេខ្ញុំគ្មានរឿងអ្វីទេ ។

កំពុងជជែកគ្នា ស្នូរគោះទ្វារបានលាន់មក មេត្រីងាកមកទ្វារ បន្ទី :

-អ្នកណាមករកអីទាំងថ្មើរនេះ ឬជាលោកយ៉ាបងប្រុសឯងទេដឹង ?

-មិនមែនបងយ៉ាទេ យប់ជ្រៅហើយគាត់មិនមកទេ ព្រោះគាត់ដឹងថាគ្នាគេងទីនេះហើយនោះ ។

-អាចជាគាត់ដែរ ព្រោះគ្នាមើលទៅទឹកមុខគាត់ ពេលដែលឯងនិយាយថា មកគេងឯផ្ទះគ្នា ជាទឹកមុខដែលគាត់គិតដល់ឯងណាំ ។ គាត់អាចនឹងមានចិត្តលួចស្រឡាញ់...

-ឆ្កួត ! ឯងគិតផ្តាស ។

-ណ្ហើយគ្នាមិនប្រកែកជាមួយឯងទេ គ្នាទៅបើកទ្វារសិន តើជានរណាក៏គោះទ្វារខ្លាំងម្ល៉េះ ?

និយាយចប់ មេត្រីដើរមកទ្វារផ្ទះ ដើម្បីបើកឱ្យមនុស្សដែលគោះទ្វារជាខ្លាំងនោះ ។ ពនិតាដើរតាមក្រោយ នាងសង្ស័យថា ស្នូរគោះទ្វារខ្លាំងបែបនេះ គឺមានតែមនុស្សម្នាក់គត់ដែលមានទង្វើដូចនេះ ព្រោះគេតែងតែមករំខានចិត្តនាង មកធ្វើបាបទ្រូងស្រី យ៉ាងនេះទើបនាងមកតាមមេត្រី ដោយស្រីមិនចង់ឱ្យមានអ្វីមិនល្អកើតក្នុងផ្ទះមេត្រីទាំងយប់បែបនេះ ។ គ្រាដែរទ្វាររបើកមេត្រី និងពនិតាឃើញជាក់ជាគុណាករឈរច្រងោ ។ មេត្រីវាចាសួរគេ :

-លោកមករកអ្នកណា ?

-សុំទោសអ្នកនាង ខ្ញុំជាបងប្រុសពនិតា ។

-មិនមែនទេ ។" ពនិតា"

-ហេតុអីមិនមែន ?

និយាយរួច គុណករដើរមកឈរទល់មុខពនិតា ដើម្បីឱ្យខ្លួនគេកៀកប្រាណស្រី :

-ខ្ញុំមានរឿងនិយាយជាមួយនាង ។ នាងចេញទៅក្រៅបន្តិចបានទេ ?

-មិន...

-មិនរបស់នាងគឺមិនបដិសេធអ្វេះ? " គុណករនិយាយកាត់សម្តីស្រី "

- ទេ ! គឺមិនទៅ ។

-តែនាងត្រូវតែទៅ ។

ប្រយោគខាងលើ គុណករនិយាយឮៗ រួចគេខិតមកកៀកប្រាណស្រីដើម្បីងាយឱនខ្សឹបក្បែរត្រចៀកនិមល :

-បើនាងមិនចង់ឱ្យមិត្តនាងដឹងថា យើងមានរឿងអីនឹងគ្នា ។

ចំចំណុចខ្សោយ ពនិតាខឹងផង ខ្មាសផងដែលមុខគេលោមកកៀកនឹងភក្ត្រឆោមឆ្លៅ នាងស្រដី :

-ភ្លើ ឆ្កួត ។

គុណករខ្សឹបបន្ត ទាំងលូកដៃមកចាប់ដៃធីតាយ៉ាងស្អិទ្ធ :

-កុំអាលជេរបង ។

រួចបុរសក្បាលខូច បែរមកមេត្រី គេញញឹមបន្ទឹះ

-សុំទោសអ្នកនាង ខ្ញុំសុំនាំប្អូនស្រីខ្ញុំទៅក្រៅមួយភ្លែត ។

បន្ទាប់មក នរៈស្រដីយ៉ាងស្រទន់ភ្ជាប់ស្នាមញញឹមមករកពនិតាម្តង ទាំងចាប់ចុងម្រាមដៃនាង មកច្របាច់តិចៗផង:

-តោះ ! អូនតោះ ។

ស្រីឆ្អើមមិនហ៊ានរើផ្តេសផ្តាស មិនហ៊ានបញ្ចេញអាកប្បកិរិយាឱ្យមេត្រីចាប់ថ្នាក់បាន ទើបនាងបណ្តោយឱ្យគេដឹកដៃ ដើរចេញមកក្រៅផ្ទះ ។ មេត្រីមឹងមាំងតាមមើលពួកគេ ទាំងភ្លេចឆ្លើយតបសម្តីគុណាករ ។

មកដល់ក្រៅផ្ទះ ពនិតារលាស់ដៃពីបាត្តាបុរស ទាំងនាងនិយាយ:

-លែងៗ !

-កុំស្រែកឮៗណា៎ តិចខ្មាសគេ ។

គេព្រលែងដៃស្រី ហើយគេដើរទន្ទឹមនាង ភក្ត្រាបុរសញញឹមស្រស់ឯមុខធីតាក្រញូវជាប់ នាងខឹង តែនាងមិនអាចប្រកែកនឹងការគម្រាមរបស់គេបាន ។ មកដល់រថយន្ត នរៈស្រដី :

-អូនចូលឡានទៅ ។

-មិនទៅ ខ្ញុំមិនមែនគោក្របីចាំតែគេដឹកទៅណា ស្រេចនឹងអំពើចិត្តគេនោះទេ ។

-បើជាគោ ជាក្របី ខ្ញុំអូសនាងមកនាំឱ្យនឿយធ្វើអី ព្រោះផ្ទះខ្ញុំគ្មានស្រែសម្រាប់ឱ្យគោធ្វើដែរទេ ។

គុណាករស្រដីទាំងមុខបែបសឿងរបៀបអ្នកឈ្នះចិត្តស្រី រួចគេប្រែជាញញឹមយ៉ាងស្រទន់ លូកដៃមកបិចចង្កានិមល វាចាយ៉ាងផ្អែម :

-តែនាងជាមនុស្សរណ៍ា សំខាន់គឺនាងជាប្រពន្ធខ្ញុំ ទើបខ្ញុំអូសយកទៅផ្ទះវិញ ៕

-ប្រពន្ធ ! មនុស្សឈ្លើយ ឆ្កួត ។

មុខនាងឈឺចាប់ចំពោះពាក្យប្រមាថនេះណាស់ ស្រីសើចយ៉ាងជូរចត់រួចយារដៃទះកំភ្លៀងគុណករភ្លាម ។

-នាងហ៊ានទះកំភ្លៀងប្តីអ្ហែះ ? " គុណករនិយាយទាំងមុខក្រញូវ "

-ប្តី ! ភ្លើ ហាស់...ហាស់ ។

-ហេតុអីសើច ឬចង់ប្រកែក ?

-ហ៊ឹះ តាំងខ្លួនជាប្តីផង គឺលោកឯងបំពានរំលោភខ្លួនខ្ញុំ ។ លោកឯងយកអំពើស្មោកគ្រោកមកប្រឡាក់ខ្លួនខ្ញុំ ។ ខ្ញុំខ្ពើម ខ្ញុំស្អប់លោកឯង ។

នាងទះគេមួយកំភ្លៀង គុណករចាប់ដៃដែលនាងទះ គេសម្លឹងមុខនាងហើយនរះវាចា :

-ស្អប់ខ្ញុំអ្ហែះ ? ក៏បាន តែ...

ចប់ប្រយោគខាងលើ ដោយមានចិត្តខ្លាំងលាយដោយការមួម៉ៅកាលបើត្រូវមួយកំភ្លៀងផង គេស្ទុះមកចាប់បង្ខិលប្រាណស្រី ឱ្យនាងបែរមុខមកចំគេ រួចគេកញ្ឆក់ទាញនាងជាខ្លាំងបណ្តាលឱ្យនាងដួលមកលើកាយគេ រួចគេស្រវាឱបស្រី គេថើបនាង ដៃគេបបោសអង្អែលកាយធីតា ។កល្យាណឈឺចាប់នឹងអំពើដែលគេប្រព្រឹត្តបំពានកាយស្រី នាងខឹង នាងឈឺចាប់ នាងតក់ស្លុតទីបំផុតស្រីសន្លប់ បាត់មាត់ឈឹង ។

គុណាករភ្ញាក់ព្រើត ពុទ្ធោ ! ស្រីសន្លប់ទៀតហើយ ។គេប្រញាប់បីធីតាដើរមកកាន់រថយន្តដែលចតក្បែរនោះ ។ គេផ្តេកកាយស្រីថ្នម១ដាក់លើពូកយាន ។ កំលោះដើរមករកចង្កូត គេចូលអង្គុយទីនោះ រួចគេទាញក្បាលស្រីឱ្យផ្តេកមកកើយលើស្មាគេ ។ គេបើកយានទៅមុខ ដោយជារឿយ១ គេតែងតែងាកមកមើលស្រីដោយការបារម្ភ ។

ព្រលឹមនាថ្ងៃថ្មី ពនិតាបើកភ្នែកឡើង ស្រីមើលឃើញថា នាងកំពុងគេងលើពូកក្នុងបន្ទប់របស់នាងនាផ្ទះលោកស្រីម៉ាណេតមាតាចិញ្ចឹម ។ ធីតាមានការងឿងឆ្ងល់ ហេតុអីនាងមកគេងនៅទីនេះ ? បើពីយប់មិញនាងបានឈ្លោះប្រកែកជាមួយកំលោះចិត្តក្តៅ នៅមុខផ្ទះជួលរបស់មេត្រីតើ ។ កំពុងរំលឹកពីហេតុការណ៍ដែលកើតមានមកលើរូបស្រី ស្រាប់តែប្រយោគមួយឃ្លាលាន់ពីមាត់មាតាចិញ្ចឹម ឮមកប៉ះសោតានិមល :

-ភ្ញាក់ហើយអ្នេះកូន ។

-អ្នកម៉ាក់ ! កូនកើតអីហ្នឹង ?

-ពីក្បាលព្រលប់ កូនគុណបើកឡានទៅជួបកូនខ្យល់គដួលនៅឯផ្លូវកុំអីកូនមិនដឹងជាយ៉ាងណាទេហ្នឹង ។

-កូនខ្យល់គ ! កូនមិនដឹងខ្លួនមែនណ៎ាអ្នកម៉ាក់ ។

-បន្តិចទៀត ណាយលើកបបរមកឱ្យកូនញ៉ាំណ៎ា ។

-អរគុណអ្នកម៉ាក់ ។

-អ្នកម៉ាក់ កូន...

-កូនមានការអី មិនស្រួលខ្លួនអ្ហេះ ?

-ចាសទេ តែខែនេះ កូនសុំទៅនៅជាមួយមេត្រីបានទេអ្នកម៉ាក់ ?

-ទៅនៅជាមួយមេត្រី ! ហេតុអីកូន ?

-ចាស គឺកូនត្រូវរៀននៅពេលយប់ ។

-បើរៀនពេលយប់ ឱ្យសិទ្ធិយ៉ាជូនទៅជូនមក ក៏បានណាកូន ។

-តែកូនមិនចង់រុកកួនបងយ៉ាសោះអ្នកម៉ាក់ ។ ម្យ៉ាងទៀត កូនត្រូវសើរើមេរៀនជាមួយមេត្រី រហូតដល់យប់ជ្រៅផង ព្រោះអាទិត្យក្រោយត្រូវប្រឡងហើយ ។ " នាងរកពាក្យមកភរលោកស្រីម៉ាណេត ដើម្បីអាចទៅរស់ជាមួយមេត្រី ដើម្បីជាការគេចមុខពីគុណករ "

-ណ្ហើយ ! បើកូនចង់អីចឹង តាមចិត្តកូនចុះ ។ ចាំម៉ាក់ទំនេរ ម៉ាក់នឹងឆ្លៀតពេលទៅលេងកូនវិញ ។

-អរគុណ អ្នកម៉ាក់ ។ អីចឹងថ្ងៃបន្តិច កូននឹងទៅផ្ទះមេត្រីតែម្តងណាអ្នកម៉ាក់ ។

-បានតើកូន ចាំម៉ាក់ឱ្យបងយ៉ាជូនកូនទៅណា ។

បន្តិចក្រោយមក លោកស្រីម្ចាស់បុរីកែលាសក៏យាត្រាចេញពីបន្ទប់ធីតា ។គាត់ដើរមកវាក់អើនឹងកំលោះកូនពៅឈរអើតអើមនៅមាត់ទ្វារពនិតា ។ លោកស្រីសម្លឹងមុខបុត្រា បម្រុងបន្លឺសួរគេ តែនរះពោលវាចាមកកាន់ម្តាយជាមុន :

- អ្នកម៉ាក់ម៉េចបណ្តោយគេ ឱ្យទៅសម្រាកនៅផ្ទះមិត្តភក្តិអីចឹង ?

-ម៉ាក់ឱ្យគេទៅ ឬ មិនទៅ វាទាក់ទងអីដល់ឯងនោះហ្អកូនគុណ ?

-ទាក់ទងណាំអ្នកម៉ាក់ ។

-ទាក់ទងយ៉ាងម៉េច ? ការដែលនាងនៅសំណាក់ផ្ទះមិត្តភក្តិ ម៉ាក់ដូចជាមិនឃើញមានអ្វីទាក់ទងកូនសោះ ។

-វាមិនទាក់ទងនឹងខ្ញុំទេ តែបើគេជួបប្រទះហេតុការណ៍មិនល្អ ម្ដាយគេមកតវ៉ានឹងយើងណាំអ្នកម៉ាក់ ។

-រឿងនេះ កូនមិនបាច់បារម្ភទេ បើមានរឿងអីកើតឡើង ម៉ាក់ទទួលខុសត្រូវទាំងអស់ ។

មុខគុណាករប្រែជាស្លូតថៃស គេមិនដឹងត្រូវនិយាយយ៉ាងណា ទៅកាន់ម្ដាយ ដើម្បីឱ្យគាត់ឃាត់ពនិតាកុំឱ្យទួនលួងទៅគេងនៅផ្ទះមេត្រី ។ គុណាករកំពុងរិះគិត ស្រាប់តែមីងណាយដើរមកដល់ បន្លឺមកកាន់គេ :

-ជម្រាបអ្នកប្រុស មានភ្ញៀវស្រីសុំជួប ។

-អ្នកណាបងណាយ ?

-នាងថា នាងឈ្មោះម្លិះ ។

-ម្លិះ ! " គុណាករលាន់មាត់ ទាំងលួងដៀងភ្នែកមើលមាតា រួចគេធ្វើមុខដូចជាមិនដឹងអ្វីទាក់ទងពីវត្តមានម្លិះ ដោយពោលបន្ដទៅម្ដាយ "...គេមករកកូនធ្វើអ្វីអ្នកម៉ាក់ ?

-ម៉ាក់ទៅដឹង គេមិនមែនសង្សារម៉ាក់ឯណា ? "លោកស្រីឆ្លើយ ទាំងមុខមិនសប្បាយចិត្ត របៀបបញ្ឆោះឱ្យកូនពៅ"

គុណករមុខមួហ្មង ព្រោះបេះដូងរបស់គេមិនបានប្រាថ្នាម្លិះទេ គេត្រូវការពនិតា ហើយពនិតាកំពុងតែរកផ្លូវគេចពីគេ ដែលគេមិនទាន់រកវិធីទប់ទល់ជាមួយការគេចរបស់ពនិតាបានផង ដូចនេះវត្តមានម្លិះមិនបានបង្កអារម្មណ៍រីករាយដល់កំលោះសោះ ។ ម្យ៉ាងមាណពមានសន្យាជាមួយស្រីជាសង្សាររបស់គេទាំងអស់ គឺពួកនាងមិនអាចមករកគេ ដល់ផ្ទះអ្នកម្ដាយទេ ដ្បិតគេមិនចង់ធ្វើអ្វីប៉ះពាល់ទឹកចិត្តម្ដាយ ដោយមិនចង់ឱ្យរំខានដល់មាតា ចំពោះទំនាក់ទំនងពួកនាង និងរូបគេ។ កាលបើម្លិះមករកគេដល់ផ្ទះយ៉ាងនេះ គឺនាងបំពានសន្យាហើយ ទើបនរៈមិនសប្បាយចិត្ត គេរអ៊ូតិចៗទាំងដើរទៅក្រៅផ្ទះដើម្បីទៅរកម្លិះ ។ ម្ដាយមិនបានដឹងចិត្តកូនប្រុសដែលជំពាក់ចិត្តលើពនិតា ហើយវត្តមានម្លិះជាក្ដីរុកកួនចិត្តគេវិញនោះ លុះអ្នកស្រីឃើញអាការៈកូន ខុសពីធម្មតា អ្នកស្រីតាមសម្លឹងកូន ដោយពោលតិចៗ :

-កូនហ្នឹងវាយ៉ាងម៉េចវាហ្ន៎ ?

នៅមុខសួនច្បារមុខភូមិគ្រឹះរបស់គុណករ ម្លិះឈរមើលកន្ទុំរុយហើរផ្លែលពីផ្កាមួយ ទៅផ្កាមួយ ។ ម្លិះញញឹម រភ្នែកតាមមើលសត្វស្លាបមិនឈប់ឈរ ។ សំឡេងគុណករលាន់មកប៉ះសោតាម្លិះ :

-អូនមកទីនេះធ្វើអ្វីម្លិះ ?

-បងសួរនេះ មានបំណងបែបម៉េច ? " ម្លិះសួរតបគេទាំងមុខក្រញូវ "

-គ្មានយ៉ាងម៉េចទេ តែអូនមិនត្រូវមករកបងដល់ផ្ទះទេណា ។

-មកពីបងខានទៅរកអូនយូរពេក ទើបអូនមករកបងដល់ផ្ទះ ។ អូនខឹងណាំ ព្រោះបងវង្វេងឈ្លក់នឹងរិនដាមែនទេ ?

-ម្លិះ ! អូននិយាយឱ្យប្រយ័ត្នមាត់បន្តិច ទីនេះជាផ្ទះបង ហើយអ្នកម៉ាក់បង ក៏លោកនៅក្នុងផ្ទះដែរ ។

-បើលោកនៅផ្ទះ តើយ៉ាងម៉េច ? អ្នកម៉ាក់បងមកទាក់ទងអីនឹងរឿងយើង បើលោកមិនដឹងរឿងរ៉ាវយើងផង ។

-ក៏ព្រោះតែលោកមិនដឹងហ្នឹងណាំ បានជាបងឱ្យអូនប្រយ័ត្នមាត់ ព្រោះបងមិនចង់ឱ្យលោកឮរឿងមិនគួរនឹងឮនោះអី ។

យល់ថា គុណាករនិយាយត្រូវ ម្លិះសម្រួលទឹកមុខ បន្ទន់សំឡេងជាងពេលមុន ដោយនាងស្រដី :

-ប៉ុន្មានថ្ងៃនេះ បងនៅឯណា ទើបអូនទូរសព្ទមកបង បងមិនទទួលសោះ ។

-បងមិនចូលចិត្តឬកពាអូនទេណាំម្លិះ ។ តាំងតែពីមុនរហូតដល់ពេលនេះ បងគ្មានចៅហ្វាយនាយត្រួតត្រាអីទេម្លិះ ។

និយាយចប់ គុណាករដើរចេញវឹង ទៅរករថយន្តដែលចតនៅមិនឆ្ងាយពីទីដែលពួកគេជជែកគ្នា ។ ម្លិះដើរតាមគេ របៀបប្រុងក្បៀកកំលោះមិនឱ្យទៅណាចោលនាងបាន គឺបើគេទៅកាន់ទីណា នាងក៏ទៅកាន់ទីនោះដែរ ។ គុណាករមួម៉ៅនឹងអាការៈហួងហែងរបស់ម្លិះណាស់ នាងកំពុងធ្វើផ្ដេសផ្ដាសខុសទំនង តែគេក៏យល់ថា ប៉ុន្មានថ្ងៃនេះ គេមិនបានទៅរកនាង ទើបនាង

មិនរីករាយ ។ គិតបែបនេះ គុណាករមិននិយាយអ្វីជាការបន្ទោសម្លិះពេកទេ គេគ្រាន់តែដើរយ៉ាងលឿន ទៅរកយាន ដើម្បីធ្វើដំណើរចេញឱ្យផុតពីផ្ទះ ។ស្រាប់តែរថយន្តវិនដាបរមកឈប់ពីមុខផ្ទះរបស់មាណពល្ងម ។ ម្លិះក្រឡេកឃើញវិនដា ភ្លើងប្រចណ្ឌដុតចិត្តនាងមួយរំពេច ស្រីនិយាយខ្លាំងៗ ទាំងបើកភ្នែកសម្លក់ទៅវិនដា ដែលចេញពីរថយន្តដើរមករកនាង និងគុណាករ :

-ហ៊ឺះ ! អីចឹងតើវិនដា ។ នាងមករកបងគុណដល់ផ្ទះមែន ។ " ម្លិះងាកមកបុរស នាងបន្លឺវាចាបន្ត " ...ហ៊ឺះ ! បងគុណ នេះអ្ហេះចម្លើយបង អូនឃើញនឹងភ្នែកហើយ បងមិនមានយុត្តិធម៌សម្រាប់អូនទេណា ។

-មិនពិត! បងមិនបានដូចអូនចោទទេ ហើយវិនដាក៏ទើបនឹងមកផ្ទះបង នៅថ្ងៃនេះដែរតើម្លិះ ។

វិនដាដើរមកជិតពួកគេ នាងញញឹមមកកាន់គុណាករ ស្រដីរួសរាយតាមនិស្ស័យនាង :

-ម៉ាក់អូនប្រើអូនមកផ្ទះគេជិតផ្ទះបង ទើបអូនក៏ឆ្លៀងចូលមកផ្ទះបងតែម្តង ។ " វិនដាងាកមកម្លិះ នាងញញឹមសួរម្លិះ " ...មកយូរហើយអ្ហេះម្លិះ ?

-មកមុនឯងបន្តិចហ្នឹង ចុះឯងមកផ្ទះបងគុណរាល់ថ្ងៃអ្ហេះ ?

-ទេ ! ទើបនឹងមកលើកដំបូង ។

-ពិតអ្ហេះ ?

-ចុះខ្ញុំកុហកឯងធ្វើអ្វី ?

-អាចនឹងកុហកដែរ របស់ឆ្នាញ់អាចនឹងលបលួចស៊ី ដោយមិនឱ្យអ្នកណាដឹងអីចឹងខ្លះទៅ ។

-ឯងនិយាយអី ខ្ញុំមិនយល់ទេ ?

-ខ្ញុំដឹងថា ឯងប្រាកដជាយល់ ចាំបាច់អីឯងក្លែងជាមិនយល់ ។

-ម្ជិះ ! ខ្ញុំពុំមែនប្រភេទមនុស្សធុនកំសាកទេ បើត្រូវការធ្វើអី ក៏មិនចាំបាច់លួចលាក់ដែរ ។ អាប្រភេទលបស៊ី លួចស៊ីក៏គ្មាន គឺបងគុណទៅរកខ្ញុំដល់ផ្ទះ ខ្ញុំពុំមែនធុនស្រីខ្លះមករកប្រុសដល់ផ្ទះទេ មែនទេបងគុណ ?

-រិនដា ! "ម្ជិះស្រែកគំហកដាក់រិនដា"

-ឈប់ៗ ! កុំឈ្លោះតវ៉ាគ្នានៅទីនេះ ។ "គុណាករ"

-មិនឈប់ ! មើលបងឯងនិយាយទៅ ឥឡូវរវាងខ្ញុំ និងរិនដា នៅទល់មុខគ្នាហើយ បងត្រូវរើសយកតែម្នាក់ ឱ្យដាច់ស្រេច ។

-អូនត្រូវការបែបនេះអ្ហេះម្ជិះ ?

-ចាស ! ដើម្បីឱ្យស្រីល្អនេះភ្លឺភ្នែក កុំក្អេងក្អាងដូចក្អាត់ក្នុងក្អមពេក ។

-បងគុណ...ខ្ញុំមិនចូលចិត្តបែបនេះទេ...ខ្ញុំជាមនុស្ស ពុំមែនរបស់...

រិនចង់និយាយថា នាងមិនមែនរបស់ដែលត្រូវឱ្យមនុស្សប្រុស ជ្រើសរើសទេ ព្រោះបើធ្វើបែបនេះ នាងគ្មានតម្លៃជាមនុស្សស្រីសោះ ។ តែគុណាករស្គាល់រិនដាច្បាស់ ហើយគេមិនស្មានថា ម្ជិះជាស្រីមិនចេះខ្មាសបែបនេះ ទើបគេស្រដី :

-ស្ងៀមរិនដា បងយល់ហើយ ។ " រួចកំលោះងាកមកម្លិះ គេសួរបញ្ជាក់នាងដោយក្រសែភ្នែកមិនសប្បាយចិត្ត ដែលម្លិះហ៊ានប្រើសម្តីបង្គាប់គេឱ្យជ្រើសរើសរវាងនាង និងរិនដា" ... ម្លិះ!អូនជាអ្នកបង្គាប់បង អូនប្រាកដជាមិនបន្ទោសបងទេណា ។ គឺបងរើសយករិនដា ជំនួសអូន ។

-បងគុណ ! ថាម៉េច បងឯង...រើសយករិនដាអ្ហេះ ? " ម្លិះសួរទាំងខឹងញ័រមាត់តតាក់"

- មែន ! បងរើសយករិនដា ។

-បងឯង ! បងឯង ! ខ្ញុំ... ខ្ញុំ ...

និយាយបានតែប៉ុណ្ណោះ ម្លិះត្រូវគាំងវាចា ដ្បិតស្រីពោរពេញដោយការក្រេវក្រោធពន់ប្រមាណ ។ តែដោយមិនអាចជះកំហឹងទៅលើបុរសជាទីស្រឡាញ់ ធីតាចិត្តស្រាលបែរជាស្រោចការក្តៅក្រហាយមកលើគូសត្រូវស្នេហា គឺរិនដាទាំងសាច់ទាំងឈាម ដោយម្លិះងាកមកសម្លក់សម្លឹងរិនដា ជាមួយដៃលើកចង្អុលសឹងតែដល់ភ្នែករិនដា ហើយនាងជះវាចាគ្រោតគ្រាតពោរពេញដោយគំនុំ :

-នាងឯង ! នាងឯង ! គង់តែដឹងទេ ថ្ងៃក្រោយ ម្លិះមិនចុះចាញ់នាងឡើយរិនដា ។

ចប់វាចា ម្លិះរត់ចេញទៅយ៉ាងលឿនសំដៅរថយន្តរបស់ស្រី ជាមួយទឹកភ្នែកឈឺចាប់លាយឡំដោយកំហឹងណែនទ្រូង ។ រិនឈរមុខស្លូត នាងចុកចាប់ណាស់ដែរ នាងមិនអាចមានពាក្យអ្វីមកនិយាយតបទៅកាន់ម្លិះ ហើយ

នាងមិនជាសប្បាយចិត្តប៉ុន្មានឡើយ ដែលគុណាករយករូបនាង ធ្វើជាឧបករណ៍ ដើម្បីព្រមានម្លិះដោយបែបនេះ ។ នាងស្រឡាញ់គុណាករ តែនាងមានកិត្តិយស នាងមិនមែនជារបស់លេងរបស់គុណាករឯណា ។ តែក្តីស្រឡាញ់ប្រុសស្នេហ៍ វាមានលើសលប់ក្នុងចិត្តរិនដា នាងចាំបាច់ត្រូវខាំមាត់លេបទឹកភ្នែកខ្លោចផ្សា ដែលបុរសធ្វើឱ្យទឹកភ្នែកនាងហូរ ។

គុណាករវិញ គេមានមុខពោរពេញដោយការរិះគិត អ្វីដែលគេធ្វើចំពោះម្លិះ វាជាចរិតឆេវឆាវ ចរិតមានះ ចរិតធ្លាប់តែមិននៅក្រោមបញ្ជានរណា ជាពិសេសចំពោះស្រីៗ ទើបបង្ខំចិត្តឱ្យគេយករិនដាមកធ្វើឧបករណ៍ព្រមានម្លិះ គេមិនចង់ធ្វើបែបនេះទេ តែគេគ្មានផ្លូវជ្រើសរើស ព្រោះម្លិះបានរុញឱ្យគេទ័លច្រក គេបែរមកលួចសម្លឹងរិនដាបន្តិច គេឃើញនាងស្រក់ទឹកភ្នែក គេអួលក្នុងចិត្ត ... តែគេមិនស្តី មិនលួងនាង មិនសុំទោសនាង ... នេះជាចរិតរបស់កំលោះឫកធំ ដែលមិនចំណុះស្រីៗ...ហើយចរិតនេះ គេកំពុងយកទៅប្រើជាមួយពនិតាដែរ ទើបគេមិនដែលសារភាពថាស្រឡាញ់ពនិតា ថាត្រូវការនាង ថាគេបានធ្វើខុសដោយរំលោភនាង ។

-៧-

គុណាកឈរនៅមុខមាត់ទ្វារផ្ទះមេត្រី ដៃគេលើកគោះទ្វារផ្ទះ ។ មួយភ្លែតនោះ មានលាន់សំឡេងមនុស្សកំពុងបើកទ្វារពីផ្នែកខាងក្នុងផ្ទះ គុណាករញញឹមសម្លឹងទ្វារ គេគិតថា បន្តិចទៀតគេនឹងបានជួបនារីជាទីស្រឡាញ់ពេញបេះដូង ។ មែន ! ទ្វាររបើកហើយ តែមិនមែនជាមេត្រីជាម្ចាស់ផ្ទះសោះ បែរជាលេចមនុស្សស្រីចំណាស់ម្នាក់មកឈរចំពោះមុខនរៈយើង ដោយស្ត្រីនោះបន្លឺវាចាមកកាន់កំលោះរូបសង្ហា :

-លោកមករកអ្នកណា ?

-ខ្ញុំសុំជួបពនិតា តើនាងនៅទេអ្នកមីង ?

-ពនិតា ! ពនិតាណាំ ខ្ញុំទើបនឹងមកនៅទីនេះបានមួយអាទិត្យ ខ្ញុំមិនស្គាល់ពនិតាណាំទេ ។ បើលោកចង់ជួបម្ចាស់មុន លោកខកហើយ ព្រោះខ្ញុំមិនដឹងនាងផ្លាស់ទៅទីណាទេ ។

-អ្នកមីងមិនដឹងពួកនាងទៅនៅទីណាទេ ?

-ចាស ខ្ញុំមិនដឹងមែនណាំលោក ។

-អ៊ីចឹង ខ្ញុំមិនរំខានអ្នកមីងទៀតទេ ខ្ញុំអរគុណ ហើយខ្ញុំសុំលាហើយ ។

នរៈដើរត្រឡប់មករករថយន្ត មុខគេស្រងូត បេះដូងគេដូចជាប្រហោងធ្លុង គេស្រាលខ្លួនស្ងើក ... ពនិតានៅទីណា គេត្រូវការរូបនាង ... ហេតុអីនាងគេចពីគេ ? គុណាករដើរមកអង្គុយសំកុកទ្រោបលើចង្កូតយាន ...

យើងបែរមកមើលសិទ្ធិយ៉ាម្តង មាណពកំពុងតែឈរទល់មុខនិស្សិតស្រីម្នាក់ នៅមុខមហាវិទ្យាល័យពេទ្យ ។ ប្រយោគមួយឃ្លាលាន់ពីបបូរមាត់អ្នកប្រុសរូបសង្ហា ជាកូនច្បងរបស់លោកស្រីម៉ាណេត :

-អត់ទោសអ្នកនាង តើស្គាល់កញ្ញាពនិតាជានិស្សិតដែលរៀននៅមហាវិទ្យាល័យវេជ្ជសាស្រ្តឆ្នាំទី៥ ដែរទេ ?

-ចាស ខ្ញុំមិនស្គាល់ទេលោក ព្រោះខ្ញុំរៀននៅឆ្នាំទី៣ ខ្ញុំមិនស្គាល់ពួកសិស្សច្បងអស់ទេ ។

-អ៊ីចឹង ខ្ញុំអរគុណហើយ ខ្ញុំសុំលាអ្នកនាងដែរ ។

-ចាស លោកអញ្ជើញ ។

សិទ្ធិយ៉ាដើរថយមករកយានរបស់គេ មុខគេស្រពោន គេនឹកពនិតាស្ទើរតែធ្វើអ្វីមិនត្រូវ គេលួចស្រឡាញ់ស្រី គេរង់ចាំឱ្យនាងបញ្ចប់ការសិក្សានាឆ្នាំនេះ នោះគេនឹងសារភាពស្នេហ៍ចំពោះនិមល ហើយអ្នកម្តាយរបស់គេលោកក៏យល់ស្របជាមួយគំនិតគេ ក្នុងការចងខ្សែជីវិតភ្ជាប់ជាមួយពនិតាដែរ។ តែពេលនេះ គឺនាងបានចាកចេញពីផ្ទះគេអស់រយៈពេលជាងមួយខែមកហើយ ហើយកំឡុងពេលនេះ ម្តាយរបស់គេក៏បានធ្វើដំណើរទៅបរទេសទៀត ធ្វើឱ្យស្រីមិនមានផ្តល់ដំណឹងអ្វីមកដល់គេសោះ ពីការរស់នៅរបស់ធីតា ។ ការដែលមាតាមិននៅទីក្រុងភ្នំពេញ ធ្វើឱ្យគេគ្មានទំនាក់ទំនងជាមួយពនិតា ទើបគេចង់ជួបនាង ចង់និយាយសាសងដើម្បីបន្ធូបចិត្តពុះកញ្ជ្រោលដោយការនឹកស្រី ...

គុណាករវិញ គេបររថយន្តវិលមកផ្ទះវិញហើយ នរះដើរដោយល្ហើយ ទៅរកបន្ទប់ដំណេករបស់ខ្លួន ។ ចូលដល់បន្ទប់ភ្លាម អ្នកប្រុសប្រះកាយភឹងទៅលើពូក ទាំងមិនខ្វីដោះខោអាវ គេបើកភ្នែកភ្លឹះ១សម្លឹងពិដាន ... ពនិតានៅទីណា ? បងនឹកអូន បងចង់សុំទោសអូនណា អ្វីដែលបងធ្វើទៅលើអូន គឺជាសេចក្ដីស្នេហាដែលបងមិនអាចទប់ចិត្តបាន ... នេះជាសម្រែកបេះដូងកំលោះឬកធំ សម្ដីអាក្រក់ ...បាត់ពនិតា គេមិនដែលទៅរករិនដាឡើយ... គ្មាននារីណាអាចមកជំនួសរូបពនិតាក្នុងបេះដូងគេបានទេ ...

ស្នូរយានរបស់សិទ្ធិយ៉ាលាន់សំឡេងនៅខាងមុខផ្ទះ កំលោះចិត្តក្ដៅស្រាប់តែស្ទុះរឹងចេញពីបន្ទប់ គេដើរយ៉ាងលឿនទៅរកបងប្រុសដែលគេគិតថាសិទ្ធិយ៉ាប្រាកដជាចូលមកក្នុងផ្ទះនាពេលបន្តិចទៀត ។ កូនប្រុសរបស់លោកស្រីម៉ាណេតទាំងទ្វេ ដើរមកប្រសព្វមុខគ្នានៅក្បែរជណ្ដើរសម្រាប់ឡើងទៅជាន់ទីមួយនៃវិមានរបស់ពួកគេ ។ ពាក្យសម្ដីមួយឃ្លាហួរពីមាត់គុណាករទៅកាន់បង:

-បងយ៉ា ! តើបងដឹងទេថា ពនិតាទៅរស់នៅទីណា ?

-បងមិនដឹងទេ ព្រោះមុននេះ បងទើបតែទៅរកនាងឯសាលា និងបងទៅរកនាងនៅឯផ្ទះរបស់អ្នកនាងមេត្រី តែបងមិនបានជួបនាង ។

ជាការពិត ក្រោយពីសិទ្ធិយ៉ាសួរនាំដល់ពួកនិស្សិតចំនួនពីរបីនាក់ដោយមិនបានព័ត៌មានអ្វីពីពនិតានោះ គេក៏បានទៅរកស្រីស្រស់នៅឯផ្ទះមេត្រី គឺគេទៅរកពនិតាក្រោយពេលដែលគុណាករបានចេញពីផ្ទះមេត្រីមកហើយ ។ រីឯគុណាករ កាលបើឮសម្ដីបងប្រុសឆ្លើយក្នុងន័យមិនដឹងអ្វីពីពនិតានោះ គេមិន

ជឿសម្ដីបងឡើយ ព្រោះគេតែងគិតថា បងប្រុសប្រាកដជាមានកំណួចចិត្តទៅលើពនិតា គេដឹងយ៉ាងច្បាស់ពីទឹកចិត្តបង ទើបគេប្រើផ្លូវកាត់ដោយរំលោភធីតា ដើម្បីជាចំណងចងរូបនាងមិនឱ្យនាងក្លាយជាមនុស្សរបស់បងប្រុស ដ្បិតបុរសដឹងទៀតថា សូម្បីតែមាតារបស់គេ ក៏លោកហាក់ដូចជាមានបំណងចង់ចងភ្ជាប់ពនិតាជាមួយសិទ្ធិយ៉ាដែរ ហើយគេវិញ គេមិនមានលេសសមរម្យនឹងបង្ហាញពីសេចក្ដីត្រូវការរបស់បេះដូងចំពោះពនិតា ដើម្បីជម្រាបម្ដាយបាន បើគេកំពុងមានទំនាក់ទំនងជាមួយនារីដល់ទៅពីរនាក់ ដែលគេមិនទាន់ដោះស្រាយចេញ ព្រោះយ៉ាងណាម្ដាយគេដែលស្រឡាញ់ពនិតាប្រៀបដូចជាលោកស្រឡាញ់បងប្អូនរបស់គេ ជាកូនរបស់លោកដែរនោះ ប្រាកដជាមាតារបស់គេមិនព្រមឱ្យគេធ្វើមិនគាប្បីទៅលើកូនស្រីចិញ្ចឹមរបស់គាត់ទេ ។ តែសម្រាប់គេគុណាករមានបំណងភ្ជាប់មេត្រីស្នេហ៍ជាមួយពនិតាសិន រួចបន្ដមក គេនឹងបញ្ចប់ឆាកលោនស្នេហ៍ជាមួយម្ទិះ ឬរិនដា ព្រោះពួកនាង និងគេមានសន្យាច្បាស់ណាស់ ដោយនរណាមិនមានសិទ្ធិរំលោភលើកិច្ចសន្យា ក្នុងការជ្រើសរើសគូជីវិតអនាគតនោះឡើយ ។ កាលបើគិតឃើញបែបនេះ និងលុះមកឮបងប្រុសបដិសេធមិនដឹងពីទីកន្លែងរស់នៅរបស់ពនិតា គុណាករបន្ទឺ :

-មិនដឹង ! បងស្មានតែខ្ញុំជឿបងអ្ហេះ ?

-ឯងជឿ ឬ មិនជឿតាមតែចិត្តឯងទៅ ព្រោះព្រឹកមិញបងទៅរកនាងដែរ តែមិនជួបនាងដូចតែគ្នា ។

ចម្លើយមួយឃ្លារបស់បងប្រុស ធ្វើឱ្យមុខគុណាករល្វើយ គេអស់សង្ឃឹម ដែលមិនមានដំណឹងពីពនិតា គេទម្លាក់ខ្លួនអង្គុយចុះលើកៅអីសាឡុង បែបដូចជាមនុស្សមានជំងឺដាបម្នាក់ ។ សិទ្ធិយ៉ាសម្លឹងប្អូនប្រុស ដោយមិនមាត់ ព្រោះនរះក៏ពិបាកចិត្តណាស់ដែរ ដែលស្រីពនិតាទៅណាបាត់ដោយគ្មានតម្រុយយ៉ាងនេះ ។ គុណាករទាញបារីមួយដើមអុជ បម្រុងជក់តាមទម្លាប់ដែលគេមានកង្វល់ ព្រោះសម្រាប់គេ គឺបារីនឹងជួយបន្ធូរចិត្តស្មុគ្រស្មាញបានមួយខណៈ ។ តែមិនដឹងជានឹកឃើញយ៉ាងម៉េច គុណាករញីបារីចោលក្នុងចានគោះបារី រួចគេបែរមកបងប្រុស ដោយនិយាយ :

-ខ្ញុំនឹងតាមរកនាង ។

-ឯងទៅរកនាងនៅទីណា ?

-ខ្ញុំមិនដឹងដែរ ។

-តាមពិត អ្នកដែលអន្ទះអន្ទែង គួរតែបង...ក្រែងឯងស្អប់ពនិតាអ្ហែះឥឡូវ...

គុណាករឆ្លើយកាត់សម្តីសិទ្ធិយ៉ា :

-ឥឡូវស្អប់ ឬស្រឡាញ់ បងគង់នឹងដឹងទេ ។

និយាយចប់ គុណាករដើរចេញវឹង ។ កំលោះកូនច្បងរបស់លោកស្រីម៉ាណេតតាមមើលដំណើរប្អូន ដោយមិនអស់ចិត្តពីអាកប្បកិរិយារបស់គុណាករទាំងសិទ្ធិយ៉ារអ៊ូផង :

-ម៉េចអីចេះគុណនេះ ។

យើងមកតាមដានពនិតាម្តង តើជាងពីរខែនេះ នាងមករស់ជាមួយមេត្រី ក្នុងស្ថានភាពបែបណាដែរ ? នុំះហ្ន៎ ! ពនិតាកំពុងក្អួតច្រងាប់ច្រងិលដោយមានមេត្រីកំពុងជួយរឹតខ្នងឱ្យនាង ។ ក្រោយពីបានធូរស្រាលពីការក្អួតបន្តិចមក មេត្រីគ្រាហ៍មិត្តរបស់នាង នាំមកកាន់ប៉ៅអី ដើម្បីពនិតាបានទម្រេតកាយយកកម្លាំង ។ យល់ថា មិត្តបានស្រួលបន្តិចហើយ មេត្រីវាចា :

-ពនិតា ! អ្នកណាជាឪក្មេងនេះ ហើយឯងខំបិទបាំងធ្វើអី ?

ពនិតាមើលមុខមេត្រី មើលរបៀបសុំទោសមិត្តដែលនាងមិនអាចនិយាយប្រាប់មេត្រីបាន ។ រួចពនិតាបិទភ្នែកសម្ងំមិនស្តី ។ នាងឈឺចាប់នាងមិនអាចនិយាយពីឈ្មោះមនុស្សចិត្តមារដែលបំផ្លាញនាង រហូតផ្តល់កំណើតទារកក្នុងផ្ទៃស្រី ប្រាប់មិត្តទេ ។ ព្រោះនាងមិនចង់រំលឹកពីបុរសជូជាតិនោះមិនចង់ឱ្យរឿងរ៉ាវរវាងនាងនិងគុណករ កាន់តែខូរខ្វាយផង ដ្បិតវាប៉ះពាល់កិត្តិយសមាតាចិញ្ចឹម ដែលពនិតាយល់ថា លោកស្រីម៉ាណេតស្រឡាញ់នាងដូចកូនចេញពីសាច់។ មិនឮមិត្តឆ្លើយ មេត្រីមិនព្រមបញ្ឈប់សំណួរទេ នាងសួរពនិតាម្តងទៀត :

-អ្នកណា ? គ្នាសួរឯងច្រើនដងហើយណ៎ា ។

-ខ្ញុំសូមប់ ខ្ញុំមិនចង់រំលឹកឈ្មោះគេទេ ឯងកុំសួរ ។" ពនិតាឆ្លើយទាំងបិទភ្នែក"

-ចុះសញ្ញាប័ត្រដុកទ័រ ឯងចង់ឱ្យវារលាយដូចជាសុបិននៅពេលភ្ញាក់ពីគេងអ្ហេះ ?

ពនិតាបើកភ្នែកភ្លាម នាងឆ្លើយទាំងមុខឈឺចាប់ :

-មិនមែនសុបិន វាមិនអាចរលាយដោយសារតែប្រុសជូជាតិនេះទេ ខ្ញុំនឹងយកកូនក្នុងពោះចេញ ។

-កុំអីពនិតា វាជាឈាមរបស់ឯងណ៎ា ។

-មិនមែន ! វាជាឈាមអាក្រក់ វាធ្វើឱ្យខ្ញុំឈឺចាប់ត្រឹមណា គេគង់នឹងឈឺចាប់ច្រើនលើសខ្ញុំ ។ ឯងចាំមើលចុះ ប្រុសម្នាក់នោះនឹងស្គាល់ខ្ញុំវិញ។ "ពនិតានិយាយទាំងខាំមាត់ដោយក្តីអួលផ្សាក្នុងចិត្ត"

-ឯងសាកឱ្យខ្ញុំទៅនិយាយនឹងគេម្តងអ្វេះ ដើម្បីឱ្យគេ...

-ឯងគិតថា គេជាអ្នកណា ? " ពនិតានិយាយកាត់សម្តីមេត្រី"

-ខ្ញុំគិតថា មានតែមនុស្សពីរនាក់ ដែលខ្ញុំសង្ស័យ ។

~៨~

ជាដំបូង មេត្រីបានស្ទាត់មកសិទ្ធិយ៉ាមុនគេ ព្រោះនាងតែងបានឃើញកំលោះកូនច្បងលោកស្រីម៉ាណេតតែងតែមកទទួល ឬជូនពនិតាមកសាលាជាញឹកញាប់ ។ ឥឡូវមេត្រីមកដល់ការិយាល័យនៃក្រុមហ៊ុនសំណង់របស់សិទ្ធិយ៉ាហើយ ។ បន្ទាប់ពីនាងបានឈ្លបសួរអ្នកប្រុសពីទំនាក់ទំនងរវាងគេ និងកូនស្រីរបស់អ្នកស្រីណារត្នទូវបញ្ហាខ្លះៗមក កំលោះសិទ្ធិយ៉ាងើបមុខពីសរសេរ មើលមកមេត្រីដោយការភ្ញាក់ផ្អើល គេបន្លឺសួរស្រី :

-ថាម៉េចពនិតាមានផ្ទៃពោះ មិនអាចទៅជាអ៊ីចឹងទេអ្នកនាងមេត្រី ?

-តែវាមានរឿងបែបហ្នឹងទៅហើយលោក គឺខ្ញុំជាអ្នកនាំនាងទៅឱ្យពេទ្យពិនិត្យ គឺនាងមានផ្ទៃពោះពីរខែណា៎ ។

-នាងមានផ្ទៃពោះពីរខែ !

-ពនិតាមានផ្ទៃពោះនឹងលោកមែនទេ ?

-នាងមានផ្ទៃពោះនឹងខ្ញុំ ?" មុខគេមានន័យបដិសេធសម្ដីមេត្រី"

-ឬក៏លោកចង់ដោះសារ ? លោកដឹងទេ ពនិតាមិនធ្លាប់ស្និទ្ធស្នាលជាមួយប្រុសណាទេ ក្រៅពីលោក និងប្អូនប្រុសលោកណា៎ ។

ប្រយោគមេត្រីមានន័យថា គុណករមានការទាក់ទងជាមួយពនិតា ធ្វើឱ្យសិទ្ធិយ៉ាភ្ញាក់ជាខ្លាំង គេងើបឈរដោយមិនដឹងខ្លួន បន្លឺវាចាសួរមេត្រីទាំងភ្លេចខ្លួន :

-ប្អូនប្រុសខ្ញុំ គុណាករហ្នឹងអ្ហេះដែលមានទំនាក់ទំនងជាមួយពនិតា ?

-ចាស ព្រោះទាំងលោក ទាំងប្អូនលោក ធ្លាប់ទៅរកនាងហ្នឹងហើយ ។

-គុណាករធ្លាប់ទៅរកពនិតាដែរ ?

ស្រដីតែប៉ុណ្ណេះ សិទ្ធិយ៉ាអង្គុយចុះវិញ មុខគេមានភាពសុបសៅ គេនឹកក្នុងចិត្តតែឯង : "គុណាករ ! ប្អូនបំផ្លាញចិត្តបង " ។ មេត្រីមិនយល់ពីមូលហេតុដែលនាំឱ្យមានការប្រែប្រួលដល់អារម្មណ៍សិទ្ធិយ៉ានាពេលនេះទេ នាងគិតតែបារម្ភតែពនិតា ទើបនាងមិនបានចាប់ភ្លឹកពីការប៉ះទង្គិចចិត្តមាណពដោយស្រីពោល :

-លោក ! បានសេចក្ដីថាម៉េច រឿងពនិតាមិត្តខ្ញុំ ?

-ខ្ញុំមិនធ្លាប់ទាក់ទងនាងទេ..." គេឆ្លើយទាំងល្ងើយក្នុងចិត្ត"

-អឺចឹង មានតែ...

សិទ្ធិយ៉ាស្រាប់តែមានកំហឹង គេគិតថា គ្មាននរណាដែលជាអ្នកបំពានរាងកាយស្រីកម្សត់ គឺប្រាកដជាគុណាករ ។ គេខឹងណាស់ ខឹងនឹងគុណាករធ្វើបាបស្រី ខឹងនឹងគុណាករបំផ្លាញទឹកចិត្តគេ ខឹងនឹងគុណាករមិនទទួលខុសត្រូវលើទង្វើដែលធ្វើបាបពនិតា ។ ដ្បិតគេមិនបានដឹងថា គុណាករក៏អន្ទះសារតាមរកពនិតានោះឡើយ ។ គិតហើយ សិទ្ធិយ៉ានិយាយខ្លាំងៗ :

-ត្រូវហើយ ប្រាកដជាគុណាករ ។

មុខមេត្រីខាំធ្មេញដោយការឈឺចាប់ជំនួសមិត្តរបស់នាង ស្រីវាចា :

-លោកគុណករចំជាមនុស្សសាហាវមែន ព្រាននារីចំតួ គេចាត់ទុកថាស្រីគ្មានបេះដូង គ្មានតម្លៃ គ្មានកិត្តិយសអ្វេះ ? យ៉ាងណាគេក៏គួរតែដឹងថាពនិតាជាស្រីសុភាព មានចរិយាល្អម្នាក់ ដែលគេមិនគួរប្រើវិធីបែបគ្មានខួរក្បាលបែបមនុស្សធុនអន់ មកធ្វើបាបនាងទេ ។ ខ្ញុំនឹងតាមសួរគេ ចាំមើល តើគេឆ្លើយយ៉ាងណា ?

-មិនបាច់ទេអ្នកនាង ។

-ហេតុអីមិនបាច់នោះលោក?

-សុំអ្នកនាងទុកនាទីនេះ ឱ្យខ្ញុំចុះ ។

-ទម្រាំលោកគិត វាហួសពេលហើយ ។

-ហេតុអីហួសពេល ?

-ព្រោះពនិតាកំពុងចង់យកកូនចេញ ។

ភ្ញាក់ដូចធ្លាក់ពីទីខ្ពស់ សិទ្ធិយ៉ាចាកចេញពីមេត្រី ដោយមិនបានលានាងមួយម៉ាត់ គេប្រញាប់ទៅរកប្អូនប្រុសចិត្តព្រានដើម្បីជម្រះបញ្ជីអាស្រូវដែលគុណករប្រព្រឹត្តចំពោះនារីស្លូតបូតម្នាក់ដូចជាពនិតា ។

មកដល់ផ្ទះ សិទ្ធិយ៉ាចេញពីរថយន្ត ដើរដូចព្យុះ ព្រោះទ្រូងគេពោរពេញដោយកំហឹង ។មិនបានប៉ុន្មានដង្ហើមផង កាយរបស់នរៈបានមកដល់ក្នុងផ្ទះភ្លាម ។សិទ្ធិយ៉ាស្ទុះទៅចាប់កអាវគុណករ ទាញក្របួចដើម្បីលើកគុណករឱ្យងើបពីទីអង្គុយលើកៅអីសាឡុង ជាការងាយស្រួលក្នុងការដែលគេមានជំហល្អ

ហើយគេយារដៃទះកំភ្លៀងប្អូនប្រុសកំហូចយ៉ាងខ្លាំង១ចំនួនពីរដៃផ្ទួន១ ជាមួយសំលេងគំហកយ៉ាងឮ១ទៅកាន់គុណាករ :

-ឯងនេះឆ្កួតហើយគុណា ។

គុណាករស្រឡាំងកាំង គេមិនដឹងថា ហេតុអីបងប្រុសមកវាយគេ ។ គេស្រែកសួរមកបងដោយសំឡេងខឹង :

-បងយ៉ា ! នេះបងកើតអីហ្នឹង បានជាមកវាយខ្ញុំ ?

សម្រែកខ្លាំងរបស់បងប្អូនទាំងទ្វេ ទាញជំហានរបស់លោកស្រីម៉ាណេតឱ្យដើររលះរលាំងមករកពួកគេ ទាំងគាត់ស្រែកឃាត់កូនទាំងពីរផង :

-ឈប់ ! ឈប់ ! មានរឿងអី ?

-ម៉ាក់សួរគេមើល គេមានរឿងអី ? " សិទ្ធិយ៉ាស្រដី ទាំងព្រលែង ដៃពីកអាវគុណាករ"

-មានរឿងអីហ្នាកកូនគុណា បានជាដល់ថ្នាក់វាយគ្នាបែកឈាមមាត់យ៉ាងហ្នឹង ?

-ខ្ញុំមិនដឹងដែរម៉ាក់ គ្រាន់តែជួបមុខខ្ញុំភ្លាម ក៏ស្រាប់តែដាល់ខ្ញុំ ដូចជាខ្ញុំហ្នឹងជាបាវខ្សាច់ ។

-ហ្នាក ! ម៉េចដល់ម្លឹងនោះកូនយ៉ា ?

សិទ្ធិយ៉ាមិនបានឆ្លើយសំណួរម្តាយទេ គេបែរមកគុណាករ គេសម្លុតកំលោះជើងល្អជាថ្មី :

-ឯងមិនដឹងមែនអ្ហេះ ?

-ខ្ញុំមិនដឹងថា បងកំពុងនិយាយរឿងអីទេ ។

-ចុះដែលពនិតាមានផ្ទៃពោះ ឯងចង់ថាមិនដឹងដែរអ្ហេះ ?

-ពនិតាមានផ្ទៃពោះ !

គុណាករ និងម្ដាយភ្ញាត់មាត់ព្រមគ្នា ដោយការភ្ញាក់ផ្អើល ។ រួចគុណាករទម្លាក់កាយអង្គុយប៉ុកលើកៅអី គេឈឺចាប់ គេអាណិតពនិតាដែលទទួលរងនូវទង្វើគេធ្ងន់ធ្ងរយ៉ាងនេះ ព្រោះយ៉ាងណា នាងជាស្រីក្រមុំ ម្ដេចអាចនឹងពពោះដោយគ្មានស្វាមីនោះ ដែលនោះជាបញ្ហាមិនល្អសម្រាប់កិត្តិយសនាងឡើយ តែចិត្តមួយធ្វើឱ្យគេត្រេកអរ ព្រោះគេមានកូនជាមួយនារីដែលគេស្រឡាញ់ពិត ។ ចុះពនិតាវិញ គុណាករមិនដឹងថា នាងគិតយ៉ាងណាពីរឿងកូនតើនាងសប្បាយ ឬនាងមិនពេញចិត្ត ? កូនពៅរបស់លោកស្រីម៉ាណេតមិនមានចម្លើយទេ ទើបគេស្រដីដោយអារម្មណ៍ច្របូកច្របល់ស្ទើរមិនមានពាក្យនិយាយមកកើត :

-បង...ខ្ញុំ...ខ្ញុំ...

-ខ្ញុំ...ខ្ញុំ...ចង់កែ ចង់គេចអ្ហេះ ? យ៉ាងម៉េចឯងចាត់ទុកពនិតាជាស្រីលេងសើចសម្រាប់ឯង ដែលឯងអាចទាត់ចោលអ្ហេះ ?

-ការពិតអ្ហេះគុណ ? " ម្ដាយសួរគុណាករ "

-ខ្ញុំ...ខ្ញុំ...

-ហ្នឹងហើយ ក៏ព្រោះតែឯងយល់ថា នាងជាផ្កាដុះចិញ្ចើមផ្លូវ ជាផ្កាព្រៃ ... ហ៊ឹះ ! ទើបឯងមិន..." សិទ្ធិយ៉ាខឹងរហូតនិយាយលេងចេញ"

-ប្រាប់ម្ដាយមក ឯងធ្វើបាបប្អូនមែនអ្ហេះ ?

-នាងមិនមែនប្អូនខ្ញុំទេម៉ាក់ ។

គុណករប្រកែកបែបនេះ ព្រោះតាំងពីគេជួបនាងភ្លាម គុណករបានចាត់ទុកថា នាងជាស្រីដែលបេះដូងគេត្រូវការ ដូចនេះនាងមិនអាចជាប្អូនស្រីរបស់គេបានទេ ។ តែលោកស្រីជាម្ដាយ បែរជាគិតថា គុណករមានចិត្តសាមាន្យ ដោយនរៈស្អប់ពនិតារហូតមិនអាចទទួលនាងជាប្អូនចិញ្ចឹមបាន ទើបគេធ្វើបាបនាង ។ លោកស្រីខឹងពេក ក៏ស្រែកគំហកដាក់គុណករ :

-អាក្រក់ ! ឈាមខ្មៅ !ឯងមិនសមជាកូនម៉ាក់សោះ ។

-ខ្ញុំមានសិទ្ធិយកនាងជាប្រពន្ធណាំម៉ាក់ មិនមែនប្អូនស្រីទេ ។ " គុណករបញ្ជាក់ប្រាប់ម្ដាយ "

-ហេតុអីឈាមអាក្រក់ មារចង្រៃអីមកនៅក្នុងចិត្តថ្លើមឯង ព្រោះយ៉ាងណា ឯងមិនគួរធ្វើបាបនាងទេ?

-អ្នកម៉ាក់ !

ដូចជាម្ដាយដែរ គុណកររន្ធត់ចិត្តអាណិតពនិតាណាស់ គេបន្លឺពាក្យហៅ "អ្នកម៉ាក់" រួចក៏អាក់វាចា ព្រោះអ្វីដែលលាក់កប់ក្នុងចិត្តគេ គឺគេចង់ប្រាប់ម្ដាយថា គេគ្មានផ្លូវជ្រើសរើស ទើបគេប្រើវិធីបែបនេះ ដើម្បីចងចិត្តនាង តែគេមិនអាចនិយាយចេញមកបាន ព្រោះយ៉ាងណា វិធីរបស់គេពិតជាព្រៃផ្សៃចំពោះពនិតាទៅហើយ ។លោកស្រីម៉ាណេតមិនដឹងជាស្ដាប់យល់សម្ដីកូនពៅ ឬ

អត់នោះឡើយ  តែគាត់នៅតែស្រងីដោយមុខឈឺចាប់ព្រោះការអាណិតពនិតាលាន់ចេញជាប្រយោគ :

-ពុទ្ធោ ! ពនិតាកូនម្ដាយ ម្ដាយដូចយកកូនមកដាក់នៅក្នុងមាត់ខ្លា ។

និយាយបានប៉ុណ្ណេះ លោកស្រីអង្គុយចុះលើកៅអី ដោយមុខស្រងូត ។ គុណាករលុតជង្គង់ចុះប្របជើងម្ដាយ បញ្ជាក់ពីការដឹងកំហុសរបស់គេ ។ លោកស្រីងាកមកសួរគុណាករដោយមុខមាំ តែបន្ទន់សំឡេងជាងមុន ព្រោះឃើញកូនប្រុសទទួលកំហុសយ៉ាងនេះ:

-ឥឡូវហ្នឹងគិតយ៉ាងម៉េចទៀត...ឯង...ឯងនេះ...បើមិនស្រឡាញ់ប្អូនទេ ចុះហេតុអីក៏ធ្វើបាបប្អូនយ៉ាងហ្នឹង ហ៊ឺះ !...ម៉ាក់ចង់តែសម្លាប់ឯងចោល ។

-ចុះឯងគិតយ៉ាងម៉េច ទទួលខ្លួនជាឪក្មេង ឬឱ្យពនិតាយកកូនចោល? " សិទ្ធិយ៉ាដែលស្ងាត់មាត់យូរហើយ ក៏សួរមកគុណាករ"

-នាងយកកូនចោល ! ទេ ខ្ញុំមិនព្រមទេ មិនឱ្យគេធ្វើបាបកូនខ្ញុំទេ ។

-កូនឯងៗអ្ហេះ ?ច្បាស់ហើយអី ? " សិទ្ធិយ៉ាសួរទាំងៗពេបមាត់ ព្រោះគេមិនជឿថា គុណាករងាយនឹងព្រមទទួលឱ្យមនុស្សស្រី និងកូន មកចងជើងគេមិនឱ្យគេបន្តធ្វើព្រាននារីបានដោយងាយនោះទេ"

គុណាករស្រាប់តែងើបពីទីលុតជង្គង់ គេនិយាយដោយមុខស្រងូត :

-បាទ ច្បាស់ហើយបងយ៉ា ច្បាស់ជាកូនខ្ញុំ ។ ខ្ញុំទៅតាមពនិតាហើយ ។

-ឯងប្រាកដថា នាងនឹងមកជាមួយឯងទេ ?" ម្ដាយសួរ"

-ខ្ញុំមិនដឹងដែរអ្នកម៉ាក់ ។ មិនដឹងចិត្តនាងយ៉ាងណាទេ ? " គុណាករ"

-បើមិនស្រឡាញ់គេ មិនបាច់ទៅតាមគេទេ ម៉ាក់នឹងឱ្យនាងទៅស្រុកវិញ ហើយម៉ាក់នឹងធ្វើអ្វីគ្រប់យ៉ាង ជាការប៉ះប៉ូវដល់នាង បើនាងត្រូវការ។ ព្រោះយ៉ាងណា ការមិនស្រឡាញ់ មិនមែនជាសុភមង្គលទេ ដូចនេះ ម៉ាក់មិនចង់ឱ្យឯង និងនាងរស់ជាមួយការឈឺចាប់នោះឡើយ ។

-មិនបានទេម៉ាក់ មិនមានការឈឺចាប់អ្វីទាំងអស់ នាងគឺជាប្រពន្ធខ្ញុំ ក្មេងនោះជាកូនខ្ញុំ ពួកគេត្រូវនៅជាមួយខ្ញុំ ។ចុះម៉ាក់មិនចង់បានចៅពទេអ្ហេះ ?

-ម៉ាក់ប្រាកដជាចង់បានចៅហើយ តែក្រែងនាងមិនព្រមមកណ៎ា ។

-អីចឹងឯងនៅធ្វើអី មិនទៅទៅ ! តិចហួសពេល ។ ណេះ! យកអាសយដ្ឋានរបស់អ្នកនាងមេត្រីទៅ "សិទ្ធិយ៉ានិយាយទាំងហុចក្រដាសអាសយដ្ឋានមេត្រីទៅឱ្យគុណករ "

គុណករទទួលអាសយដ្ឋានមេត្រីពីដៃបងប្រុស គេគោរពទឹកចិត្តបងលាយឡំការស្តុតចិត្តដោយអាណិតបង ដែលគេបានខ្វេះយកបេះដូងសិទ្ធិយ៉ា ។ គុណករសម្លឹងបងបន្តិច គេឃើញសិទ្ធិយ៉ាបែរមុខទៅម្ខាង គេចពីក្រសែភ្នែករបស់គេ គេដឹងថា បងប្រុសកំពុងឈឺផ្សាក្នុងចិត្ត ប៉ុន្តែស្នេហាមិនអាចរំលែកឱ្យអ្នកទីបីបានឡើយ ។ បន្ទាប់មក គេបែរមកម្តាយ ម្តាយគេគ្រវីក្បាលតិចៗ របៀបហួសចិត្ត ជាមួយមុខស្ងួតចែស ។ គុណករសំពះដាក់ដៃលើភ្លៅម្តាយ រួចគេងើបដើរចេញទៅ ។ គឺគេទៅរកពនិតា ។

លោកស្រីម៉ាណេតដកដង្ហើមធំមួយឃ្លូរ តាមសម្លឹងកូនពៅ រួចមុខដ៏ស្រពោនរបស់គាត់បែរមកសម្លឹងកូនច្បង... ពួកគេជាកូនរបស់គាត់ទាំងពីរនាក់

ពួកគេកំពុងគិតអ្វី គាត់ដឹងច្បាស់ណាស់ ប៉ុន្តែអ្វីទាំងអស់ វាហាក់ដូចជាមាន គំនូសជីវិតកំណត់មកទៅហើយសម្រាប់គេទាំងពីរនាក់ ។ គាត់លូកដៃមកចាប់ ដៃសិទ្ធិយ៉ាមកច្របាច់ស្រាលៗ ជាសញ្ញាឱ្យគេទប់ចិត្ត ទប់ការឈឺចាប់ ដែល គេត្រូវបាត់បង់ស្រីជាទីស្រឡាញ់ ។ បាតដៃដ៏កក់ក្តៅរបស់មាតា កាន់តែជំរុញ ក្តីឈឺចាប់ ក្តីអួលណែនកាន់តែខ្លាំងក្នុងទ្រូងកំលោះកូនច្បង ធ្វើឱ្យសិទ្ធិយ៉ាងាក មកស្រវាឱបម្តាយ ឧទានតែមួយម៉ាត់ :

-អ្នកម៉ាក់ !

-ម៉ាក់ដឹងចិត្តកូនហើយ កូនស្រឡាញ់នាង ។ កាត់ចិត្តចុះកូន នាងមិន មែនជាគូនឹងកូន ។

សិទ្ធិយ៉ាបិទភ្នែកមួយភ្លែតបន្ធូរដង្ហើមធំពីទ្រូង បន្ទាប់មក មុខដ៏ស្រងូត របស់គេប្រែជាលេចស្នាមញញឹម ដោយគេស្រដីថា :

-គុណ និងកូន គឺជាកូនរបស់អ្នកម៉ាក់ ។

ម្តាយញញឹម វាចា :

-កូនគួរឱ្យស្រឡាញ់ណាស់កូនយ៉ា តែកូនគុណធ្វើឱ្យម៉ាក់បារម្ភ មិនដឹង តើគេជួបអ្វីទៅនៅពេលនេះ បើពនិតាមិនមែនជាមនុស្សស្រី ដែលងាយនឹង ជឿនរណានោះទេ ។

-បាទ ម៉ាក់ ! តែយ៉ាងណាវាដៃដល់ជាងកូន ។ កូនជឿថា គេអាច ស្គាល់ពនិតាជាងយើងក៏មិនដឹងណាំម៉ាក់ ។

គុណាករចេញពីឡាន រត់យ៉ាងលឿនចូលទៅក្នុងផ្ទះមេត្រី ។ ស្នូរជើងរត់របស់មាណពមកដល់ជិតទ្វារ ភ្នែកគេឃើញមេត្រីចេញពីក្នុងផ្ទះ មករកគេដែរ ។ អ្នកទាំងពីរមកជួបគ្នានៅក្បែរមាត់ទ្វារ ។ គុណាករក្រឡេកឃើញមេត្រីបុរសស្ទុះទៅចាប់ដៃរបស់នាង សួរយ៉ាងញាប់មាត់ :

-អ្នកនាងមេត្រី ពនិតា...ពនិតា...នៅ...

មិនឱ្យគុណាករនិយាយចប់ប្រយោគទាន់ មេត្រីបន្លឺកាត់វាចាបុរស ទាំងមុខភិតភ័យ :

-លោកគុណាករ...ពនិតា...ពនិតា...

មេត្រីនិយាយមិនចេញ ហើយមុខនាងកាន់តែស្លេកស្លាំង ។ គុណាករសួរនាងដោយសំឡេងខ្លាំងៗ :

-ពនិតាកើតអី... កើតអី ?

-នាងទៅពេទ្យ...ទៅយកកូន ។

-យកកូន ! នៅឯណា ? អ្នកនាងជូនខ្ញុំទៅរកគេភ្លាម ។

-លោកមកតាមខ្ញុំមក ព្រោះខ្ញុំបម្រុងទៅរកគេដែរ ។

ទាំងពីរនាក់រត់ត្របាញ់ជើងទៅរករថយន្តរបស់គុណាករ ។ អ្នកប្រុសបញ្ជាយានតាមការបង្ហាញផ្លូវរបស់មេត្រី ។ រថយន្តគុណាករបើកមកដល់ផ្លូវមួយ ស្រាប់តែរថយន្តរបស់ម្លិះបើកមកពីផ្លូវមួយទៀត ហើយម្លិះបានក្រឡេកឃើញគុណាករនៅក្នុងយានជាមួយមេត្រី ។ នាងគិតថា មេត្រីជាស្រីថ្មីរបស់

គុណករ ហើយភ្លើងកំហឹងប្រចណ្ឌច្រាលពេញទ្រូងម្ទិះ ។ នាងបត់ឡានវ៉ារ បើកដេញតាមរថយន្តរបស់អ្នកប្រុស ។

មកដល់មុខគ្លីនិកពេទ្យឯកជនមួយកន្លែង មេត្រីបានប្រាប់ឱ្យគុណករ បញ្ឈប់យាន ដោយនាងស្រដី :

-លោកចូលទៅ ពនិតានៅខាងក្នុងនេះហើយ ហើយខ្ញុំទៅសាលា សុំច្បាប់ឱ្យពនិតាសិន ។

-បាទ អ្នកនាងឆាប់មកវិញណ៎ា ។

គុណករនិយាយទាំងបើកទ្វារឡានចេញបណ្ដើរ ឯមេត្រីម្ទីម្ទាយាត្រា មកកាន់ទីចង្កូតយានវិញ ។ នាងបញ្ឆាយានឱ្យទៅមុខ ។ គុណករដើរចូលទៅ ក្នុងមន្ទីរពេទ្យដោយជំហានដូចហោះ ។ ម្ទិះវិញ នាងឈប់ឡានពីចម្ងាយគ្លីនិក ប្រហែលហាហុកសិបម៉ែត្រ ភ្នែកនាងសម្លឹងទៅគុណករ ដែលចូលទៅក្នុងគ្លីនិក ជាមួយមុខជិតដោយកំហឹង ។

ក្រោយពីសួរបុគ្គលិកទំនាក់ទំនងភ្ញៀវរួចហើយ គុណករប្រញាប់ដើរ ទៅរកបន្ទប់សម្ភព ។ មកដល់មាត់ទ្វារបន្ទប់សម្ភព បុរសរុញទ្វារបន្ទប់ ទាំងគេ ស្ទុះចូលទៅខាងក្នុង ជាមួយសម្រែក :

-កុំ...កុំ...ពនិតា ។

គុណករស្ទុះទៅរកពនិតាដែលគេងលើគ្រែពេទ្យ ព្រោះពេទ្យបម្រុង នឹងចាត់ការយកទារកទៅហើយ គេលូកដៃចាប់ដៃនាង នរៈស្រដី :

-ហេតុអីអូនធ្វើយ៉ាងនេះ ?

-ហេតុអី ?ម៉េចលោកឯងមិនសួរខ្លួនឯង ឈាមចង្រៃខ្ញុំយកវាចេញ ។

-មិន...មិនបានទេ បង...

ពនិតាងាកមកគ្រូពេទ្យដែលឈរស្រឡាំងកាំងនៅក្បែរនោះ ដោយនាងនិយាយទៅកាន់ពេទ្យ :

-ត្រូវតែបាន អ្នកគ្រូពេទ្យចាត់ការចុះ ហើយដេញគេភ្លាមទៅ ។

គ្រូពេទ្យម្នាក់នេះមិនទាន់បាមាត់និយាយអ្វីផង ស្រាប់តែមានគ្រូពេទ្យម្នាក់ទៀតដើរចូលមក ហើយគ្រូពេទ្យថ្មីនេះ ដែលមិនដឹងរឿងហេតុកើតឡើងរវាងពនិតា និងគុណាករ ទើបនាងពេទ្យទីពីរពោលទៅកាន់គុណាករ :

-សូមលោកមេត្តាអញ្ជើញចេញ ។

-ខ្ញុំមិនចេញ ។ អ្នកគ្រូពេទ្យសាកមើល បើហ៊ានធ្វើអីកូនខ្ញុំ ខ្ញុំប្តឹងអ្នកគ្រូពេទ្យទាំងអស់គ្នាហ្នឹង ។ " គុណាករបែរមកពនិតា គេនិយាយដោយពាក្យទន់ភ្លន់ " ...ពនិតាអូន ! កូនយើងណា កុំធ្វើបាបវា ។

-មិនមែនកូនខ្ញុំ វាជាមារបំផ្លាញការសិក្សាខ្ញុំ វាចាំតែបំផ្លាញជីវិតខ្ញុំជារហូតមកតើ ។

-ពនិតា!បងទទួលខុសត្រូវគ្រប់យ៉ាង សុំតែម្យ៉ាង កុំបំផ្លាញកូនយើង។

ពនិតាឈឺចាប់ រហូតដល់ពេលនេះ គុណាករត្រូវការតែកូន នរៈមិនបានត្រូវការនាងទេ គេយកកល្យាណធ្វើជាឧបករណ៍សម្រាប់បម្រើអារម្មណ៍ពុះកញ្ជ្រោលដោយតណ្ហា ដោយគេមិនគិតពីកិត្តិយសស្រី មិនខ្វល់ពីអនាគតនាង

... មិនទទួលខុសត្រូវពីការបំផ្លាញក្តីបរិសុទ្ធរបស់ស្រីក្រមុំម្នាក់ ... ចុកចាប់ពេក ពនិតាស្រែកសួរគេ :

-ហើយចុះដែលលោកឯងបំផ្លាញក្តីសុខខ្ញុំនោះ ខ្ញុំទ្រាំទ្រវេទនាយ៉ាងណា លោកឯងដឹងទេ ? អនាគតខ្ញុំរលាយដោយសារលោកឯង ...លោកឯងជាបិសាច ឬ មនុស្ស ?

-ពុទ្ធោ ! ឱ្យបងសុំទោស បងសុំទោសទៅចុះ កំហុសទាំងអស់បងទទួល ?" ជាមួយសម្តី គុណករស្រវាឱបកាយស្រី "

-លែង...លែង !" ពនិតាបម្រះរើពីដៃបុរស"

-អភ័យទោសឱ្យបងផងណា ប្រពន្ធសំឡាញ់ ។ "គុណករឱបនាងកាន់តែតឹង"

-គ្មានផ្លូវទេ...ខ្ញុំស៊ូស្លាប់ប្រសើរជាងរស់ឃើញមុខលោកឯង លែង...ឮទេ ...លែង ។

ពនិតារើទាល់តែរួចពីដៃគុណករ នាងស្ទុះរត់មកក្រៅបន្ទប់ គុណកររត់ដេញតាមនាងពីក្រោយ ។ ធីតារត់សំដៅទៅរកផ្លូវ ហើយនរៈនៅតែរត់ដេញតាមនាងពីក្រោយ ។ បុរសរត់ផង ស្រែកហៅនាងផង :

-ពនិតាឈប់សិនអូន ។

ម្លិះដែលសំកុកនៅក្នុងឡានចាំគុណករ មើលមកឃើញសង្សារសំណព្វរត់ដេញតាមនារីម្នាក់ផ្សេងពីមេត្រី ម្លិះក៏បញ្ឆេះយានលាន់ម៉ាស៊ីនង៉ោង ជើងស្រីជាន់ហ្គាយ៉ាងកប់ បណ្តាលឱ្យរថយន្តបោលទៅរកពនិតាដែលកំពុងនៅតាម

ផ្លូវ ។ គុណករវិញ គេរត់មកជិតទាន់ពនិតា នៅចម្ងាយប្រហែលជាពីរម៉ែត្រ ដោយគេស្រែកហៅនាងពីក្រោយ :

-ពនិតាស្ដាប់បងសិន ។

ពនិតាងាកមកមើលបុរស នាងលើកដៃចង្អុលមករកគេ ទាំងស្រែកដោយមុខមាំ :

-ឈប់ ! ឈប់ត្រង់ហ្នឹងហើយ ។

គុណករឈប់ង៉ក់ គេសម្លឹងមុខនាង វាចា :

-ពនិតាទៅផ្ទះវិញអូន ។

-មិនទៅ ! លោកឯងកុំសង្ឃឹមថា មានថ្ងៃនឹងនាំខ្ញុំទៅវិញបាននោះ មនុស្សសាហាវដូចលោកឯងនឹងស្គាល់ការឈឺចាប់ តើវាមានរសជាតិល្វីង ចត់យ៉ាងណា ?

-ពនិតាកុំណាំអូន កុំធ្វើអីកូនយើង បងស្រឡាញ់កូន ។

ពនិតាឈឺចាប់ណាស់ នាងសម្លឹងមុខគេ រួចសើចដូចមនុស្សឆ្កួត នាងមិនជឿសម្ដីមនុស្សដូចជាគុណករទេ ។ យល់អាការៈឈឺចាប់របស់នាង គុណករមុខស្រពោន ពោល :

-មែនណាំអូន ! ពិតណាំ បងអង្វរ ។

-បាន ! ហេតុអីមិនបាន កាលបើលោកស្រឡាញ់កូន លោកត្រូវការខ្ញុំបែបដូចលោកធ្វើមកលើខ្ញុំនេះ... លោកចាំយកសពខ្ញុំក៏បាន ... លោក...

ស្រាប់តែ គុណករក្រឡេកឃើញរថយន្តរបស់ម្ហិះបោលសំដៅមករក ពនិតា គុណករស្រវាចាប់ឱបពនិតាទាញឱ្យផុតមកឆ្ងាយពីទិសដៅ ដែលយាន របស់ម្ហិះតម្រង់មករកនាង ។ រថយន្តម្ហិះក្នុងល្បឿនគួរឱ្យខ្លាច បោលទៅមុខ ដោយមិនអាចទប់បាន រថយន្តម្ហិះក៏ស្ទុះសំដៅទៅបុកដើមឈើមួយដើមធំ ដែលនៅចិញ្ចើមផ្លូវ ។ ម្ហិះដាច់ខ្យល់ស្លាប់នៅក្នុងរថយន្ត ។ គុណករឯណេះ ដួលទៅដីទាំងដៃនៅឱបកាយពនិតាជាប់ ។ ដឹងថាផុតពីស្លាប់ គុណករដែល ដៃនៅតែឱបកាយស្រីជាប់នោះ គេបានបន្លឺក្បែរត្រចៀកនាងដោយញាប់ញ័រ :

-អស់ស្លាប់ហើយអូន ហ៊ឺ !...ម្ហិះមិនគួរសោះ នាងអាក្រក់យ៉ាងនេះ ។

មុននេះ ដោយសារពនិតាខ្លាចសន្ទុះរថយន្តរបស់ម្ហិះ ដែលបោលមក រកបុកនាងនោះ ស្រីបានបិទភ្នែក លុះឮសម្តីគុណករក្បែរត្រចៀកនាង លាន់ មកស្រាលៗ មាណវីហាក់ស្វាងពីការភ័យខ្លាច នាងបើកភ្នែកឡើង ក៏ស្រាប់តែ ឃើញដងខ្លួនស្រីឋិតនៅក្នុងការក្រសោបរបស់អ្នកប្រុស ធីតាខ្មាសណាស់ ស្រី បម្រះទាល់តែរួចពីដៃគុណករ ។ ដោយលាន់ស្នូរដង្ហើមធំមួយឃូរ :

-ហ៊ឺ !

គុណកររវល់តែបារម្ភពីសុវត្ថិភាពនាង គេមិនបានដឹងថា ធីតានឹង រើបម្រះឱ្យផុតពីក្នុងរង្វង់ដៃគេទេ ទើបគេមិនបានប្រុងប្រៀប បណ្តាលឱ្យ ប្រាណស្រី ក៏របូតពីហត្ថាគេ ។ និមលវិញ បានរួចពីដៃកំលោះ នាងរត់ទៅមុខ បុរសរត់តាមស្រីស្រស់ ទាំងគេស្រែកហៅកល្យាណ :

-ពនិតា!

ពនិតាមិនបានឈប់តាមការហៅរបស់ប្រុសថ្លៃ នាងរត់ទៅមុខរហូត រត់បានបានបន្តិច នេត្រាស្រីក្រឡេកឃើញមេត្រីបើកឡានមកឈប់ក្បែរស្រី ។ ពនិតាក្រឡេកឃើញមិត្តរបស់នាងជាអ្នកបញ្ជាយាន ស្រីស្ទុះមកបើកទ្វារយាន នាងចូលអង្គុយទន្ទឹមមេត្រី ទាំងស្រដី :

-ទៅមុខភ្លាមឡើងមេត្រី ។

-ចុះលោកគុណាករ ។

-កុំរវល់ជាមួយគេ ។ ឯងបើកឡានទៅមុខទៅ ។

មេត្រីស្គាល់ចិត្តពនិតាយ៉ាងច្បាស់ នាងមិនអាចអែអង់បាន ។ រថយន្ត លូនទៅមុខក្រោមការបញ្ជារបស់មេត្រី ទាំងស្រីលួចមើលទៅគុណាករ ដែល ឈរមុខស្លូត នៅលើចិញ្ចើមផ្លូវ សម្លឹងមកពនិតា ។

-៩-

ពេលវេលាបានកន្លងទៅ ចាប់តាំងពីថ្ងៃដែលពនិតាត្រូវបានម្ចិះបើករថយន្តបម្រុងនឹងបុក មកដល់ពេលនេះ មានរយៈពេលប្រហែលជាជាងមួយខែហើយ ។ គ្រួសារលោកស្រីម៉ាណេតទាំងអស់គ្នា គ្មាននរណាដឹងថា ពនិតាទៅរស់នៅទីណាទេ ។ ទាំងគុណាករក៏ដូចជាសិទ្ធិយ៉ា ព្រមទាំងអ្នកស្រីម៉ាណេតសុទ្ធតែបានស្វះស្វែងដើររកពនិតា ដោយពួកគេទៅរកនាងនៅឯផ្ទះមេត្រី នៅសាលារៀនរបស់នាង នៅផ្ទះរបស់អ្នកម្ដាយនាងនៅឯខេត្តដែរ ។ តែដោយសារពនិតាមិនបានទៅរស់ជាមួយមេត្រី មិនបានទៅសាលរៀន មិនបានទៅរស់ជាមួយម្ដាយនៅឯខេត្ត ទើបពួកគេមិនបានទទួលដំណឹងពីស្រស់ស្រី ។ ឯគុណាករវិញ គេឈឺចាប់ គេខ្វាយខ្វល់ណាស់ គេអស់តម្រិះនឹងដើររកធីតា គេមិនដឹងថា ត្រូវទៅរកឆោមល្អនៅទីណា។ មាណពកើតទុក្ខ មួហ្មង នឹកស្រី បារម្ភពីកូនក្នុងផ្ទៃធីតា ព្រួយខ្លាចកល្យាណគិតខ្លី ហើយស្រីនឹងធ្វើបែបណាទៅលើទារកក្នុងពោះ ។ ក្រៅពីពេលដើររកពនិតា ភាគច្រើន គុណាករមិនសូវដើរទៅទីណា ក្រៅពីសំងំនៅក្នុងបន្ទប់ ដោយគេអង្គុយសម្លឹងរូបថតពនិតា ។ យូរៗម្ដង គេឆ្លៀតទៅជួបរិនដា តែគេមិនដែលទៅគេងនៅទីនោះទេ ។

សិទ្ធិយ៉ាបារម្ភពីសុខទុក្ខរបស់ពនិតាជាខ្លាំង គេតែងតែស្ទាក់ទៅជួបមេត្រី ដើម្បីសុំបសួរដំណឹងពីពនិតា ។ តែមួយរយៈពេលនេះ កំលោះកូនច្បងរបស់លោកស្រីម៉ាណេតមិនបានទទួលលទ្ធផលអ្វី ពីនារីដែលគេធ្លាប់លួចប៉ង

ស្នេហ៍នោះឡើយ ។ ការចុះឡើងទំនាក់ទំនងជាមួយមេត្រី សិទ្ធិយ៉ាមិលឃើញពីប្រការប្រពៃរបស់ស្រីមេត្រី ។ អ្វីដែលជាទឹកចិត្តល្អ អ្វីជាទង្វើគួរឱ្យសរសើររបស់មេត្រី វាក្លាយជាទម្ងន់ដែលផ្ទុកបេះដូងកំលោះខកស្នេហ៍ ឱ្យបែរមកពិចារណាពីធីតាខ្លះៗ ។ ប៉ុន្តែនរៈមិនទាន់បានបង្ហើបពីសេចក្តីត្រូវការរបស់ដួងចិត្តប្រាប់នាងទេ គេកំពុងស្ទាបស្ទង់ចិត្តស្រី ។ ស្រាប់តែថ្ងៃមួយ សិទ្ធិយ៉ាទទួលទូរសព្ទពីមេត្រី ដោយណាត់គេឱ្យទៅជួបនាងនៅកន្លែងមួយ ។ បេះដូងសិទ្ធិយ៉ាត្រេកអរ គេគិតថា ពេលជួបមេត្រី គេអាចបានឃើញភក្ត្រស្រីដែលចិត្តគេកំពុងជិតស្នាមិរះគិត ... ជួបមេត្រី គេអាចនឹងដឹងពីដំណឹងពនិតា...

ម៉ោងពេលកំណត់បានមកដល់ សិទ្ធិយ៉ា និងមេត្រីបានមកជួបគ្នា នៅមាត់ស្ទឹងកន្ទួត ។ ជាមួយដំណើរទឹមស្នាគ្នាតាមបណ្តោយដងស្ទឹង មេត្រីហុចសំបុត្រមួយមកឱ្យសិទ្ធិយ៉ា ទាំងស្រីវាចា :

-នេះសំបុត្រពនិតា ។ វាផ្ញើជូនអ្នកម៉ាក់លោក ។

-ពនិតាទៅខេត្តពីអង្កាល់ ? បើប៉ុន្មានថ្ងៃមុន ខ្ញុំ និងម៉ាក់បានទៅរកនាងដែរ តែម្តាយនាងប្រាប់ថា នាងមិនបានទៅទីនោះទេ ។

-គេទើបតែទៅពីម្សិល ។

-ចុះរយៈពេលកន្លងមកនាងនៅទីណា ?

-គេរស់នៅក្នុងផ្ទះជួលមួយ ដោយគេប្រាប់ខ្ញុំមិនឱ្យជម្រាបគ្រួសារលោក ។ ខ្ញុំយល់ចិត្តមនុស្សទាំងអស់ក្នុងគ្រួសារលោក តែខ្ញុំក៏យល់ចិត្ត

ពនិតាដែរ ព្រោះអ្វីដែលជាទង្វើរបស់លោកគុណករធ្វើបាបមកលើមិត្តខ្ញុំ វាធ្ងន់ធ្ងរណាស់ ហើយពនិតាក៏មិនទាន់បាត់ខឹងចំពោះទង្វើលោកគុណករនៅឡើយ ។

-គុណករម្រោលដូចដរីចុះប្រេង ពនិតាខឹងនឹងវាយ៉ាងនេះ ខ្ញុំមិនបន្ទោសនាងទេ ។

-នឹកដល់រឿងបន្ទោស ... ខ្ញុំសុំទោសលោកផង ដែលកាលពីមុន ខ្ញុំធ្លាប់បានបន្ទោសលោកខុសពីការពិត ។

សិទ្ធិយ៉ាសើចតិចៗនៅដើមក គេសម្លឹងមុខនាង ហើយគេក៏នឹកដល់គ្រានោះ ដោយគេមានអាការៈហួសចិត្តចំពោះការប្រព្រឹត្តរបស់នាងពីគ្រាមុនមកលើរូបគេ ។ គេសម្លឹងភក្ត្រអៀនអន់របស់ស្រីដែលរំលឹកដល់កំហុសនាងនាគ្រានោះ ទើបសិទ្ធិយ៉ានិយាយទាំងភ្ញាប់ស្នាមញញឹមៈ

-នាងជាមិត្តល្អ ខ្ញុំមិនដែលនឹកខឹងនឹងនាងទេ ។ តែនឹកដល់កាលណោះ " គេសើចញឹមៗ មើលមុខនាងមិនព្រិច " ... មិនដឹងនាងនឹកឃើញយ៉ាងណាបានជាទៅរករឿងខ្ញុំ ទាល់តែជាប់ចំណងខ្ញុំវិញយ៉ាងនេះ ។

-ជាប់ចំណងលោក ? ជាប់យ៉ាងម៉េច ? " មេត្រីសួរទាំងធ្វើមុខឡេងឡង់ "

សិទ្ធិយ៉ាបែរពីមើលមុខនាង រួចគេសម្លឹងទៅជើងមេឃ បន្លឺដោយភក្ត្រស្រងូតបន្តិច :

-បន្តិចទៀតខ្ញុំនឹងប្រាប់នាង តែឥឡូវនេះខ្ញុំនិយាយរឿងមួយប្រាប់នាងសិនចុះ តើនាងអាចស្តាប់បានទេ ។

-ចាស មិនមានរំខានអ្វីលោក ខ្ញុំចាំតែស្តាប់តើ ។

សិទ្ធិយ៉ាដើរទៅមុខបណ្តើរ និយាយបណ្តើរ :

-ខ្ញុំអាយុជិតសាមសិបឆ្នាំហើយ ពីមុនមកខ្ញុំមិនដែលនឹកនាដល់រឿងស្នេហាទេ តែឆ្នាំនេះចិត្តខ្ញុំប្លែក ... ជួបស្នេហ៍ទីមួយ ជួបរឿងខកចិត្ត ឥឡូវស្នេហ៍ទីពីរ ខ្ញុំប្រុងនឹងបង្កើតវា ប៉ុន្តែប្រសិនជាខុសបំណងទៀតនោះ ខ្ញុំបែបស្អាលាហើយស្នេហា ។

មេត្រីដើរបណ្តើរ នាងសម្លឹងទៅជើងមេឃបណ្តើរ ដោយវាចាមួយៗ :

-មិនដឹងហេតុអី លោកឆាប់មានអារម្មណ៍ភ័យខ្លាចយ៉ាងនេះ ? បើរូបលោកមានទ្រព្យស្តុកស្តម្ភ មានតិរិះវិជ្ជាខ្ពង់ខ្ពស់អីចឹងនោះ ។

សិទ្ធិយ៉ាងាកមកញញឹមមើលមុខនាង :

-នាងយល់ថា អីចឹងអ្ហេះ ?

មេត្រីងក់ក្បាល មុខនាងញញឹម រួចស្រីបែរមកសម្លឹងទៅជើងមេឃវិញ ។ សិទ្ធិយ៉ាមើលនាងមិនដាក់ភ្នែក គេលូកដៃមកចាប់ដៃមេត្រី ស្រដីទាំងញញឹម ដោយបេះដូងលោតក្តុកក្តាក់ក្នុងទ្រូង :

-ឥឡូវអូនឆ្លើយមក បើបងថា បងស្រឡាញ់អូន អូនឆ្លើយថាម៉េច ?

មេត្រីថយក្រោយបន្តិច ដកដៃចេញពីដៃសិទ្ធិយ៉ា នាងរំភើប នាងត្រូវការគេ តែនាងជាស្រី ... ជាមួយស្នេហា ធីតាក៏អៀនខ្មាស ទើបស្រីសួរអ្នកប្រុស ទាំងបបូរមាត់ញ័រ :

-លោកយ៉ា ! លោកនិយាយថាម៉េច ?

មុខសិទ្ធិយ៉ានៅតែញញឹម នៅតែសម្លឹងស្រី គេស្រដី :

-នេះជាភាសាស្នេហា មានតែនៅមុខមនុស្សស្រីដែលគេស្រឡាញ់ទេ ទើបគេនិយាយពាក្យហ្នឹងឱ្យអូនស្តាប់ ។

មេត្រីឱនមុខ ថ្ពាល់ស្រីក្រហមថ្លា ចាំងសម្រស់ស្រស់ស្អាតដល់ភ្នែកសិទ្ធិយ៉ា ។ បន្ទាប់មក តូចតន់បែរមុខទៅម្ខាង និយាយតិចៗ :

-តែ...ខ្ញុំ...អត់ដែលគិតរឿងហ្នឹងផង ។

-អូនអត់ដែលគិត តែអូនយកសម្ផស្សអូនទៅចងចិត្តបងឱ្យជាប់ជំពាក់នោះអី ។ ឥឡូវបងសុំដាក់ចំណងចិត្តឱ្យអូនវិញ ព្រោះនៅមិននៅ អូនទៅរករឿងបងធ្វើអី ?

ស្នាមសម្លក់ក្ដាញ់លាយឡំពន្លឺស្នេហ៍ ជះចេញពីនេត្រាថ្លាយង់របស់មេត្រី ... បុរសលួចញញឹមក្នុងចិត្ត គេចាប់ម្រាមដៃកល្យាណមកក្រសោប មេត្រីមិនដកដៃបាត្តា អ្នកប្រុសលើកម្រាមដូចបន្លាក្រូចរបស់នោមស្រស់មកជម្ពិតថ្នមៗ ... រួចសំណើចយល់ចិត្តបានផ្ទុះឡើងពីប្រអប់មាត់ពួកគេទាំងពីរ ជាមួយស្នូរជើងរត់ប្រដេញគ្នាតាមមាត់ស្ទឹង ។

..................................................................................................

..................................................................................................

កំលោះគុណករអង្គុយលើវាលស្មៅមួយ ផ្ដោតនេត្រាសម្លឹងពពក ដែលរសាត់ក្នុងលំហអាកាស ។ វិនដាមុខស្លូត សម្លឹងមុខអ្នកប្រុស ដោយក្រសៃភ្នែកក្រៀមក្រំ នាងបន្លឺតិចៗស្ទើរមិនឮសំឡេង :

-ញ៉ាំបារីទេបង ?

គុណាករគ្រវីក្បាល វិនដាយកបារីមកជក់ខ្លួនឯង ។ ផ្សែងបារីហើរចេញពីមាត់វិនដា ហោះកាត់មុខគុណាករដែលកំពុងចោលនេត្រាគយគន់ដុំពពក អ្នកប្រុសងាកមុខយឺតៗមកសម្លឹងវិនដា ពោលវាចាដោយភក្ត្រស្រពោន :

-អូនមិនដែលញ៉ាំបារីទេណា ? ចុះថ្ងៃនេះម៉េចក៏អូនខ្វាយខ្វល់ម្ល៉េះ ។

វិនដាដកបារីចេញពីមាត់ នាងញញឹមស្ងួតវាចា :

-អូនបានគិតទុកជាយូរមកហើយ គង់មានថ្ងៃណាមួយ បងនឹងឈប់ស្រឡាញ់អូនដូចស្រីដទៃទៀត តែអូនមិនគិតថា ថ្ងៃនោះមកដល់លឿនពេកយ៉ាងនេះទេ ។

និយាយចប់ វិនដាយកបារីមកបឺតបង្ហុយផ្សែងជាថ្មី ... នារីទាន់សម័យដូចជាវិនដា ដោយពីមុននាងមិនដែលគិតថា រឿងស្នេហាវាជាបញ្ហាឈឺចាប់បែបនេះទេនោះ ព្រោះនាងគិតថា ស្នេហាជាតម្រូវការរបស់មនុស្ស មិនមែនជាអារម្មណ៍ពិតអ្វីទេ វាគ្រាន់តែជាអារម្មណ៍មួយរឹបដែលមនុស្សត្រេកត្រអាលហើយមនុស្សមានសិទ្ធិផ្លាស់ប្តូរស្នេហាតាមការត្រូវការរបស់ជីវិត ។ លុះវេលាដែលនាងសេពគប់ជាមួយគុណាករ នាងបែរជាស្គាល់ស្នេហាពិតមួយ ហើយនាងស្គាល់រសជាតិខ្លោចផ្សានៃការបាត់បង់ស្នេហាពិតនោះដែរ ។ តែសម្រាប់វិនដានាងហ៊ានធ្វើអ្វីគ្រប់យ៉ាងដើម្បីស្នេហាទៅវិញ នាងហ៊ានលះបង់ក្តីសុខផ្ទាល់ខ្លួនដើម្បីមនុស្សជាទីស្រឡាញ់ នាងយល់ថា ស្នេហាមិនមែនត្រូវតែបង្ខំភាគីម្ខាងទៀត ឱ្យគេមករួមរស់ជាមួយខ្លួនដោយគេមិនយល់ព្រមនោះឡើយ មានន័យ

ថា ស្នេហាពិតអាចជាការលះបង់មួយដ៏ធំ ។ គុណាករយល់ចិត្តវិនដាច្បាស់ នរះដកដង្ហើមធំ គេច្របាច់ដៃវិនដាស្រាល១ បន្លឺ :

-វិនដា ! បងតូចចិត្តណាស់ ដែលបងជាមូលហេតុ...

ទឹកភ្នែកវិនដាស្រក់ចុះ តែមាត់នាងញញឹម វាចាកាត់សម្ដីបុរស :

-ដើម្បីសេចក្ដីសុខរបស់បង អូននឹងលះបង់អ្វី១ទាំងអស់ ហើយពាក្យ នេះអូនធ្លាប់និយាយប្រាប់បងហើយតើ ។ យ៉ាងណាអូន គឺមិនអីទេ។

គុណាករទាញដៃនាងមកឱបផ្អប់ទ្រូងគេ :

-វិនដា អូនល្អនឹងបងពេក តែបងដូចជាទទួលយកអំពើល្អរបស់អូន មិនបានសោះទៅវិញ ។ បងមិនយល់ចិត្តខ្លួនឯង ហេតុអីមិនបញ្ឈប់ការ ស្រឡាញ់ត្រឹមអូន ?

-កុំបន្ទោសខ្លួនឯងណាំបង ព្រោះស្នេហាពិបាកកំណត់អត្ថន័យណាស់ មិនដឹងហេតុអីស្រឡាញ់ ? ហេតុអីមិនអាចទទួលបាន ? ... អូនយល់ណាំបង បងទៅតាមរកពនិតាចុះ នាងជាស្រីគួរឱ្យអាណិតជាងអ្នកណាទាំងអស់ បើអ្វី ដែលបងធ្វើទៅលើនាង វាធ្ងន់ធ្ងរជាងដែលបងធ្វើមកលើអូន និងម្ចិះ ដ្បិត យ៉ាងណាអូន និងម្លិះសុទ្ធតែបានព្រមព្រៀងជាមួយបង ។ ចំណែកពនិតា នាង មិនមែនដូចពួកអូនទេ ។

រំភើបចំពោះទឹកចិត្តរបស់វិនដា គុណាករទាញនាងមកឱប គេបន្លឺ បានតែឈ្មោះស្រី :

-វិនដា !

ទឹកភ្នែកស្រឡាញ់ហូរពីនេត្រាទាំងគូរបស់វិនដា ។ គុណាករលើកដៃជូតទឹកនេត្រាឱ្យស្រី ស្រដីដោយមុខជូរចត់ :

-បងព្រួយពីអូនណាំវិនដា ។

-អូនមិនអីទេ បងកុំព្រួយ អូនមិនគិតខ្លី១ដូចជាម្ទិះឡើយ ។

គេបន្ទរដង្ហើមធំមួយឃ្លូរ គុណាករសម្លឹងមុខនាងមិនព្រិច មាណពសួរ :

-មែនអេ្ហះ អូនមិនអីមែនអេ្ហះ ?

វិនដាងក់ក្បាល ទាំងទឹកភ្នែករហាម នាងឆ្លើយ :

-ចាស ស្នេហាក៏មានអត្ថន័យមួយបែបទៀត ក្នុងចំណោមអត្ថន័យជាច្រើនអំពីវាណាំបង នោះគឺស្នេហាជាការយល់ព្រមពីមនុស្សពីរនាក់ ហើយបើម្នាក់លែងទទួលបាន ឯម្នាក់ទៀតព្យាយាមដណ្តើមយក ក៏ឥតន័យដែរ បើមិនដូច្នេះទេ លទ្ធផលមានតែទឹកភ្នែកទេបង ។ ម្ទិះនាងបានគិតខុសទៅហើយ តែអូនមិនមែនយ៉ាងនោះទេបង ។ ណ្ហើយ ! បងទៅចុះ ។

គុណាករនៅតែឱបវិនដា គេមិនឆ្លើយអ្វីមួយម៉ាត់ ។ វិនដាចន្ទ្រើតជើងដើម្បីឱ្យកម្ពស់នាងអាចធ្វើឱ្យនាងអាចលោទៅឱ្យបដាក់ត្រចៀកគុណាករ ។វាំចាខ្សាវ១លាន់ពីបបូរមាត់ស្រី ជាមួយទឹកភ្នែកធិតាស្រក់លើថ្ពាល់គុណាករ :

-បងទៅរកពនិតាទៅបង ។ ទៅចុះបង ។

គុណាករទាញមុខវិនដាឱ្យខិតឆ្ងាយពីមុខគេបន្តិច ដើម្បីគេអាចសម្លឹងមុខនាងបានចំ ។ គេស្រដីស្ទើរមិនចេញសំឡេង :

-វិនដា ! បងអរគុណអូន ។

ស្នាមញញឹមលេចលើបបូរមាត់វិនដា ជាមួយទឹកភ្នែកហូរស្រក់មក ។ សន្សឹម១ គុណាករព្រលែងដៃពីកាយនាង រួចគេបែរខ្នងបោះជំហានទៅមុខ ។ វិនដាផ្អែកខ្នងទៅនឹងដើមឈើដែលនៅក្បែរខ្លួននាង សំឡេងខ្សឹកខ្សួល ៉ ទ់មក កំដរបេះដូងប្រេះស្រាំ ។ នាងឱនមុខយំ នាងមិនហ៊ានសម្លឹងខ្នងបុរសទេ គុណាករវិញក៏មិនហ៊ានងាកមកមើលវិនដាដែរ ។

.................................................................................................

.................................................................................................

ឡានមួយបានមកឈប់នៅពីមុខផ្ទះក្បឿងមួយខ្នង ដែលមានរបងដើមអំពិលកាត់តម្រឹមយ៉ាងស្អាតព័ទ្ធជុំវិញ ។ ធ្លាផ្ទះពោរពេញដោយម្លប់ត្រឈឹងត្រឈៃនៃដំណាំហូបផ្លែ ។ ក្នុងបរិវេណធ្លាផ្ទះមិនមានស្មៅដុះ ឬស្លឹកឈើជ្រុះរាយប៉ាយនោះឡើយ ។គុណាករចុះពីរថយន្ត ដើរទៅរកគេហដ្ឋាននេះ ។ អាពាលដេកនៅក្រោមផ្ទះ វាក៏ស្ទុះងើបហើយព្រុស ព្រោះវាឃើញភ្ញៀវដើរមករកវា ។ គុណាករឈរស្ញៀម ស្រែកទៅកាន់ឆ្កែ :

-កុំព្រុសអី ក្មាមកល្អជាទេ ។

ឆ្កែនៅតែព្រុស តែភ្លាមនោះសំឡេងស្រីចំណាស់ម្នាក់លាន់ឡើង :

-ឈប់ព្រុសអាពាល ។

ភ្នែកគុណាករសម្លឹងទៅកាន់ប្រភពសំឡេង គេឃើញអ្នកស្រីណារត្នដើរចេញពីក្នុងផ្ទះ ដោយចុះជណ្តើរ រួចដើរតម្រង់មករកទ្វាររបង ។ គុណាករលើកដៃសំពះគាត់ វាចា :

-ខ្ញុំជម្រាបសួរអ្នកម៉ែ ។ ខ្ញុំជាគុណាករ ។

-គុណាករ ! លោកមករកអី ?

-ខ្ញុំសុំទោស ... ខ្ញុំមករកពនិតា ។

អ្នកស្រីណារត្នញញឹមបែបចំអកលាយឡំដោយការឈឺចាប់ ពោល :

-មករកនាងធ្វើអី ? កូនស្រីខ្ញុំ វាជាមនុស្សល្ងង់ វាតាមមិនទាន់មនុស្សឆ្លាតដូចជាលោកទេ ។ នុ៎ះ ផ្លូវ ! លោកទៅវិញទៅ ។ យ៉ាងណាក៏ខ្ញុំមិនបណ្ដោយឱ្យកូនស្រីខ្ញុំ ទៅនៅក្នុងដៃប្រុសចិត្តមារដូចជាលោកទៀតទេ ។

-តែខ្ញុំ...

អ្នកមីងស្រែកកាត់សម្ដីគុណាករមិនឱ្យគេបន្តវាចា :

-គ្មានតែ គ្មានអីទេ លោកទៅវិញចុះ ពនិតាមិនចង់ឃើញមុខលោកទេ

គុណាករស្រាប់តែស្រែកឮៗ ដោយគេមានបំណងចង់ឱ្យសំឡេងរបស់គេ នឹងលាន់ឮដល់ត្រចៀកពនិតា ព្រោះគេគិតថា នាងអាចនឹងពួនសំងំលាក់ខ្លួននៅក្នុងផ្ទះ ដោយស្រីគេចមុខមិនមកជួបគេ :

-តែខ្ញុំត្រូវការកូនខ្ញុំ ។ ខ្ញុំស្រឡាញ់កូនខ្ញុំ ។

សំឡេងពនិតាស្រែកតបមកកាន់ម្ដាយ :

-អ្នកម៉ែត្រឡប់មកវិញមក ។

គុណាករឮសំឡេងនាង គេត្រេកអរណាស់ គេងាកទៅមើលស្រី ជាមួយមុខញញឹមពព្រាយ វាចាស្រែកហៅនាង :

-ពនិតា ! បងមកហើយ ។

សំឡេងពនិតាស្រែកពីមាត់ជណ្តើរលើផ្ទះ :

-ឱ្យគេចូលមកចុះអ្នកម៉ែ បើគេត្រូវការកូនរបស់គេ ឱ្យគេមកយកចុះ

ស៊ើរមិនទាន់ចប់ប្រយោគស្រួលបួលផង ពនិតាលោតទម្លាក់ខ្លួនពីលើផ្ទះ មកដីតែម្តង ។ នាងមានបំណងឱ្យរូបនាង និងកូនស្លាប់ព្រមគ្នា ។ ព្រោះយ៉ាងណារហូតមកដល់ពេលនេះហើយ គុណាករមិនបានត្រូវការរូបនាង ក្រៅតែពីរូបកូនឡើយ ។ មនុស្សប្រុសម្នាក់នេះធ្វើខុសហើយ មិនព្រមលួងលោមនាង ទើបនាងឈឺចិត្តយ៉ាងនេះ ក៏សម្រេចជ្រើសរើសយកការស្លាប់ជាមួយកូន ដើម្បីជាការសងសឹកដែលគេត្រូវការកូន ដោយមិនឱ្យបំណងគេបានសម្រេច ។ ជាការពិត ទាំងពនិតា ក៏ដូចជាគុណាករ ពួកគេទាំងពីរសុទ្ធតែជាមនុស្សចិត្តក្តៅ ចង់ឈ្នះចង់ចាញ់គ្នាទៅវិញទៅមក ដោយមិនព្រមសារភាពនូវសេចក្តីត្រូវការរបស់បេះដូងរៀងខ្លួនឡើយ ។ កាលបើឃើញពនិតាលោតទម្លាក់ខ្លួនពីលើផ្ទះមកដី គុណាករក៏ដូចជាម្តាយនាង ភិតភ័យជាខ្លាំង ស្រែកឡើងភ្លាត់សំឡេង :

-ពុទ្ធោ!ពនិតា ហេតុអីអូនចាំបាច់ធ្វើបែបនេះ ។ "គុណាករស្រែកទាំងរត់ទៅរកនាង "

-ពុទ្ធោ!កូនម្តាយ ។ " ម្តាយនាងស្រែកទាំងរត់ទៅរកនាងដែរ "

គុណាករស្ទុះទៅបីត្រកងពនិតាពីក្នុងថ្លុកឈាម ព្រោះកូនអាចនឹងរលូតដូចបំណងស្រីហើយ ។ ពនិតាឈឺចុកចាប់ពេញពោះ នាងខាំមាត់និយាយទាំងកំហឹងមកកាន់គុណាករ :

-ខ្ញុំសម្លាប់កូនលោក ព្រោះវាជាកូនដែលកើតព្រោះសេចក្តីមើលងាយរបស់លោកមកលើរូបខ្ញុំ...លោក...

ពនិតានិយាយលែងរួច ព្រោះនាងចុកចាប់ពេក នាងចុកចាប់ទាំងផ្ទៃពោះ ចុកចាប់ទាំងបេះដូង នាងមិនមែនមិនស្តាយទេ ព្រោះពេលនេះ កូនអាចនឹងស្លាប់បាត់ទៅ ... ធីតាអូលអាក់ តែនាងក៏ធ្លាប់បារម្ភពីកូនដែរ ដោយបើកូននេះរស់នៅ នៅពេលវាកើតមក វាអាចនឹងមិនមែនជាក្មេងដែលមានសុខភាពល្អ ឬមាំមួន ព្រោះថា គ្មានថ្ងៃណាមួយដែលនាងមិនក្តៅក្រហាយ ចំពោះអំពើរបស់ឪពុកវាមកលើនាងឡើយ ។ដូចនេះកាលបើមានកូននៅក្នុងផ្ទៃ ហើយម្តាយចេះតែមានរឿងមួម៉ៅក្តៅក្រហាយ មុខជាបង្កការប៉ះពាល់ដល់ការលូតលាស់របស់ទារកក្នុងផ្ទៃ ទាំងសុខភាព ទាំងសតិបញ្ញា។ តែទោះជាយ៉ាងណាប្រសិនជាពេលនេះ កូននឹងទៅចោលនាងមែន នោះពនិតាសោកស្តាយកូននាងសោកស្តាយដែលកំហឹងមួយរឹប ធ្វើឱ្យនាងគិតខ្លីយ៉ាងនេះ ។ នាងខឹងខ្លួនឯងផង ខឹងគុណាករផង ស្តាយកូនផង ឈឺរបួសផង តែចិត្តរឹងរូសរបស់នាងមិនត្រូវការពឹងជំនួយគុណាករឡើយ ។ ទីបំផុត នាងកញ្ច្រោលរើមិនឱ្យគុណាករត្រកងបីនាង ទាំងស្រែកតិចៗដោយគ្មានកម្លាំងៈ

-លែង...លែងខ្ញុំ ទុកឱ្យខ្ញុំស្លាប់ចុះ អ្វីៗវានឹងចប់ ។

ស្រែកបានតែប៉ុណ្ណេះ ពនិតាសន្លប់បាត់មាត់។ គុណាករភ័យណាស់ គេលើកបីនាង ទាំងគេស្រែក :

-ពនិតាកុំកើតអីណា៎ ។

-កុំកើតអីឱ្យសោះកូនម្ដាយ ។

គុណករបីពនិតារត់ទាំរករថយន្ត ដោយអ្នកស្រីណារត្នរត់តាមពីក្រោយ ទាំងទឹកភ្នែកសស្រាក់ ។ រថយន្តបោះពួយទៅមុខដូចព្យុះ ដើម្បីនាំពនិតាទៅកាន់មន្ទីរពេទ្យ ។ មួយស្របក់ប៉ុណ្ណោះ រថយន្តក៏នាំពួកគេមកដល់មន្ទីរពេទ្យ ។ គុណករបីពនិតារត់ចូលទៅក្នុងមន្ទីរពេទ្យទាំងភ្នែកនៅកញ្ជឹងក ។ ម្ដាយរបស់ពនិតារត់តាមគេទាំងពីរផង យំផង ។

ពនិតាត្រូវបានបញ្ជូនទៅកាន់បន្ទប់សង្គ្រោះបន្ទាន់។ ទាំងគុណករ ទាំងអ្នកស្រីណារត្នអង្គុយរង់ចាំស្ដាប់លទ្ធផលពីអាការៈពនិតា ដោយចិត្តខ្វាយខ្វល់និងអន្ទះអន្ទែង ។ មួយរយៈពេលកន្លងផុតទៅ ទ្វារបន្ទប់សង្គ្រោះបន្ទាន់បានរបើក លោកគ្រូពេទ្យម្នាក់បានដើរចេញមក គុណករស្ទុះរឹងទៅជិតលោកគ្រូពេទ្យ មុនម្ដាយពនិតាទៅទៀត ទាំងគេបន្លឺសួរ :

-លោកគ្រូពេទ្យ ...នាង...នាងយ៉ាងម៉េចហើយ ?

-ខ្ញុំតូចចិត្តណាស់ ដែលមិនអាចជួយកូនក្នុងផ្ទៃបាន តែម្ដាយផុតពីគ្រោះថ្នាក់ហើយ ។

និយាយបានប៉ុណ្ណេះ ពេទ្យក៏ដើរហួសទៅ ។ អ្នកស្រីណារត្នងាកមកមើលមុខគុណករ ដោយក្រសែភ្នែកស្រងូតស្រងាត់ គាត់មិននឹកស្មានថា ពនិតាចិត្តខ្លាំងដល់ម្លឹង ។នៅពេលដែលកូនស្រីគាត់ជួបអាសន្នដ៏ធំនេះ ទឹកចិត្តគុណករបានបង្ហាញឱ្យឃើញថា គេស្រឡាញ់កូនស្រីគាត់ គេមានការស្ដាយក្រោយចំពោះកំហុសរបស់គេ គេឈឺចាប់អាណិតកូនស្រីគាត់ដែលកំពុងឈឺខ្លួន ។ អ្នក

ស្រីមិនស្រដីអ្វីទៅកាន់គុណាករទេ គ្រាន់តែគាត់សម្លឹងមកគេយ៉ាងស្ងៀមស្ងាត់ ។ គុណាករដើរមកជិតម្ដាយពនិតា មុខដ៏ឈឺចាប់របស់គេសម្លឹងមកស្ត្រីចំណាស់ជាមួយទឹកភ្នែកដែលហូរមកលើថ្ពាល់ បុរសពោលដោយអួលអាក់ :

-ពេញចិត្តពនិតាហើយអ្នកម៉ែ ដែលនាងសម្លាប់កូនខ្ញុំទាល់តែបាន ។

គេអាក់សម្ដីបន្តិច ព្រោះទ្រូងវាអួលណែនពេក រួចគេខាំមាត់ វាចាដាច់ៗមកថា :

-ខ្ញុំវាអាក្រក់...នាងអត់ទោសឱ្យខ្ញុំម្ដងមិនបានទេ ... នាងធ្វើបាបកូនខ្ញុំធ្វើបាបគ្នាទាល់តែបាន ។

ទឹកភ្នែកដណ្ដើមហូរចេញពីភ្នែកគុណាករមករហាម នរៈឈឺផ្សាណាស់គេដើរចេញពីមុខម្ដាយពនិតា ហាក់មិនចង់រំលឹកពីអ្វីដែលកន្លងមក ។ បាត់កូនទៅហើយ ... ហើយពនិតាមិនដឹងជាមានអារម្មណ៍បែបណាចំពោះគេ ចំពោះកូន ។ គុណាករមិនចង់ជួបមុខពនិតានាពេលនេះទេ គេពិបាកនឹងអត់ឱនឱ្យនាងតែគេក៏ពិបាកនឹងបន្ទោសនាងដែរ ។ អ្វីទាំងអស់ជាកំហុសគេ ជាកំហុសនាងដែលកំហុសនោះអាចផ្ដើមឡើងពីការស្រឡាញ់គ្នាទៅវិញទៅមក ហើយដែលគេទាំងពីរមិនហ៊ាននិយាយការពិតដូចគ្នា ។

អ្នកស្រីស្រងូតចិត្ត គាត់ក៏ជាម្ដាយមួយរូបដែរ គាត់យល់ចិត្តគុណាករនាពេលនេះ រួចគាត់ក៏អាចយល់ចិត្តពនិតាដូចគ្នា ។ ស្រីចំណាស់តាមសម្លឹងគុណាករមួយភ្លែត គាត់ដកដង្ហើមធំមួយឃ្លូរ ទើបបែរកាយដើរមករកបន្ទប់ដែលពនិតាគេងសម្រាក ។ នៅពេលដែលគាត់ចូលដល់ក្នុងបន្ទប់ គាត់ឃើញ

ពនិតាគេងយំរហាម ។ វង្វង់មុខស្លេកស្លាំងរបស់ពនិតាបង្ហាញពីចិត្តសោកចិត្តស្រពោនរបស់នាង ដែលកំពុងហេងហាងព្រោះបាត់កូន ព្រោះបាត់បុរសដែលនាងលបស្រឡាញ់ដែរ តែគ្មានឱកាសបាននិយាយល្អជាមួយគ្នា ។ លុះយល់ម្ដាយមកជិត ភាពរឹងស្ងួតដែលមាននៅក្នុងចិត្តពនិតា ក៏កាន់តែរឹងស្ងួត ស្រីស្រែកហៅម្ដាយទាំងចិត្តអួលផ្សា :

-អ្នកម៉ែជួយកូនផង...ហ៊ឹក ហ៊ឹក ...គេទៅណាហើយ ?

-គេទៅបាត់ហើយ...គេតូចចិត្តណាស់កូន ។

ពនិតាស្រាប់តែស្រែកយំង៉ោងតែម្ដង :

-អ្នកម៉ែខ្ញុំខុសហើយ ... ខ្ញុំខុសហើយ ខ្ញុំអាក្រក់ណាស់ ហ៊ឹក ហ៊ឹក ។

អ្នកស្រីណារត្នស្រវាឱបពនិតាមកផ្ទប់ក្នុងទ្រូង ពោលលួងលោមនាង :

-កុំតូចចិត្តអីកូន អ្វីដែលកន្លង វាក៏កន្លងទៅហើយ ។ កូនត្រូវតែទប់ចិត្តណាកូន ។ កុំអស់សង្ឃឹមកូន ជីវិតមនុស្សមិនមែនចេះតែសប្បាយទេកូន តស៊ូណាកូន...ណាកូនម្ដាយ ។

-គេប្រហែលជាស្អប់កូនរហូតមួយជីវិតហើយអ្នកម៉ែ ។ ព្រោះកូនបានសម្លាប់កូនខ្លួនឯង ហ៊ឹក ហ៊ឹក កូនមិនគួរធ្វើបែបនេះទេមែនទេអ្នកម៉ែ ?

-បណ្ដោយទៅតាមដំណើរទៅកូន ។ កូនអត់គេ កូនបាត់កូន តែកូនមានម្ដាយម្នាក់ ក៏អាចគ្រប់គ្រាន់ហើយ... ព្រោះលើលោកនេះ អ្នកណាគេនឹងមកស្រឡាញ់កូន ដូចដែលម៉ែស្រឡាញ់កូននោះ... ណាកូនណា ។

ពនិតានៅតែយំមិនឈប់ ។ អ្នកស្រីណារត្នស្ងួតអាណិតកូនស្រី តែគាត់ព្យាយាមលួងលោមនាងជាបន្ត ដើម្បីកុំឱ្យនាងឈឺចាប់ពេក :

-កុំគិតច្រើនកូន គាល់ណាជា យើងទៅផ្ទះយើងវិញ ហើយអ្វីៗវានឹងអស់អីហើយកូន ...វាមិនអីមែនណ៎ាកូន ។

ពនិតានៅតែខ្សឹកខ្សួលក្នុងទ្រូងម្ដាយ នាងយំមិនឈប់ យំឈឺចាប់ យំខឹងនឹងខ្លួននាងដែលធ្វើអ្វីដោយការឆេវឆាវ...រហូតកូនទៅចោលនាង ... រួចគុណករក៏ទៅចោលនាងដែរ...

## -១០-

នៅពេលដែលពនិតាចេញពីមន្ទីរពេទ្យបានពីរថ្ងៃ លោកស្រីម៉ាណេត សិទ្ធិយ៉ា និងមេត្រីបានមកលេងនាង ដោយនិយាយលួងលោមឆោមឆើត ឱ្យធូរស្រាលពីកង្វល់ ។ ដោយសារតែក្តីទុក្ខសោកដោយការស្លាយកូន ដែលបាត់បង់ទៅ ពនិតាសុខចិត្តសំងំខ្លួនរស់ជាមួយម្តាយមួយរយៈ ដោយនាងត្រូវព្យួរការសិក្សានៅមហាវិទ្យាល័យ ។

ពេលវេលាបោះពួយទៅមុខគ្មានរង់ចាំនរណាឡើយ ឥឡូវនេះ ជាងបីខែហើយ ដែលបន្ទាប់ពីកូនក្នុងពោះបានទៅចោលស្រី ដែលស្រមោលគុណាករមិនបានមកស្រីសោះ ... មានតែសិទ្ធិយ៉ា និងមេត្រីតែងតែមកលួងលោមពនិតាហើយយូរម្តង១ នាពេលទំនេរពីការងារមើលខុសត្រូវក្នុងការលក់ផ្ទះក្នុងបុរីកៃលាស លោកស្រីម៉ាណេតក៏មកសួរសុខទុក្ខពនិតាដែរ ។ ឃើញថា បាត់តែបុរសកំពូលស្នេហ៍របស់ពនិតា ហើយដំណើងអ្វីពីគេ ក៏នាងមិនបានដឹងដែរ ។

ពេលវេលាកន្លងទៅមួយរយៈទៀត កង្វល់ និងទុក្ខសោកក៏រសាយខ្លះពីចិត្តពនិតា តែនាងដឹងថា ចិត្តនាងហាក់ដូចជានៅតែគិតដល់គុណាករ នាងចង់ជួបគេ ចង់សុំទោសគេ នឹងចង់ឱ្យគេសុំទោសនាងវិញដែរ ។ ប៉ុន្តែច្រើនខែកន្លងទៅ ពនិតារសើរងរៃបីដូចជាបក្សីត្រូវភ្លើងឆេះសំបុក សូម្បីតែគុណាករក៏មិនដែលឃើញមករកនាង ។

រាត្រីនេះ ពនិតាគេងនៅក្នុងបន្ទប់ដែលពន្លត់ចង្កៀង នៅសល់តែពន្លឺស្រអាប់នៃរស្មីព្រះចន្ទដែលជះចូលតាមបង្អួច ។ នេត្រាល្ងឹងល្ងើយរបស់ធីតាសម្លឹងតារាដែលរះអមកំដរចន្ទ្រា ... កល្យាណស្រណោះខ្លួនដែលហេងហាងក្នុងជីវិត ដែលបាត់បង់មនុស្សជាទីស្រឡាញ់ផ្ទួនៗគ្នាយ៉ាងនេះ គឺបាត់កូន គឺបាត់បុរសដែលនាងលួចស្នេហ៍ តែស្រីមិនហ៊ានស្តី មិនហ៊ានបង្ហាញចិត្តឱ្យអ្នកប្រុសយល់ដោយការលើកទោសដល់គេ ព្រោះគេក៏មិននិយាយឱ្យច្បាស់លាស់ពីទឹកចិត្តគេ ចំពោះនិមលវិញដែរ ។ យប់នេះ លើវេហា លោកខែមានផ្កាយរះអមតែពនិតាវិញគ្មានសល់អ្នកណា ក្រៅពីម្តាយនោះឡើយ ។ កំពុងស្លុងជាមួយការសោកសង្រេង ស្នូរទ្វារបន្ទប់បើកក៏លាន់ឮដល់ត្រចៀកពនិតា ស្រីបន្លឺសួរទាំងមិនដកនេត្រាពីការសម្លឹងហ្វូងតារា :

-អ្នកណាចូលមកហ្នឹង ? ម៉ាក់អ្ហែះ ?

គ្មានចម្លើយ តែស្នូរជើងរំកិលមករកពនិតា ។ ស្រីមិនបានងាកមើលដដែល តែមាត់នាងសួរម្តងទៀត :

-អ្នកណាហ្នឹង ?

-បង !

ភ្ញាក់ដូចជាជាន់ក្បាលពស់ ព្រោះសំឡេង "បង" នេះ ជាសំឡេងគុណករតែម្តង ។ ពនិតាស្ទុះងើបពីទីគេង នាងអង្គុយច្រងក់ បើកភ្នែកធំៗសម្លឹងមកអ្នកប្រុសដែលដើរមកកាន់តែជិតនាង ។ ដៃម្ខាងរបស់ពនិតាលូកទៅចុចកុងតាក់ភ្លើង ។ ពន្លឺអគ្គិសនីបាចសាចពេញបន្ទប់ពនិតា ធ្វើឱ្យស្រីបានឃើញរង្វង់

ភក្រ្តដ៏ស្គមរបស់បុរសដែលនាងនឹក ។ ភ័យផង រំភើបផង នួនល្ងងសម្លឹងមុខគេ ដោយភាំង ស្រីក្មេចទាំងស្ងួរនាំអ្វីទៅកាន់គេ ។ គុណាករដាក់បង្គុយជិតថ្ងៃ គេមើលមុខនាង គេឃើញថា នាងស្គមច្រើនណាស់ ស្គមដូចជាគេដែរ ព្រោះមេរៀនជីវិតដែលពួកគេជួបប្រទះកន្លងទៅមួយនេះ បានដាក់ទណ្ឌកម្មដល់ពួកគេទាំងពីរ ដូចគ្នា ។ ពនិតាស្រាប់តែបន្លឺវាចាញ័រៗមកកាន់បុរស :

-ហេតុអីលោកមករកខ្ញុំ ? បើលោកមិនមានសល់អ្វីទៀត ជាប់នឹងខ្លួនខ្ញុំផង ។

មុខឈឺចាប់របស់បុរសបានបង្ហាញក្រោមក្រសែភ្នែកពនិតាយ៉ាងច្បាស់ ជាមួយការបានឮនូវប្រយោគខាងលើរបស់ស្រី ដោយគុណាករគ្រវីក្បាលយឺតៗ គេស្រដី :

-គ្មានទេ ។

អាការៈខុសពីមុនរបស់បុរស ដែលធ្លាប់តែឫកធំ និងក្អេងក្អាង ហើយស្រាប់តែក្លាយមកប្រុសដ៏ស្លូតដូចជាកូនចៀមមួយក្បាលបែបនេះ ពនិតារន្ធត់ចិត្តជាខ្លាំង នាងគិតថា ការបាត់បង់កូនជាមូលហេតុដែលបានកែប្រែចរិតរបស់គេហើយ ។ ព្រោះពនិតាក៏បានទទួលការឈឺចាប់ សោកស្តាយមិនខុសពីគេដែរ ទើបនាងបន្ទន់សម្តីពោលទៅកាន់គេ :

-គុណាករមកសងសឹកខ្ញុំទៀតអ្ហេះ ព្រោះខ្ញុំធ្វើឱ្យបាត់កូនលោកនោះ ។

-មិនមែនទេ ។ " គេឆ្លើយទាំងមុខស្លូត "

សម្តី និងទឹកមុខរបស់គេបង្ហាញប្រាប់ថា គេអត់ឱនឱ្យនាងហើយ ហើយទឹកមុខនេះក៏មានន័យដូចជាប្រាប់ថា គេកំពុងសុំទោសនាងតាមរយៈកែវភ្នែក និងទឹកមុខដែរ ។ ពនិតាអួលណែន ព្រោះការសុំទោសនេះ វាសមតែនាងជាអ្នកស្រដីទៅកាន់គេមុន ព្រោះនាងសម្លាប់កូន ។ កាលបើនឹកដល់កូន ស្រីក៏ស្តាយស្រណោះដល់កូន ស្រីក៏អាណិតគេដែលគេស្រឡាញ់កូន ... ពនិតាយំរហាម យំដោយស្ងៀមស្ងាត់មិននិយាយអ្វី ។ គុណាកររំជួលចិត្តអាណិតស្រី គេលូកដៃមកចាប់ដៃនាង បន្លឺតិចៗ :

-ឈប់គិតទៅចុះ អ្វីអាក្រក់ៗ វាកន្លងទៅហើយ ។

-តែហេតុអីលោកមករកខ្ញុំ ? លោកមកធ្វើអ្វី ? បើលោកនិយាយពាក្យថា ឈប់គិតបែបនេះ ។

គុណាករសម្លឹងនាង បាក់រាវរកចម្លើយអ្វីពីកែវភ្នែកស្រី :

-បងមក ព្រោះបងមិនអាចរស់ដោយអត់អូនបាន ។

-ទេ ...ខ្ញុំគ្មានកូនឱ្យលោកទៀតទេ ។

-ទោះជាគ្មានកូន ក៏បងត្រូវការអូន ។

គេទាញដៃនាងមកក្តោបក្នុងដៃគេ ។ ពនិតាញាប់ញ័រក្នុងចិត្ត ហើយនាងមិនច្បាស់ពីទឹកចិត្តបុរសដែរ ស្រីបន្លឺដោយសំឡេងញ័រៗ :

-មិនពិត ...មិនពិត...សុំអាណិតខ្ញុំផងលោក...ខ្ញុំសុំអង្វរ...អ្វីដែលកន្លងមក ខ្ញុំឈឺចាប់សមល្មមនឹងចិត្តគុំខឹងរបស់លោក មកលើខ្ញុំហើយ ។

គុណាករស្រវាឱបនាង ពោលដោយទន់ភ្លន់ :

-បងឈប់អាក្រក់ទៀតហើយ បងសុំសន្យា ។ ត្រឡប់ទៅផ្ទះយើងវិញ យើងនឹងរៀបការណ៍អូន ។

-មិនអាចទៅកើតទេ បើអ្វីដែលលោកធ្វើពេលនេះសម្រាប់តែតបស្នងអំពើអាក្រក់ដែលលោកធ្វើមកលើខ្ញុំតែប៉ុណ្ណោះ ... ខ្ញុំទ្រាំបានហើយ មិនបាច់លោកមកខំទូទាត់ទេ ចាត់ថា អ្វីនោះជាសុបិនអាក្រក់សម្រាប់ខ្ញុំចុះ ខ្ញុំទទួលបាន ។

-មិនមែនសុបិនទេ គឺបងស្រឡាញ់អូន ។បងមិនដឹងថា បងស្រឡាញ់អូនពីពេលណាផង ស្រាប់តែមានការស្រឡាញ់ពេញបេះដូងបងតែម្តង ។

-ទេ...ខ្ញុំមិនជឿ ។ លោកភរ ។

-មែន! មនុស្សដូចបងសាហាវអាក្រក់យ៉ាងនេះ គ្មាននរណាគេនឹងជឿបងទេ តែថ្ងៃនេះបងអង្វរ សុំអូនជឿបងចុះ បងស្រឡាញ់អូនពិត១ ។

-មែនអ្ហេះ ! បងមិនខឹងអូនដែល...

-មិនទេ ! អូនមិនមែនជាអ្នកខុសទេ ។ អ្នកខុស គឺបង ។ យើងនឹងរៀបការនឹងគ្នាណ៎ាអូន ។" និយាយផង គុណាករទាញកាយស្រីមកឱប"

-រៀបការ ! បងមិនសួរអូនសិនថា អូនស្រឡាញ់បងឬទេ ? "ពនិតាស្រដីទាំងញញឹមក្នុងទ្រូងបុរស"

-មិនទេ ! មិនបាច់សួរទេ បើសួរទៅអូនមុខជាឆ្លើយថា អត់ស្រឡាញ់បងទេ គឺអត់សូម្បីតែបន្តិចក៏គ្មានផង ។

-ហេតុអីអូនស្រឡាញ់បងមិនបាន ? បើបងស្រឡាញ់អូនបាន ។

-មែនអ្ហេះពនិតា ?

- ចាសមែន អូនស្រឡាញ់បង ។

-ពនិតា ! បង...

គេសម្លឹងមុខនាង ដោយក្ដីរំភើបដែលបានឮសម្ដីស្រីមានន័យស្រឡាញ់គេ ដូចគេស្រឡាញ់នាងដែរ ។ ពនិតាញញឹម នាងនិយាយបន្ត :

-អូនដឹងខ្លួន ពេលដែលកូនយើងទៅបាត់ទៅ ។ អូនតូចចិត្តដែលខ្លួនអូនចង់ឈ្នះបង ដោយអូនគិតថា អូនសងសឹកបង ឱ្យដល់ទីបំផុត...តែដោយសារការសងសឹកនេះ ...ធ្វើឱ្យកូន... កូនយើង ... ហ៊ុក ហ៊ុក គេទៅ...

-រៀបការហើយ យើងចង់បានកូនប៉ុន្មាន គង់នឹងបានទេអូន ។

បុរសស្រដី ព្រមទាំងលូកដៃមកបិទមាត់នួននាងមិនឱ្យវាចាបន្ត រួចគេយកដៃទៅជូតទឹកភ្នែកស្រីដែលហូរ ដោយសារនោមឆើតឈឺចាប់ដោយការបាត់បង់កូន ។ បន្ទមក បុរសចាប់នាងផ្ដេកទៅលើគ្រែ នរះលើកក្បាលស្រីមកកើយភ្លៅគេ គេស្រដីទន់ភ្លន់ ទាំងច្របាច់ដៃនួនល្អងថ្នមៗដើម្បីជាការផ្ដល់ភាពកក់ក្ដៅដល់នាង :

-អ្ហឹៗកន្លងទៅ ដូចភ្លៀងរាំង ។

..................................................................................................

..................................................................................................

សន្លឹកប្រក្រតីទិនរបើកជាបន្តបន្ទាប់ ពេលវេលាដែលគុណករនិងពនិតាបានរង់ចាំ ក៏បានមកដល់ គឺពួកគេបានរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយ ។

ក្រោយពីរៀបការ ពួកគេបានមករស់ក្រោមដំបូលវិមានលោកស្រីម៉ាណេត ។ ឯមេត្រី និងសិទ្ធិយ៉ា ក៏បានរៀបមង្គលការក្រោយអ្នកទាំងពីរ ប្រហែលជាបួនខែប៉ុណ្ណោះ គឺបន្ទាប់ពីមេត្រីប្រឡងបញ្ចប់ឆ្នាំសិក្សាទី៥នេះ ។ ព្រោះពនិតាមិនបានបន្តការសិក្សានៅឆ្នាំនេះទេ ដោយលុះត្រាតែឆ្នាំក្រោយ ទើបនាងចូលរៀនវិញ ។

ថ្ងៃមួយនេះ ក្នុងបន្ទប់ដំណេករបស់ប្តីប្រពន្ធគុណករ យើងឃើញនរៈគេងនៅលើពូក ដោយអាការៈសន្ធឹងសន្ធៃបោះដៃបោះជើង ដូចជាល្ហើយសម្បើមណាស់ ។ ស្រីពនិតាដើរចេញពីបន្ទប់ទឹក នាងដាក់កាយអង្គុយលើពូកប្របកាយស្វាមី នាងស្រដី :

-បងគុណភ្ញាក់ឡើង ថ្ងៃហើយណា៎ ។

-បងភ្ញាក់យូរហើយ តែបងក្រោកមិនកើត បងអស់កម្លាំងល្ហើយ ។

-ហ៊ឺះ ! មាយាទៀតហើយ ។

-អ៊ំ ! ប្រពន្ធបងកាចណាស់ហ្ន៎ បងអស់កំលាំង ថាបងមារយា ។ បងមិនបានភរអូនទេណា៎ បើបងក្រោកទៅ ចេះតែវិលមុខ ផែនដីចេះតែផ្អៀងៗ ។

-មែនអ្ហេះបង ?

ពនិតាមានទឹកមុខបារម្ភពីអាការៈបុរស ធីតាយកដៃទៅស្ទាបថ្ងាសគេរួចស្រីវាចា :

-សាច់បងអត់ក្តៅ ។

ភ្លាមនោះ គុណាករស្ទុះងើបពីគ្រែ គេរត់ទៅរកបន្ទប់ទឹកផង ស្រដីផង:

-បងចង់ក្អួត ។

ពនិតារត់ទៅតាមប្ដី ។ មកដល់ក្នុងបន្ទប់ទឹក នរៈក្អួតវ៉ក១ ស្រីល្អយកដៃគក់ខ្នងគុណាករ ទាំងនាងបន្លឺ :

-បងញ៉ាំចំណីខុសទេដឹង ?

-បងអត់មានញ៉ាំអីមិនល្អទេអូន ។

ក្អួតមួយស្របក់ គុណាករដូចជាស្រឡះមុខមាត់បន្តិច ។កល្យាណត្រាហ៍អ្នកប្រុសមករកគ្រែវិញ ។ គុណាករប្រះគេង បិទភ្នែកដោយល្ហើយ ។ ធីតាដណ្ដប់ភួយឱ្យគេ នាងពោលវាចា :

-ខ្ញុំទៅយកសេនមកកោសខ្យល់ជូនបងណា៎ ។

-យកប្រេងខ្យល់ឱ្យបងផង ។

-ពីមុនក្រែងបងស្អប់ប្រេងខ្យល់អេ្ហះ ? ចាំបន្តិចអូនយកឱ្យ ។

-អ៊ូ!អូនឆ្វៀតទៅយកដំណាប់អំពិលក្នុងទូរទឹកកក ឯបន្ទប់ចង្ក្រានឱ្យបងផង ។

-ដំណាប់អំពិល ! ហេតុអីបង...

-បងដូចជាភ្លាវមាត់...ចង់ញ៉ាំអីជូរ១ណា៎អូន ។

-ចាស ចាំអូនយកមកជូន ។

ពនិតាដើរទៅក្រៅបន្ទប់ ដើម្បីរកសេន ប្រេងខ្យល់ និងដំណាប់អំពិលតាមការត្រូវការរបស់ស្វាមី ។ នៅពេលស្រីរកបានរបស់ទាំងនោះគ្រប់គ្រាន់

ហើយ ធីតាបែរកាយដើរមកបន្ទប់វិញ ស្រាប់តែនាងមកជួបមាតាក្មេក នៅជិតទ្វារបន្ទប់ លោកស្រីម៉ាណេតសម្លឹងមកដំណាប់អំពិលក្នុងដៃកូនប្រសា គាត់បើកភ្នែកធំៗ ញញឹមជាប់មាត់ ស្រដី :

-ហ្អាក! ដំណាប់អំពិល ។

-ចាស ម៉ាក់ ។

-អ៊ូ ! ម៉ាក់ជិតបានចៅហើយហ្នឹង ។

-ទេ ! កូនអត់កើតអីទេ បងតើចង់ពិសា ។

-ប្ដីចង់ម្ជូរទាំងព្រលឹម ហាស់ ហាស់ ។ តាមម៉ាក់ណា៎ ទៅពេទ្យទាំងពីរនាក់ ឱ្យគេពិនិត្យទៅកូន ។

-ចាស ម៉ាក់ កូននិងបងនឹងទៅពេទ្យឱ្យគេពិនិត្យ ។ " ធីតាឆ្លើយទាំងមុខអៀនអន់ "

ក្រោយពីទទួលការណែនាំពីលោកស្រីម៉ាណេត ពនិតានិងគុណករ ក៏បានមកពិគ្រោះជាមួយគ្រូពេទ្យ ពីអាការសុខភាពរបស់គុណករ និងភរិយា ។ ជាលទ្ធផល លោកគ្រូពេទ្យញញឹមបន្លឹមកកាន់ពួកគេ ដោយប្រយោគ :

-លោកស្រីទម្ងន់ជាងមួយខែ ។ នេះវេជ្ជបញ្ជា សូមលោកពិសាថ្នាំតាមនេះចុះ ។

-បាទ អរគុណលោកគ្រូពេទ្យ ។ ខ្ញុំជម្រាបលាហើយ ។

-ខ្ញុំក៏ជម្រាបលាលោកដែរ ។

-បាទ អញ្ជើញ ។

នៅពេលបណ្តើរគ្នាចេញពីបន្ទប់គ្រូពេទ្យមកវិញ គុណករញញឹម ស្រដីទៅកាន់នួនល្អង :

-បងមានទម្ងន់រាប់សិបគីឡូ មិនគួរចាញ់អាញ៉ក់ក្នុងពោះអូនសោះ ហាស់ ហាស់ ។

-អីចឹងហើយ ទេព្តាមានភ្នែក កុំឱ្យរែកពុនតែស្រីៗពេក ហាស់ ហាស់ តែប៉ុណ្ណេះបងនឹងអាចប្រាប់ប្រុសៗដូចគ្នាឱ្យដឹងថា មនុស្សស្រីចាញ់កូននោះមានការពិបាកយ៉ាងណា ហាស់ ហាស់។

-ហាស់ ហាស់ ! បងខ្លាចហើយអូន ... តែអូនហ្អា បងដូចជាមិនស្រួលទេ ... ក្បាលបងចង់ក្រឡាប់ចុះក្រោម...

មែនហើយ ! គឺគុណករស្រាប់តែមានអាការដូចជាវិលមុខភ្លាមៗ ។ គេលូកដៃមកតោងជញ្ជាំងមន្ទីរពេទ្យ ។ ពនិតាភ័យណាស់ នាងប្រញាប់ជួយទប់កាយស្វាមី ទាំងបន្លឺដោយញ័រមាត់បប៉ុប :

-បង !

-អូនទៅរកទិញពុទ្រាត្រាំឱ្យបងមក ព្រោះបើបងបានញ៉ាំអីជូរៗ បងនឹងលែងអីហើយ ។

-ចាស បង ។ ចាំអូនទៅរកទិញជូនបងភ្លាម ។

ជាមួយវាចា ស្រីគ្រាហ៍ប្តី ដើរទៅរករថយន្ត ។ ក្រោយពីដាក់ស្វាមីឱ្យផ្អែកកាយស្រួលបួលក្នុងយាន ពនិតាស្ទុះទៅរករទេះលក់ផ្លែឈើមួយ ដែលនៅ

មិនឆ្ងាយពីទីចតរថយន្ត ។ គុណាករក្រឡេកឃើញភរិយារត់យ៉ាងនេះ គេស្រែកឃាត់ស្រី ដោយក្តីបារម្ភ :

-កុំរត់ណាំអូន ខ្លាចមានអ្វីមិនល្អដល់អូន ដល់កូន ។

ពនិតាឈប់រត់ នាងងាកមកមើលគេ ស្រីញញឹម និយាយ :

-អូនសុំទោស ព្រោះអូនភ័យពីបងពេក ហើយអូននឹងដើរវិញណាំបង

គុណាករញញឹម ងក់ក្បាល ទទួលពាក្យភរិយា ។ និមលបានដើរទៅរកទិញបានផ្លែឈើ ទើបស្រីយកមកហុចឱ្យគុណាករ ។ បុរសទទួលពុទ្រាត្រាំមកខំាបរិភោគ ដូចជាឃ្លានខ្លាំងណាស់ ។ ពនិតាញញឹមសម្លឹងស្វាមីញុាំពុទ្រាត្រាំ ទាំងព្រលឹម ។

ពេលដែលរថយន្តនាំពនិតា និងប្តី មកដល់ផ្ទះ ពនិតាលូកដៃប្រុងមកគ្រាហ៍គុណាករ តែអ្នកប្រុសញញឹម ស្រដី :

-បងមានកម្លាំងព្រឹសវិញហើយអូន ។

-មែនអ្ហេះ ? អំបាញ់មិញអូនភ័យសឹងអី ។

ទាំងពីរនាក់ស្វាមីភរិយាបណ្តើរគ្នាដើរចូលទៅក្នុងវិមាន ដើម្បីមករកកៅអីសាឡុងអង្គុយ ។ ក្រោយពីសម្រួលឥរិយាបទបន្តិច គុណាករឱនទៅជិតពោះពនិតា និយាយទាំងញាក់មុខ :

-អស្ចារ្យអាច្រម៉ក់តូចនេះធ្វើបាបបងតើ មើល៍ ! បងសុំស្តាប់មើលស្រី ឬប្រុសអូន ?

-ដឹងស្អីទេ អូនស្អប់ណាស់ ។

ស្រីវាចាទាំងក្របាមមុខ ដោយអៀនអន់ រួចទួនល្អងយកដៃរុញកាយបុរសចេញពីពោះស្រី ដោយវាចាតិចៗ ។ គុណាករធ្វើជាដួលទៅម្ខាង ស្រែក :

-អូយ ។

ឆោមល្អបារម្ភពីស្វាមី ក្រែងគេមិនស្រួលខ្លួនមែន នាងប្រញាប់លើកកាយគេពីទីដួល ដោយនិមលពោលពាក្យ :

-បងមិនអីទេអ្ហេះ អូនភ័យណាំ ។

-បងសាកចិត្តអូនតើ ។ បងមានកើតអី បើកម្លាំងពុទ្រាត្រាំនៅមានពេញខ្លួនតើអូន ។

គុណាករបម្រុងឱនមុខលោទៅរកថ្ពាល់ស្រី តែភ្លាមនោះ សំឡេងមួយឃ្លាលាន់មក :

-ឈប់ៗកុំអាលធ្វើផ្តេសផ្តាសណាំគុណ ។

ឮសំឡេងខាងលើ គុណាករនិងពនិតាងាកមកឃើញបងប្រុស និងមេត្រីបណ្តើរគ្នា ដើរមករកគេនិងភរិយា ។ ការពិតពីម្សិលម៉្ងៃមួយ សិទ្ធិយ៉ាបាននាំមេត្រីទៅសួរសុខទុក្ខលោកស្រីណារីនៅឯខេត្ត ។ លុះលោកស្រីម៉ាណេតបានទូរសព្ទទៅប្រាប់ពួកគេថា ពនិតាអាចនឹងមានផ្ទៃពោះនោះ ទើបសិទ្ធិយ៉ានិងភរិយាប្រញាប់វិលមកវិញ ដើម្បីសួរដំណឹងនេះភ្លាម ។ គុណាករឃើញជាក់ជាបងប្រុស គេគ្រវីក្បាល ញញឹមលាន់មាត់ :

-បងយ៉ាតើ ។ រំខានណាស់បងយ៉ានេះ ។

-បងអត់មករំខានទេ គឺបងមកសួរដំណឹង យ៉ាងម៉េចមានអាច្រម៉ក់មែនអី ? ដើម្បីឱ្យបងមកសុំក្បួនរៀនសូត្រតាមណា៎ ព្រោះពួកបងមិនទាន់រកឃើញពិភពកូនក្មេងសោះ ។

-ពិតហើយបងយ៉ា ខ្ញុំពិតជាចាញ់អាតូចមែន ហើយមេរៀនមួយនេះចាំខ្ញុំឪ្យបប្រាប់បងណា៎ ។

-អឺចឹងឪ្យបប្រាប់បងភ្លាមមក ។

គុណាករខិតទៅជិតបងប្រុស ធ្វើកាយវិការដូចជារបៀបឪ្យបសិទ្ធិយ៉ាតែមេត្រីបានទាញកាយប្ដីមកកៀកនាង ដោយកល្យាណក្ដិចដើមដៃអ្នកប្រុសនាងវាចា :

-ផ្ដេសផ្ដាសណាស់បងយ៉ា ។ អូនមិនឱ្យបងស្ដាប់គុណាឪ្យបទេ ។ តោះយើងទៅជម្រាបសួរអ្នកម៉ាក់ឯក្នុងបន្ទប់វិញ ។

សិទ្ធិយ៉ាត្រូវដើរតាមការអូសរបស់ភរិយា ដោយនរៈធ្វើកាយវិការដូចជាខ្លាចមេត្រីណាស់ ។ គុណាករ និងពនិតាសើចនឹងភាពក្រម៉ាចក្រមើមរបស់បងប្រុស និងមេត្រី ។

**ចប់**